01376846

E1/490.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤៧១**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jan-2017, 11:32
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ស្រី រតនះ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ជួន ធី (2-TCW-859) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ជួន ឌី** (2-TCW-859)


សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី.................................................................... ទំព័រ ២

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ............................................................................ ទំព័រ ១៤

សួរដោយ វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................................................................ ទំព័រ ៦៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ជួន ធី បញ្ចប់ ហើយនិងមានសាក្សីបម្រុង 2-TCW-1045។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក ជួន ធី។ លោក និងមេធាវីប្រឹក្សា គឺលោកស្រី សុក សុជាតា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

នៅថ្ងៃនេះដែរមានសាក្សីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-1045។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាពេលព្រឹកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុន

សិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦។

[០៩:០៣:៤៥]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា ថានៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ អង្គុយយូរ កាន់តែឈឺខ្លាំង និងបានផ្ដល់អនុសាសន៍ សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទនួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ជួន ធី ខ្ញុំសូមបន្តនូវអ្វីដែលយើងបានឈប់សម្រាកកាលពីម្សិលមិញ។

លោកបាននិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកក្នុងការរៀបការ និងបែបបទផ្សេងៗនៅក្នុងអង្គភាពរបស់លោក។ មុននឹងបន្តទៅទៀត ខ្ញុំសុំការបញ្ជាក់មួយពីលោក។ ក្នុងពេលវគ្គរៀនសូត្រ តើលោកធ្លាប់រៀនអំពីសីលធម៌១២ប្រការរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ ជាពិសេសគឺសីលធម៌ប្រការទី៦?

**លោក ជួន ធី៖**

**ឆ៖** សូមគោរព គឺធ្លាប់បានប្រជុំ ហើយធ្លាប់បានរៀនសូត្រអំពីសីលធម៌១២ប្រការរបស់កម្ពុជាប្រជាធិបតេយ្យ គឺធ្លាប់បានរៀន។ តែពេលនេះគឺចាស់ អត់បានចាំគ្រប់ផងហ្នឹង។

[០៩:០៦:១២]

**ស៖** ខ្ញុំសូមរំឭកពីសីលធម៌ទី៦ គឺនៅក្នុងឯកសារ E3/765 ជាទស្សនាវដ្ដីយុវជនយុវនារីបដិវត្តនៅ ERN ជាភាសាបារាំង 00540024, ជាភាសាអង់គ្លេស 00539994, និងជាភាសាខ្មែរ 00376493។ ខ្ញុំសូមបញ្ជាក់ថា ភាសាខ្មែរនិងបារាំងហ្នឹង ខ្ញុំអាននៅទំព័រដូចតទៅ ខ្ញុំសូមដកស្រង់៖ "ប្រការ៦៖ កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ។" និង<នៅទំព័រ>ជាបន្តទៅទៀតជាភាសាបារាំង ជាភាសាខ្មែរនោះ យើងឃើញមានការពន្យល់ ជាពិសេសពាក់ព័ន្ធនឹងបញ្ហារៀបការ និងការរៀបចំគ្រួសារ។ "ចំពោះបញ្ហារៀបចំគ្រួសារបច្ចុប្បន្ននេះ គ្មានអ្វីជាឧបសគ្គទេ ឲ្យតែឈរលើគោលការណ៍របស់បក្សទាំងពីរយ៉ាង គឺទី១ សាមីខ្លួនទាំងសងខាងយល់ព្រម។ ទី២ សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ។ តើមានហេតុផលអីនាំឲ្យយើងប៉ះពាល់សីលធម៌នារីបុរសនោះ?" សូមបញ្ចប់ការដកស្រង់។

ដូច្នេះខ្ញុំសួរថា ចំណុចនេះធ្វើឲ្យលោកនឹកឃើញឡើងវិញទេ? ហើយនៅក្នុងពេលរៀនសូត្រនោះ គេមាននិយាយអំពីការរៀបការ ហើយនិងលក្ខខណ្ឌដែលគ្រប់គ្រងទៅលើការរៀបការទាំងអស់ហ្នឹងដែរទេ?

**ឆ៖** ខ្ញុំសូមគោរព គឺពេលនេះ គឺគេមានការរៀបចំឲ្យហើយ អត់មានគោលការណ៍អីទេ គឺការសម្រេចរៀបចំការនេះ ទៅលើការពេញចិត្តទាំងសងខាង។ ហ្នឹងគឺវាបញ្ជាក់ប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកនិយាយថា<នៅពេលដែលការរៀបការត្រូវបានគេរៀបចំឡើង> មិនមានអ្នកណាប្រកែកហ្នឹង អ៊ីចឹងលោកខ្លួនឯងផ្ទាល់ហ្នឹង លោកធ្លាប់រៀបការឲ្យអ្នកណាទេ? ហើយមានអ្នកណាប្រកែកទេ?

**ឆ៖** ខ្ញុំក៏ធ្លាប់រៀបការឲ្យបងប្អូននៅក្នុងអង្គភាពដែរ។ ដូច្នេះការរៀបការក៏មិនមែនជាប្រញាប់

ប្រញាល់អីពេកដែរ គឺធ្វើទៅតាមការពិនិត្យមើលពេលវេលា និងការពេញចិត្តទាំងសងខាងដែរ។ ដូចខ្ញុំបញ្ជាក់អ៊ីចឹង គឺការទាក់ទងរវាងយុវជននិងនារី គឺមិនមានហាមឃាត់ខ្លាំងក្លាទេ ដូច្នេះគេអាចដឹង អាចយល់ទឹកចិត្តគ្នា ដូច្នេះគេរៀបចំឱ្យទៅ គឺអត់មាន។ តែប្រសិនជាមាន អ្នកដែលមិនពេញចិត្តហ្នឹង គឺគេអាចមិនចូលរៀបការ ហើយគេត្រឡប់ទៅកន្លែងគេវិញបាន អត់មានបញ្ហាអីទេ។

[០៩:០៩:៤៥]

**ស៖** ខ្ញុំយល់។ តាមរយៈចម្លើយរបស់លោកហ្នឹង វាដូចជាផ្ទុយពីចម្លើយមុន។ ជាភាសាបារាំងខ្ញុំឮនិយាយថា ពេលដែល<លោកកំពុងនិយាយពីការ>រៀបការហ្នឹង <លោកនិយាយថា “នៅពេលនេះ> គ្មាននរណាអាចប្រកែកបានទេ។” អ៊ីចឹងវាដូចជាផ្ទុយពីអ្វីដែលលោកនិយាយឥឡូវនេះថា បើអ្នកណាគេមិនព្រមហ្នឹងគេមិនបង្ខំអីទេ អាចទៅកន្លែងវិញនេះ។ អ៊ីចឹងលោកអាចបញ្ជាក់ម្តងទៀតទៅមើល?

**ឆ៖** ខ្ញុំសូមបញ្ជាក់ពីលើកមុន ខ្ញុំអត់បានមាននិយាយពីរឿងការហ្នឹងចាប់បង្ខំទេ ខ្ញុំបាននិយាយលើការធ្វើការ ខ្ញុំចាំពាក្យខ្ញុំដែរ។ គឺការរៀបចំការគឺការពេញចិត្តរៀងខ្លួន តែបើអ្នកណាមិនពេញចិត្តគឺគេអត់ចូលរៀបចំការ អាហ្នឹងគឺបានបញ្ជាក់អ៊ីចឹង អត់មានចាប់បង្ខំ អត់មានថាយ៉ាងម៉េចៗ ក្រៅពីនេះគឺអត់មានទេ។

**ស៖** លោកថាគេអត់មានចាប់បង្ខំឱ្យការទេ ក៏ប៉ុន្តែនៅពេលដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត នៅក្នុងឯកសារ E3/10713 លោកថា ទោះបីជាលោកខ្លួនឯងផ្ទាល់មិនដែលឃើញគេរៀបការដោយបង្ខំក៏ដោយ ក៏លោកធ្លាប់ស្តាប់ឮ ថាមានអ្នកដែលនិយាយថាមានការបង្ខំឱ្យរៀបការ។ ខ្ញុំសូមយោងទៅចម្លើយរបស់លោក៤៤ ទៅដល់៥៣ គឺឯកសារ E3/10713។ ដូច្នេះខ្ញុំចង់សួរលោកថា អ្នកណាដែលប្រាប់លោកថា មានការបង្ខំឱ្យរៀបការ? នេះជាសំណួរដំបូង ហើយនាងខ្ញុំនឹងសួរបន្តទៅទៀត។

[០៩:១១:៤០]

**ឆ៖** ខ្ញុំសូមគោរព ខ្ញុំនិយាយពីលើកមុន ខ្ញុំថាសម្រាប់អង្គភាព អ្នកដែលអង្គភាពផ្សេងអាហ្នឹងខ្ញុំមិនដឹងទេ។ តែសម្រាប់អង្គភាពខ្ញុំគឺរៀបចំទៅតាមការស្ម័គ្រចិត្ត នេះខ្ញុំនិយាយលើកមុនគឺខ្ញុំចាំពាក្យអ៊ីចឹងគឺនៅក្នុងអង្គភាពខ្ញុំ កន្លែងខ្ញុំរៀបចំទៅតាមការស្ម័គ្រចិត្ត ការពេញចិត្តទាំងសងខាង។ តែអង្គភាពផ្សេងដែលចាប់បង្ខំអី អាហ្នឹងគឺខ្ញុំអត់ ខ្ញុំក្តាប់អត់បានទេ ខ្ញុំវាគ្រាន់បញ្ជាក់អ៊ីចឹង។ ក្រោយមកគ្រាន់តែឮគេនិយាយគេអីដែរ តែខ្ញុំអត់ដឹង អត់មានដឹង។ តែសម្រាប់អង្គភាពខ្ញុំ និងខ្ញុំមិនដែលមានបញ្ហាហ្នឹងទេ។

**ស៖** អ៊ីចឹងបានន័យថា នៅក្នុងអង្គភាពលោកមិនមានការបង្ខំឲ្យរៀបការទេ។ អ៊ីចឹងលោកមានដឹងទេថា ក្នុងពេលលោករៀនសូត្រ ឬក៏ពេលដែលលោកទទួលសេចក្តីណែនាំពីថ្នាក់លើ ឬក៏ពីកម្មាភិបាលណាមួយនៃបក្សកុម្មុយនីស្តកម្ពុជា លោកធ្លាប់ស្តាប់ឮថា ត្រូវតែបង្ខំមនុស្សឲ្យរៀបការទេ? ហើយទោះបីជាអ្នកសាមីខ្លួនហ្នឹង មិនព្រមក៏ដោយ គឺត្រូវតែរៀបការដាច់ខាត។ លោកធ្លាប់ឮ ធ្លាប់ស្តាប់ឮសេចក្តីណែនាំបែបហ្នឹងទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ គឺខ្ញុំអត់ដែលឮពាក្យថា អ្នកចង់ មិនចង់គឺរៀបការ។ ដូច្នេះគេខាងណោះគេចង់បញ្ជាក់ថា សាមីខ្លួនបើគេចង់មានគ្រួសារ គេចង់បានគ្រួសារ គេប្រាប់មកថ្នាក់ដឹកនាំ ដូច្នេះគេស្រឡាញ់អ្នកណាអីអ្នកណា គឺប្រាប់យើងទៅ យើងនឹងដោះស្រាយទៅតាមសំណូមពររបស់បងប្អូន។ អាហ្នឹងគឺមានអ៊ីចឹង តែឲ្យឮថាត្រូវតែរៀបការ អ្នកបង្ខំ មិនបង្ខំ ទាំងបង្ខំ ទាំងអីគឺអត់មានទេ ខាងខ្ញុំនេះអត់ដែលឮខាងលើអប់រំអ៊ីចឹងផង។

[០៩:១៣:៤៦]

**ស៖** ទោះបីជាមិនមានការបង្ខំឲ្យមនុស្សឲ្យរៀបការក៏ដោយ តើមានសេចក្តីណែនាំឲ្យតាមដានអ្នកដែលទើបរៀបការហើយ ថាតើពួកគេរួមដំណេកជាមួយគ្នា ឬក៏អត់។ មានន័យថា ក្នុងពេលដែលលោករៀនសូត្រនោះ លោកធ្លាប់ទទួលបានសេចក្តីណែនាំណាមួយដែលប្រាប់ថា ត្រូវតែតាមដានប្តីប្រពន្ធដែលទើបតែរៀបការថ្មីនេះ ហើយបើគេមិនរួមដំណេកទេ ត្រូវតែបង្ខំឲ្យពួកគេរួមដំណេកជាមួយគ្នា លោកធ្លាប់បានទទួលសេចក្តីណែនាំបែបហ្នឹងទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ គឺការរៀបចំដូចខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង ដូច្នេះខាងលើមិនដែលណែនាំថាទៅទី១ សម្រាប់អង្គភាពខ្ញុំ កន្លែងខ្ញុំទេ តែមិនដែលចាប់បង្ខំឲ្យអ្នកពេញ មិនពេញចិត្តនឹងគ្នារៀបចំជាមួយគ្នាទេ។ ពេលដែលរៀបចំហើយ មិនឲ្យទៅតាមដានរឿងដំណេកអីជាមួយគ្នា គឺអត់ដែលឮ។ អត់មានដែលឮអ្នកខាងលើឲ្យតាមដានទេ ខ្ញុំអត់ដែលក្តាប់បាន អត់ដែលឮសោះ តាំងពីខ្ញុំធ្វើមេដឹកនាំដែរ ខ្ញុំក្តាប់អង្គភាពហ្នឹង អត់ដែលឮទេ។ គ្រាន់តែអាហ្នឹង គឺសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ខ្ញុំយល់ហើយ លោកនិយាយអំពីអង្គភាពរបស់លោក។ ហើយមានមនុស្សជាច្រើនមកផ្តល់សក្ខីកម្មនៅទីនេះ ពួកគាត់បញ្ជាក់ថា <ពួកគេត្រូវបាន>អាជ្ញាធរភូមិឃុំនោះ <>បង្ខំឲ្យរួមដំណេក។ អ៊ីចឹងបានខ្ញុំសួរលោកថា ក្នុងឋានៈលោកជាបក្ខជននោះ លោកធ្លាប់ឮគេនិយាយអំពីគោលនយោបាយហ្នឹងឬក៏អត់? ឥឡូវខ្ញុំសួរជាលក្ខណៈទូទៅ លោកធ្លាប់ឮមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាណាមួយនោះ

បានណែនាំថា ត្រូវផ្សព្វផ្សាយសេចក្តីណែនាំបែបហ្នឹង ទៅថ្នាក់ក្រោមនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទេ?

[០៩:១៥:៤៧]

**ឆ៖** ខ្ញុំអត់ដែលឮថ្នាក់ដឹកនាំខាងលើប្រាប់ឲ្យតាមដានរឿងការរស់នៅអី ផ្សំដំណេកជាមួយគ្នា មិនផ្សំដំណេក គឺអត់ដែលមានទេ។ អានេះបើខាងមូលដ្ឋាន ខ្ញុំក្តាប់មិនបានទេ ខ្ញុំជម្រាបអ៊ីចឹង ព្រោះខ្ញុំខាងអង្គភាពយោធា គឺខ្ញុំគ្រប់គ្រងនិងក្តាប់។ ខាងហ្នឹងគឺអត់មាន ដែលមានបញ្ហាអ៊ីចឹងផង ព្រោះរៀបចំហើយដូចរូបខ្ញុំអ៊ីចឹង រៀបចំក្នុងពេលហ្នឹងដែរ។ ដូច្នេះគឺជាប់រហូត របួតគ្នាទាល់រាល់ថ្ងៃហ្នឹង មានកូនមានជាចៅទៅហើយ។ ដូច្នេះហ្នឹងសម្រាប់អង្គភាព។ ហើយអង្គភាពខ្ញុំ ក៏ធ្លាប់ឃើញអ៊ីចឹងដែរ អ្នកដែលស្គាល់គ្នា ដែលរៀបចំមួយពេលនោះ ក៏ឃើញជួបជុំគ្នាទៅ ខ្លះក៏ព្រាត់ប្រាស ដោយសារស្លាប់ក្នុងពេលសង្គ្រាមយួនបុកនេះ ដោយសារព្រាត់ប្រាសគ្នាអ៊ីចឹង។ ដោយការលែងលះ មិនពេញចិត្ត គឺមិនដែលឃើញមាន។

**ស៖** ចំណុចចុងក្រោយ ដោយសារតែលោកនិយាយអំពីការរៀបការដែលលោកខ្លួនឯងផ្ទាល់បានរៀបចំ។ ក្នុងពេលដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/10713 ដដែល លោកបាននិយាយអំពីករណីមួយចំនួនដែលកើតមាននៅក្នុងការរៀបការ។ លោកថា ពេលខ្លះទៅមានអ្នកខ្លះមកសុំលោករៀបការផ្ទាល់តែម្តង ដោយសារតែពួកគេស្រឡាញ់គ្នាជាមុន ហើយក៏មានករណីអ្នកខ្លះទៀត មកសុំឲ្យលោកហ្នឹងរើសគូឲ្យពួកគេ។ <លោកបានបញ្ជាក់ចំណុចនេះ>នៅក្នុងចម្លើយទី៣៣ ដើម្បីកុំឲ្យបំប្លែងនូវចម្លើយរបស់លោក ខ្ញុំសូមអានឯកសារនេះជាភាសាអង់គ្លេស ចម្លើយទី៣៣៖ “មានពីរករណី មួយគឺកូនកម្លោះ កូនក្រមុំគេយល់ព្រមជាមួយគ្នាជាមុន ហើយស្នើរៀបការ។ ករណីផ្សេងទៀត បើកូនក្រមុំ ឬកូនកំលោះ<ចង់រៀបការ ពួកគេអាច>ស្នើសុំប្រធានឲ្យជួយជ្រើសរើសគូស្រករឲ្យគេ។ នៅពេលនោះយើងណែនាំពួកគេឲ្យស្គាល់គ្នា។” បញ្ចប់ការដកស្រង់។

លោក ជួន ធី ខ្លួនលោកផ្ទាល់នេះ តើលោកបានរៀបការបានប៉ុន្មានគូដែរ? បើសិនជាលោកនៅចាំ សូមលោកជម្រាបជូនអង្គជំនុំជម្រះ បើមិនចាំចំនួនច្បាស់ គ្រាន់តែចំនួនប្រហាក់ប្រហែលក៏បានដែរ ដូចជាមួយ ពីរ ឬក៏ប្រាំ ឬក៏១០គូអ៊ីចឹង។

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះការរៀបចំ ដូចខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង ថាទី១ អ្នកដែលធ្លាប់បានជួបជុំគ្នា អ្នកដែលហ៊ានទោះគឺទាក់ទងអ៊ីចឹងទៅ ត្រូវរូវគ្នាទៅ អាហ្នឹងក៏គេពេញចិត្ត គេប្រាប់ឈ្មោះនេះ

ឈ្មោះនោះអ៊ីចឹងដែលគេពេញចិត្ត។ ហើយមួយផ្នែកទៀត មានអ្នកដែលមិនសូវ ហៅថាក្លាហាន ឬ អៀនខ្មាសច្រើន ក៏គ្នាអត់ហ៊ានទេ ពឹងពាក់លើអ្នកដឹកនាំឲ្យជួយមើល។ ហើយយើងក៏ប្រាប់គេថា ត្រូវការមួយណា អីមួយណា ដើរមើលទៅ បើទៅហើយ គេប្រាប់ទៅ យកឈ្មោះទៅ យើងយករៀបចំឲ្យ។ អាហ្នឹងគឺ បញ្ហាហ្នឹងគឺខាងខ្ញុំគឺមានធ្វើអ៊ីចឹង។ ឯបើសិនជារៀបចំទៅ ពេលដែលរៀបចំ អ្នកដែលគេចាប់ទៅ ចេះតែដាក់ទៅវាច្រឡំ ដែលមិនពេញ សាម៉ីខ្លួនខាងប្រុសក៏ដោយ ខាងស្រីក៏ដោយដែលគេមិនពេញចិត្ត គេអាចដើរចេញមិនរៀបចំបាន។ នេះគឺខ្ញុំមានបញ្ជាក់ប៉ុណ្ណឹង។

[០៩:១៩:៣២]

**ស៖** ចុះនិយាយពីចំនួនគូវិញ ចំនួនការរៀបការនេះ លោកធ្លាប់រៀបការឲ្យគេហ្នឹងបានប៉ុន្មានគូ ប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំរៀបចំឲ្យបងប្អូននៅក្នុងអង្គភាពខ្ញុំបានប្រហែល១៥ ទៅ២០គូដែរតើ។

**ស៖** នៅក្នុងចម្លើយពីមុនៗរបស់លោក លោកថាមានការរៀបការច្រើនគូ។ យើងដឹងហើយនៅក្នុងអង្គជំនុំជម្រះនេះ សាក្សីជាច្រើននិយាយអំពីបញ្ហារៀបការជាច្រើនគូនេះ។ អ៊ីចឹងលោកដឹងទេថា មូលហេតុអីបានជាត្រូវរៀបការម្ដងៗច្រើនគូបែបនេះ? ហេតុអីបានជាគេមិនរៀបការម្ដងតែមួយគូៗ?

**ឆ៖** បញ្ហានេះខ្ញុំអត់យល់ច្បាស់ដែរ។ តែគ្រាន់ថា ពេលវេលាលើក គឺអង្គភាពប្រមូលផ្ដុំគឺគ្មានគេរៀបចំឲ្យ តែហ្នឹងដឹងថាម៉េចទេ គឺខាងលើថាត្រូវរៀបចំយ៉ាងច្រើន តែបើយើងរៀបមួយ រៀបម្ដងមួយគូៗ បើមនុស្សច្រើនជាងនេះមិនដឹងថ្ងៃហ្នឹងនេះទេ។ បើ ខ្ញុំគ្រាន់អ៊ីចឹង ដែលម៉េចទៀតគឺខ្ញុំស្ដាប់មិនបាន។ គ្រាន់តែគេឲ្យរៀបចំទៅ មានប៉ុន្មានគូរៀបទៅ មានកន្លែងមានអី មុននឹងរៀបចំកន្លែងរៀបចំគូឲ្យគេមានកន្លែងសម្រាប់ការរស់នៅជាមួយជីវិតគូផង់គេ គឺមានត្រឹមត្រូវ។ ហើយឯការរៀបចំប៉ុណ្ណោះគូ ប៉ុណ្ណោះគូអី ដែលមាន ដែលបង្ខំ ដែលឮនិយាយអីដូចនេះទេ ខ្ញុំក្លាប់អត់បានដែរ។ តែគ្រាន់តែរៀបមួយគូៗម្ដង ព្រោះវាគ្មានពេលវេលា ព្រោះកាលពេលនោះ គឺថា គេថាគ្មានពេល ដូច្នេះយើងរៀបច្រើនទៅ វាដូចមួយគូ ក៏ដូចច្រើនគូដែរ ហ្នឹងខ្ញុំគ្រាន់បញ្ជាក់ប៉ុណ្ណឹង។

[០៩:២១:២៣]

**ស៖** អ៊ីចឹងខ្ញុំត្រលប់មកសំណួរដើមវិញ លោកថា លោកអត់ដឹងថាមានការរៀបការដោយបង្ខំទេ ក៏ប៉ុន្តែក្នុងចម្លើយពីមុនរបស់លោកហ្នឹង លោកថាលោកមិនដឹងខ្លួនឯងទេ តែមានគេនិយាយប្រាប់ថា មានការឲ្យរៀបការដោយបង្ខំមែន។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា អ្នកណាជាអ្នកនិយាយប្រាប់លោក

អំពីរឿងការរៀបការដោយបង្ខំហ្នឹង?

**ឆ៖** ខ្ញុំសូមបញ្ជាក់ដែលការអ្នកដែលប្រាប់ គឺខ្ញុំភ្លាប់អត់បានទេ ភ្លេចអស់ហើយ តាំងពីជំនាន់ តាំងពីជំនាន់មុនយួនចូល ៗឈ្លានពានស្រុកខ្មែរហ្នឹង។ ដូច្នេះមួយរយៈពេលនោះ គឺអ្នកនុំងក៏ស្លាប់អស់ មិនដឹងទៅណាដែរ អត់ដែរឃើញផង គ្រាន់តែឮគេនិយាយ ថាមានអង្គភាពខ្លះដែលរៀបចំដោយចាប់បង្ខំ ដល់នេះសាមីខ្លួនគេអត់ត្រូវ គេអត់ព្រមយកហ្នឹង គឺខ្ញុំសួរថាគេធ្វើម៉េចដែរ អាហ្នឹងគេទៅកន្លែងគេទៅ អត់មានដឹងគេធ្វើម៉េច អត់មានដឹងផង គ្រាន់តែឮគេថាដែរហ្នឹង។ អាហ្នឹងនិយាយអ៊ីចឹង។ វាមិនច្បាស់ គ្រាន់តែឮគេនិយាយទេ។

**ស៖** នៅក្នុងចម្លើយទី៤៩ នៅក្នុងឯកសារដដែល លោកបាននិយាយថា ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "អ្វីដែលខ្ញុំបានឮ គឺថាមានការបង្ខំឲ្យរៀបការនៅភូមិឃុំស្រុក ហើយនៅពេលដែលខ្ញុំសួរថាបង្ខំឲ្យរៀបការយ៉ាងម៉េច បើគេមិនស្រលាញ់គ្នា។ គេប្រាប់ខ្ញុំវិញថាបន្ទាប់ពីរៀបការរួច គេក៏បំបែកគ្នាទៅ ដោយរស់នៅមិនចុះសម្រុងគ្នា គេក៏បំបែកគ្នា។" បញ្ចប់ការដកស្រង់។ ត្រង់ចំណុចនេះ ខ្ញុំយល់ថាលោកមិនចាំថាអ្នកណាជាអ្នកប្រាប់លោកទេ ក៏ប៉ុន្តែលោកអាចប្រាប់បានទេថា អ្នកប្រាប់លោកហ្នឹងជាស៊ីវិល ឬក៏ជាយោធា? បើលោកមិនចាំឈ្មោះក៏ហើយទៅចុះ ហើយគាត់ប្រាប់លោកហ្នឹងនៅកន្លែងណាដែរ?

[០៩:២៣:៣៥]

**ឆ៖** កាលហ្នឹងគេប្រាប់ខ្ញុំនៅកន្លែង នៅកន្លែងដែលពីបន្ទាយរបស់កន្លែងដែលទាហានខ្ញុំឈរជើងហ្នឹងហើយ គេមកលេង អាហ្នឹងគឺអត់ដឹងថាច្បាស់ទេ។ គេមកជួបហ្នឹងគេនិយាយថា គេរៀបចំមានគូខ្លះគេរៀបចំ ថាច្រឡំគូក៏មិនដឹងៗ ដល់រៀបចំទៅវាខុសគូគ្នា ដូច្នេះគេអត់ព្រម។ ហើយដល់អត់ព្រម គេទៅវិញ។ រីឯអាហ្នឹងរៀបចំនេះ ខ្ញុំនិយាយខាងយោធាខ្ញុំ គឺខ្ញុំនិយាយក្នុងក្របខ័ណ្ឌយោធា។ ឯខាងមូលដ្ឋាន ខាងស៊ីវិលនេះ ខ្ញុំភ្លាប់អត់បានទេ ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង ព្រោះខ្ញុំមិនដែលចូល មិនដែលចូលជ្រៅក្នុងខាងស៊ីវិលហ្នឹងទេ។ ខ្ញុំនិយាយតែអង្គភាព ខ្ញុំយោធាខ្ញុំ ហើយខ្ញុំនិយាយថា ឮគេថានេះក៏មិនច្បាស់ជា ៗនៅកន្លែងណាដែរ ហើយគេក៏អត់ប្រាប់ថាកន្លែងណាដែរ គ្រាន់តែឮគេថាដែរ តៗអ៊ីចឹង ខ្ញុំគ្រាន់តែឮអ៊ីចឹង បានខ្ញុំមកដែលអស់លោកហៅទៅសួរខ្ញុំ ខ្ញុំនិយាយតាមហេតុផលដែលឮ ហើយក៏មិនអាហ្នឹង--។

**ស៖** លោកបាននិយាយអំពីករណីមួយនេះ អ៊ីចឹងលោកធ្លាប់ឮអ្នកណាផ្សេងនិយាយអំពីករណី

01376858



នៃការរៀបការដោយបង្ខំហ្នឹងផ្សេងទៀតទេ ក្រៅពីម្នាក់ហ្នឹងមានអ្នកផ្សេងទៀតប្រាប់លោកទេ?

**ឆ៖** ក្រៅពីម្នាក់ហ្នឹងអត់ទេ អត់មានអ្នកណាដែលនិយាយទៀតទេ។

[០៩:២៤:៥៨]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមបញ្ចប់ហើយ។ យើងបានបែងចែកពេលវេលាគ្នាជាមួយមេធាវី នួន ជា ហើយ។ បើខ្ញុំចាប់ផ្តើមនៅម៉ោងមួយ សាមសិបនាទីនោះ ខ្ញុំត្រូវបញ្ចប់<ក្នុងរយៈពេលប្រាំនាទី ដើម្បីទុកពេលជាងកន្លះម៉ោងបន្តិច ដើម្បីទុកពេលឲ្យក្រុមមេធាវីលោក នួន ជា។ ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ថា យើងយល់ស្របគ្នាពាក់ព័ន្ធនឹងពេលវេលា ដែលថា> យើងបានខាតពេល១៥នាទីដែរ នៅពេលដែលចាប់ផ្តើមដំបូងដោយយើងពិភាក្សាគ្នាទៅលើការអនុវត្តសេចក្តីរបស់សហចៅក្រមស៊ើបអង្កេត។ អ៊ីចឹងតើលោកប្រធានអាចប៉ះប៉ូវពេលម៉ោងប្រាំនាទីហ្នឹងបានទេ? ខ្ញុំឃើញលោកប្រធានឯកភាពហើយ អ៊ីចឹងខ្ញុំបន្តទៅទៀតអ៊ីចឹង។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី ខ្ញុំសូមបញ្ចប់ការសួររបស់លោកដោយលើកនូវចំណុចមួយ ដែលលោកបាននិយាយនៅក្នុងចម្លើយ<ពីរ>របស់លោក <ហើយនិងចម្លើយនៅក្នុងអង្គជំនុំជម្រះនេះផងដែរ>នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២/០១ គឺនិយាយអំពីសេចក្តីប្រកាសរបស់ ប៉ុល ពត ពាក់ព័ន្ធនឹងការរៀបការនៅក្នុងការប្រជុំនៅកំពង់ឆ្នាំង។ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោកនៅក្នុងសំណុំរឿង០០២/០១ ខ្ញុំសូមរកមើលឯកសារសិន។ ខ្ញុំរកមិនឃើញទេ ខ្ញុំអ៊ីចឹងខ្ញុំធ្វើតាមរបៀបផ្សេងវិញ។ ខ្ញុំសួរជាសំណួរបើកវិញ។ ក្រៅពីការប្រជុំនៅស្វាយរៀងនោះ <ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជាទូទៅនៅកំពង់ឆ្នាំង តើ> លោកចាំពាក្យពេចន៍ លោកចាំប្រធានបទដែល ប៉ុល ពត បាននិយាយទេ នៅខែមិថុនា ឆ្នាំ១៩៧៨ហ្នឹង?

**លោក ជួន ធី៖**

**ឆ៖** ខែមិថុនា ខ្ញុំសូមឆ្លើយ ខ្ញុំប្រជុំនៅខែមិថុនាហ្នឹង ខ្ញុំអត់មានដែលប្រជុំផង ខ្ញុំប្រជុំជាមួយ ប៉ុល ពត តែខែ៦ហើយ នៅកំពង់ឆ្នាំទេ។ ហេតុដូច្នេះមកព្រំដែន គឺអត់មានដែលប្រជុំអីទៀត គ្មានដែលប្រជុំអីជួបទៀតទេ អត់មានដែលបានជួបអីទេ ជួបតែម្តងនៅកំពង់ឆ្នាំង។

[០៩:២៧:៣១]

**ស៖** អ៊ីចឹងលោកចាំចំណុចផ្សេងៗដែល ប៉ុល ពត បាននិយាយក្នុងពេលប្រជុំហ្នឹងទេ? បើ

លោកមិនចាំ ខ្ញុំអាចរំឭកការចងចាំរបស់លោកបាន។

**ឆ៖** ប្រជុំនៅកំពង់ឆ្នាំង ខ្ញុំចាំ។ ប៉ុន្តែគ្រាន់តែចូលប្រជុំហ្នឹង ទី១ ពិនិត្យអំពីកិច្ចការពារប្រទេស, ទី២ និយាយពីការកសាង គឺលើកទិសធំពីរហ្នឹង មកនិយាយ មកដោះស្រាយ។ ដូចខ្ញុំបញ្ជាក់អ៊ីចឹង ខ្ញុំចូលធ្វើការបានតែមួយថ្ងៃទេ គឺគ្រាន់តែនេះទេ ដូច្នេះខ្ញុំត្រូវមក យកទ័ពមកព្រំប្រទល់ខាង ផ្នែកខាងកើតនេះ ដូច្នេះខ្ញុំបញ្ជាក់អ៊ីចឹង នេះ។ សូមអស់។

**ស៖** នៅក្នុងឯកសាររបស់លោកគឺ E3/4593 លោកបាននិយាយច្បាស់ជាងនេះ។ លោកបានពន្យល់ ខ្ញុំសូមអានទូវចម្លើយរបស់លោក ដើម្បីកុំអានបំប្លែងសម្ដីរបស់លោក។ លោកថា ដំបូង ប៉ុល ពត និយាយអំពីបញ្ហាស្រូវ ក្នុងការលើកស្ទួយសេដ្ឋកិច្ចកម្ពុជា។ នេះជាអ្វីដែលលោកបានឆ្លើយ។ "ប៉ុល ពត បានសួរទៅមេសហករណ៍ មេឃុំ មេស្រុកដែលមានវត្តមាននៅទីនោះ ថាតើប្រជាជនហូបឆ្អែតដែរឬទេ។ មេសហករណ៍ មេឃុំជាច្រើនបាននិយាយថា ប្រជាជនហូបឆ្អែត ហើយមានតែសហករណ៍មួយចំនួនតូចតែប៉ុណ្ណោះ ដែលហូបមិនឆ្អែតនោះ។ ប៉ុល ពត ក៏បានសួរទៀត ថាចុះស្រូវដែលប្រមូលបាននោះទៅណាអស់? ហើយមេសហករណ៍ គាត់ឆ្លើយទៅវិញថា ផលស្រូវហ្នឹងគឺមិនសូវល្អទេ។ ប៉ុល ពត ក៏បញ្ជាក់ថា ស្រូវ និងអង្ករដែលនៅសល់ពីប្រជាជនហ្នឹង ត្រូវបានយកទៅដូរជាមួយនឹងឧបករណ៍កសិកម្មនៅបរទេស។ ប៉ុល ពត បានពន្យល់ថា ការនាំចូលឧបករណ៍ទាំងអស់ហ្នឹង គឺដូចថា ត្រូវតែធ្វើហើយ ដើម្បីឲ្យជំរុញឲ្យមានឧស្សាហកម្មហ្នឹងជឿនលឿនទៅមុខ។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងតើលោកនឹកឃើញចំណុចនេះឡើងវិញទេ? ហើយពេលដែល ប៉ុល ពត បាននិយាយពាក្យពេចន៍ទាំងអស់ហ្នឹង លោកមានវត្តមានទេ?

[០៩:៣០:១៣]

**ឆ៖** ខ្ញុំបញ្ជាក់លើកមុនជូននេះហ្នឹង ក៏ថា គឺគេនិយាយពីកសិកម្ម ហើយគេថា ដើម្បីកសាងប្រជាជនឲ្យទៅជាកសិ -- សេដ្ឋកិច្ចឲ្យទៅជាកសិកម្មជឿនលឿន ដូច្នេះត្រូវការ ទី១ ត្រូវការកម្លាំងឲ្យប្រជាជនហូបគ្រប់គ្រាន់ អីអ៊ីចឹង គឺគាត់និយាយដែរ និយាយដែរ។ ដូច្នេះខ្ញុំគ្រាន់តែ -- ដូច្នេះលើកឡើងឃើញថាការហូបគ្រប់គ្រាន់ មិនគ្រប់គ្រាន់តាមសហករណ៍អាហ្នឹង គឺកាលនោះខ្ញុំអត់បានបញ្ជាក់អីដល់ថ្នាក់ហ្នឹងទេ។ គ្រាន់ថា ដឹងថាគេហូបបីពេល ឲ្យហូបគ្រប់គ្រាន់។ តែត្រង់ថា សហករណ៍ណាខ្វះខាតអីយ៉ាងម៉េចមិនដឹងទេ។ ដូច្នេះគាត់បញ្ជាក់អ៊ីចឹងថា ដូច្នេះត្រូវធ្វើយ៉ាងម៉េចឲ្យប្រជាជនគ្រប់គ្រាន់ ដីយើងមានច្រើន ស្រូវយើងធ្វើបាន។ ដូច្នេះប្រជាជនកុំឲ្យហូបខ្វះខាត។ អាហ្នឹងគឺខ្ញុំដែល ខ្ញុំឮ ពាក្យសម្ដីហ្នឹង

តែត្រង់ថាយ៉ាងម៉េច អីយ៉ាងម៉េច អាហ្នឹងខ្ញុំដឹងគាត់ថាអ៊ីចឹងហើយ ក៏ខ្ញុំទៅព្រំដែនទៅ។ ខ្ញុំគិតគូរដូចខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង ផ្នែកខ្ញុំយោធា គឺគ្រាន់តែមកស្ដាប់ទេ មិនមែនជាអ្នកការងារអី គឺច្បាស់លាស់ទេ គឺគ្រាន់តែមកស្ដាប់គេប្រជុំ តើខ្លឹមសារយ៉ាងម៉េច ដើម្បីយ៉ាងម៉េចទេ គឺកងទ័ពមានភារកិច្ច គឺការពារព្រំដែន គឺប៉ុណ្ណឹង។ គឺអត់មានការងារអីចូលក្នុងនេះហ្នឹងទេ គ្រាន់តែត្រូវយល់ ត្រូវដឹងខ្លះអំពីកិច្ចការពារការកសាង និងការពារប្រទេស គ្រាន់ត្រូវដឹង ត្រូវយល់ប៉ុណ្ណឹង។

[០៩:៣១:៣៤]

**ស៖** អ៊ីចឹងនៅពេលដែល ប៉ុល ពត សួរគណៈសហករណ៍ទាំងអស់នុ៎ង តើលោកមានវត្តមានទេ? ហើយលោកបានស្ដាប់ឮការសួរឆ្លើយគ្នានុ៎ង ដោយផ្ទាល់ត្រចៀកលោកទេ?

**ឆ៖** ខ្ញុំៗ សូមបញ្ជាក់គឺពេលនុ៎ង គឺខ្ញុំធ្វើការបាន១ថ្ងៃទេ តែខ្ញុំគ្រាន់តែឮគេនិយាយដំបូង ដូច្នេះវាមិនទាន់បានឮឆ្លើយឆ្លងអីស្រួលបួលទេ ព្រោះខ្ញុំគ្រាន់តែនេះ បញ្ជូនចេញ ខ្ញុំចេញមកបាត់មក គឺ១ថ្ងៃធ្វើការនុ៎ង វាមិនទាន់បានច្បាស់លាស់ទេ។ គ្រាន់តែឮខ្លះដែរ ឮខ្លះ គាត់តែចាប់ផ្ដើមរៀបចំផែនការហ្នឹង គ្រាន់តែដូច្នេះខ្ញុំត្រូវចេញមក ព្រោះខ្ញុំខាងយោធាមិនបាននៅជាប់នុ៎ងទេ។ គឺច្បាស់អ៊ីចឹង គ្រាន់ថា ខ្ញុំមិនដឹងទេ គ្រាន់តែច្បាស់ជាមានសួរហើយ ព្រោះឮមិត្ត យឿង អីគេនិយាយថា អូ៎! ខាងលើសួរការហូបចុករបស់ប្រជាជន ហើយកងទ័ពក៏ដឹងដែរថា ប្រជាជនអាចមានបញ្ហាខ្វះហើយ តែស្រូវមួយគរគោកទៅណា? អាហ្នឹងអ៊ីចឹង។ ដល់នេះពេលហ្នឹងសួរ បែបមានក្រែងបញ្ហាហើយ។ គ្រាន់តែនាំគ្នាមកគិតអ៊ីចឹងទេ។ ខ្ញុំគ្រាន់តែបញ្ជាក់ប៉ុណ្ណឹង។

**ស៖** លោកសាក្សីម៉េចបានជាខ្ញុំជជីកសួរត្រង់ចំណុចនេះ ពីព្រោះថានៅពេលដែល ប៉ុល ពត សួរហ្នឹង គឺវាចេញពីចម្លើយរបស់លោក។ លោកបានឆ្លើយហ្នឹង គឺនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ អ៊ីចឹងលោកចាំចម្លើយរបស់លោកនេះទេ? ហើយចម្លើយនៅក្នុងឯកសារហ្នឹង វាត្រូវនឹងអ្វីដែលលោកបានស្ដាប់ឮនៅពេលនុ៎ងទេ ឬក៏មួយលោកភ្លេចអស់ហើយ នឹកមិនឃើញត្រង់ចំណុចហ្នឹងទេ?

[០៩:៣៣:២៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ ថ្ងៃដែលខ្ញុំឆ្លើយក្នុងប្រជុំនុ៎ង មិនមែនថ្ងៃ០២ មីនាទេ ខែមីនាទេ គឺខែ៦ គឺខែ៦ ព្រោះខែ៦ហ្នឹងខ្ញុំចូលបាន១ថ្ងៃ ខ្ញុំត្រឡប់មកព្រំដែនវៀយួននៅព្រំដែននៅស្វាយរៀងនេះ មិនមែនខែមីនាទេ។ ហើយការនិយាយហ្នឹង ក៏ខ្ញុំ ៗគ្រាន់តែបញ្ជាក់ជូនអ្នកដែលទៅសង្កេតការណ៍ ទៅស៊ើបសួរខ្ញុំ ហេតុផលខ្លះដែលក្នុងការប្រជុំហ្នឹង គេនិយាយអ៊ីចឹង គេលើកហេតុផលអ៊ីចឹងមកនិយាយ មកបន្ទោស ហ្នឹងខ្ញុំ

គ្រាន់តែបញ្ជាក់ហេតុផលអ៊ីចឹង។ ហើយខ្ញុំថាដែរ ខ្ញុំមិនបានក្នុងអង្គប្រជុំហ្នឹងចប់ចុងចប់ដើមទេ។

**ស៖** ខ្ញុំសូមបន្តពាក់ព័ន្ធនឹងចម្លើយទី៤ នៅក្នុងឯកសារដដែលហ្នឹង លោកបាននិយាយអំពីសម្ដីផ្សេងទៀតរបស់ ប៉ុល ពត លោកបាននិយាយថា ខ្ញុំសូមដកស្រង់៖ "ប៉ុល ពត ក៏បានបន្ថែមថា យើងត្រូវបង្កើនចំនួនប្រជាជនក្នុងរយៈពេល១០ទៅ២០ឆ្នាំ ឱ្យបានពី២០ទៅ៣០លាននាក់ ដើម្បីការពារប្រទេស។ ក្នុងន័យនេះ ប៉ុល ពត បានបញ្ជាក់ថា គាត់តម្រូវឱ្យមានការរៀបចំ ឱ្យមានការរៀបអាពាហ៍ពិពាហ៍ដើម្បីបង្កើនចំនួនប្រជាជន ដោយឱ្យថ្នាក់ក្រោមបង្គាប់ជាអ្នករៀបចំអាពាហ៍ពិពាហ៍របស់ប្រជាជន។" សូមបញ្ចប់ការដកស្រង់។ លោកនឹកឃើញថា តើ ប៉ុល ពត ពិតជាបាននិយាយអ៊ីចឹងមែនទេ ក្នុងពេលប្រជុំនៅកំពង់ឆ្នាំងនោះ? លោកនឹកឃើញឡើងវិញទេ? ខ្ញុំនឹងសួរសំណួរបន្ថែមទៅទៀត។

**ឆ៖** ខ្ញុំនឹកឃើញ ព្រោះខ្ញុំឆ្លើយយ៉ាងហ្នឹងមែន ហើយ ប៉ុល ពត ក៏បញ្ជាក់អ៊ីចឹងដែរ ឱ្យរៀបចំ។ ឱ្យរៀបចំ ហើយឱ្យកម្មាភិបាលខាងក្រោមហ្នឹង គឺរៀបចំឱ្យមានគូស្រករដូចខ្ញុំបញ្ជាក់អ៊ីចឹង ទៅតាមការពេញ តាមវ័យ តាមនេះគេអ៊ីចឹង គេឱ្យរៀបចំ គេឱ្យរៀបចំ ព្រោះត្រូវការប្រជាជន។ គាត់និយាយថា ទឹកដីយើងនៅធំណាស់ នៅទូលាយណាស់ បើមនុស្សប៉ុណ្ណឹង គឺនៅមិនបានសព្វទេ ដូច្នេះត្រូវតែថែមមនុស្សឱ្យបានច្រើន។ អ៊ីចឹងបានបង្ខំរៀបចំ ឱ្យរៀបចំគូស្រករទៅ។

[០៩:៣៦:០៣]

**ស៖** នៅពេលដែល ប៉ុល ពត និយាយអំពីបញ្ហាបង្កើនចំនួនប្រជាជន និងការរៀបអាពាហ៍-ពិពាហ៍ហ្នឹង គាត់មានបានបញ្ជាក់ទេថា ទោះបីជាសាមីខ្លួនមិនព្រមការក៏ដោយ ក៏ត្រូវតែចាប់ការដែរ។ គាត់មានបាននិយាយអ៊ីចឹងទេ?

**ឆ៖** គាត់អត់មានបាននិយាយអ៊ីចឹងទេ ខ្ញុំអត់ឮគាត់និយាយអ៊ីចឹងផង។

**ស៖** នៅក្នុងឯកសាររបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺថ្មីៗនេះដែរ គឺឯកសារE3/10713 នៅចម្លើយ២៨, ២៩ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។ គឺសូមអាននូវសំណួរដែលគេសួរលោក "សួរ៖ នៅពេលដែលលោកចូលរួមប្រជុំជាមួយនឹង ប៉ុល ពត តើ ប៉ុល ពត មាននិយាយត្រូវធ្វើយ៉ាងម៉េចសម្រាប់ការរៀបការ<>ដែរឬទេ? ចម្លើយរបស់លោក ប៉ុល ពត មិនបាននិយាយអ្វីច្បាស់លាស់ទេ គឺគ្រាន់តែនិយាយឱ្យមានការរៀបការ ដើម្បីបង្កើនចំនួនប្រជាជនតែប៉ុណ្ណោះ។ សួរ៖ កាលនោះ ប៉ុល ពត មាននិយាយថា ត្រូវរើសគូយ៉ាងណាដែរឬទេ? លោកឆ្លើយ៖ ប៉ុល ពត និយាយថា សម្រេចលើសាមីខ្លួន គេជាអ្នកសម្រេច។ បើគេយល់ព្រម រៀបចំឱ្យគេទៅ កុំបង្ខំ

គេ។” បញ្ចប់ការដកស្រង់។

លោក ជួន ធី លោកនឹកឃើញចំណុចឡើងវិញទេ? ហើយលោកពិតជាបានស្ដាប់ឮ ប៉ុល ពត និយាយអ៊ីចឹងមែនទេ ក្នុងពេលប្រជុំនៅកំពង់ឆ្នាំងនោះ?

**ឆ៖** ខ្ញុំឮ។

[០៩:៣៨:២២]

**ស៖** ពាក់ព័ន្ធនឹងបញ្ហាបង្កើនចំនួនប្រជាជននេះ លោកធ្លាប់ស្ដាប់ឮពីមុនមកទេ នៅក្នុងពេលលោកចូលរួមនៅក្នុងវគ្គរៀនសូត្រផ្សេងៗនោះ? ខ្ញុំមិនសំដៅទៅលើការប្រជុំនៅកំពង់ឆ្នាំងទេ ខ្ញុំចង់ដឹងពីពេលដែលលោកប្រជុំរៀនសូត្រផ្សេងៗហ្នឹង លោកមានធ្លាប់ឮគេនិយាយអំពីបញ្ហាបង្កើនចំនួនប្រជាជនហ្នឹងទេ?

**ឆ៖** កាលពីប្រជុំកំពង់ឆ្នាំងនេះ ខ្ញុំមិនដែល អត់មានដែលឮគេនិយាយអីផង ព្រោះថ្នាក់ដឹកនាំក៏មិនគិតពី -- អត់បានឮនិយាយអីផង ពីការបន្ថែមបង្កើនពលអី អត់មានបានគិតគូរចាប់អារម្មណ៍អីទេ។

**ស៖** អ៊ីចឹងក្រៅពីពេលប្រជុំនៅកំពង់ឆ្នាំងហ្នឹង គឺថាលោកមិនដែលបានស្ដាប់ឮគេនិយាយបញ្ហាហ្នឹងទេ។ ចុះបើក្រៅពីបញ្ហារៀបការហ្នឹង លោកធ្លាប់ឮនិយាយអំពីភាពចាំបាច់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺផ្សេងៗ ភាពចាំបាច់ក្នុងការប្រយុទ្ធប្រឆាំង ដើម្បីបង្កើនជីវភាពប្រជាជនទេ ពេលដែលលោកចូលរៀនវគ្គរៀនសូត្រនយោបាយក្នុងក្របខ័ណ្ឌលោកជាបក្ខជននោះ?

**ឆ៖** សូមៗឆ្លើយ សូមសួរម្ដងទៀតមក។

**ស៖** មិនអីទេ ខ្ញុំនឹងសួរឲ្យស្រួលយល់ជាងនេះ។ ខ្ញុំចង់ដឹងថា ក្នុងពេលដែលលោករៀនសូត្រវគ្គនយោបាយ ព្រោះថាលោកជាសមាជិកបក្សកុម្មុយនីស្ដកម្ពុជា ឬក្នុងពេលដែលលោកអានទស្សនាវដ្ដីទង់បដិវត្ត តើលោកធ្លាប់ឃើញឯកសារ ឬក៏ធ្លាប់ឮគេនិយាយថា បក្សកុម្មុយនីស្ដកម្ពុជាមានគោលដៅលើកស្ទួយ ឬបង្កើនជីវភាពប្រជាជនដែរឬទេ? <តើនេះជាអ្វីដែលលោកបានឮគេនិយាយ>ក្នុងចន្លោះឆ្នាំ៧៥ ដល់៧៩នោះ<ដែរទេ>?

[០៩:៤០:២៨]

**ឆ៖** ក្នុងចន្លោះឆ្នាំចិតសិប -- ពេលហ្នឹងគឺខ្ញុំដែលឮ និយាយថាខំធ្វើម៉េចក៏សាងឲ្យប្រទេសយើងមានសេដ្ឋកិច្ចគ្រប់គ្រាន់ ឲ្យប្រជាជនយើងមានជីវភាពធូរធារ មានទឹកមានដី មានបាយអីហូបចុកគ្រប់គ្រាន់ និយាយជីវភាពគ្រប់គ្រាន់។ អាហ្នឹងគឺមានឮនិយាយ។

**ស៖** ចំណុចចុងក្រោយ ព្រោះថាខ្ញុំជិតអស់ពេលហើយ។ តើលោកមានបាត់បង់សាច់ញាតិ ឬក៏សមាជិកគ្រួសារទេ ក្នុងពេលមានជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាមនោះ?

**ឆ៖** ពេលដែលមានជម្លោះជាមួយយួននោះ គឺខ្ញុំមានបាត់ប្អូនខ្ញុំបង្កើតអស់បីនាក់ដែរ។

**ស៖** លោកបាត់ប្អូនបីនាក់ហ្នឹង នៅពេលណាដែរ?

**ឆ៖** ពេលដែលយួនចូលមកឈ្លានពានហ្នឹង វ៉ៃគ្នានៅហ្លួសពីតាំងពីឆ្នាំនេះ មកក្រោយមកទៀតមក គឺតាំង៧៨, ៧៩, ៨០ហ្នឹងមក។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមបញ្ចប់ត្រឹមនេះសិន ទុកឲ្យភាគីគាត់សួរសិន។

**ប្រធានអង្គជំនុំ៖**

តទៅនេះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់។ ជម្រាបសួរលោកសាក្សី។

[០៩:៤២:៥២]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ព្រឹកនេះខ្ញុំនឹងនិយាយអំពីបញ្ហាទាក់ទងទៅនឹងការប្រយុទ្ធគ្នា ដែលបានកើតឡើងនៅស្វាយរៀង។ ប៉ុន្តែដំបូង ខ្ញុំសូមសួរចំណុចមួយចំនួនទាក់ទងទៅនឹងសុន្ទរកថារបស់ ប៉ុល ពត ដែលលោកបានស្តាប់ឮ គឺសុន្ទរកថាអំពីការបង្កើនការរៀបការ ដើម្បីឲ្យមានប្រជាជនច្រើន។ មុនពេលលោកជួបប្រជុំជាមួយ ប៉ុល ពត តើអ្នកដែលគេចង់រៀបការដោយខ្លួនគេផ្ទាល់នោះ គេអនុញ្ញាតឲ្យរៀបការដែរឬទេ?

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា គឺការដែលចង់រៀបការបែបបុគ្គលផ្ទាល់គឺ ពេលនោះគេធ្វើជាអ៊ីចឹងមិនកើតទេ ធ្វើដោយមានការរៀបចំ ទទួលខុសត្រូវពីថ្នាក់ដឹកនាំ។ បើចង់បានគ្រួសារអី រៀបចំគ្រួសារអីត្រូវប្រាប់អ្នកដឹកនាំ ហើយអ្នកដឹកនាំគេរៀបចំឲ្យ។ គឺអត់ទៅ បើការឯកជន ដឹងគេធ្វើតាមវិធីណា

អាហ្នឹងខ្ញុំអត់យល់ដែរ អត់យល់ត្រង់សំណួរហ្នឹងដែរ។ តែបើធ្វើការរៀបចំតាមថ្នាក់ដឹកនាំ គេរៀបចំឲ្យយើង ចង់ស្នើទៅ ម្នាក់ក៏គេរៀបចំឲ្យតែបានដែរ គេមិនមែនចាំតែទាំងអស់ទេ។

**ស៖** តើនេះគិតចាប់តាំងពីថ្ងៃ១៧ មេសា ១៩៧៥ រហូតដល់ ១៩៧៨ មែនទេ?

**ឆ៖** នេះអត់ទេ គឺការៗរៀបចំគ្រួសារនេះគឺ៧៥ អាហ្នឹងគឺអត់ទាន់មានឮសួរនិយាយទេ ទើបដល់ពេលឈ្នះហើយ ៧៦, ៧៧, ៧៦, ៧៧ អាហ្នឹងគឺទើបតែមានការរៀបចំជាគ្រួសារឲ្យ។

[០៩:៤៥:០៦]

**ស៖** ដូច្នេះសក្ខីកម្មរបស់លោកហ្នឹងគឺថានៅក្នុងឆ្នាំ១៩៧៦ទេ។ លោកសាក្សីសូមបញ្ជាក់ឡើងវិញ គឺថា គឺចាប់ពីឆ្នាំ១៩៧៦, ៧៧ ឬក៏ដល់ពាក់កណ្តាលនៃដើមឆ្នាំ១៩៧៨ទេ ទើបគេឲ្យប្រជាជនរៀបការបែបនេះ នេះអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំស្តាប់ឮអ៊ីចឹង។

**ស៖** ឥឡូវខ្ញុំចូលទៅនិយាយអំពីការណែនាំពី ប៉ុល ពត នៅ<ក្នុងកិច្ចប្រជុំ>ខែមិថុនា ១៩៧៨។ ឥឡូវនិយាយអំពីចម្លើយរបស់លោកនៅខែកញ្ញា ឆ្នាំ<២០១៥> គឺE3/10713 ត្រង់ចម្លើយលេខ២១ គឺអ្វីដែលលោកបានស្តាប់ឮពី ប៉ុល ពត ផ្ទាល់។ សូមដកស្រង់៖ “ខ្ញុំចាំឮ ប៉ុល ពត និយាយថា យើងត្រូវការកម្លាំងបន្ថែម ហើយប្រទេសកម្ពុជាគឺនៅមានទឹកដីទូលំទូលាយណាស់ ប៉ុន្តែចំនួនប្រជាជនមានប្រហែលជា៧លាននាក់ទេ។ ប៉ុល ពត បាននិយាយថា គម្រោងក្នុងរយៈពេល១០ ទៅ២០ឆ្នាំខាងមុខ ផែនការហ្នឹងគឺដើម្បីបង្កើតប្រជាជនឲ្យបាន២០ទៅ៣០លាននាក់។ ដូច្នេះចាប់ពីពេលនេះទៅ យើងត្រូវតែបង្កើនឲ្យមានការរៀបការរវាងយុវជន និងយុវនារីដើម្បី<បង្កើន>ប្រជាជន។” បញ្ចប់ការដកស្រង់។

សំណួររបស់ខ្ញុំលោកសាក្សី <បើ>នៅពេលនេះ<>អ្នកដែលចង់រៀបការហ្នឹងគឺគេឲ្យរៀបការ។ <តើធ្វើម៉េចទើបអាច>បង្កើនចំនួនប្រជាពលរដ្ឋឲ្យកើនច្រើនលឿនយ៉ាងនេះ គឺពី<៧>ទៅ<២០>លាននាក់ ដោយបង្កើនចំនួនការរៀបការ ដោយសារថាអ្នកដែលគេចង់រៀបការហ្នឹងបានរៀបការរួចទៅហើយ? អ៊ីចឹងសំណួរខ្ញុំសួរថា <តើលោកត្រូវធ្វើអ្វីដើម្បីបង្កើត>ចំនួនប្រជាពលរដ្ឋឲ្យកើនច្រើនលឿនយ៉ាងនេះ? ហើយនាំឲ្យមានការបង្កើនការរៀបការបែបនេះ?

[០៩:៤៧:៤០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់សំណួរនេះ ពីព្រោះវាជាសំណួរច្រំដែលដែល ទាក់ទងនឹងចម្លើយរបស់សាក្សីបានបញ្ជាក់រួចហើយថា ដោយសារតែផ្ទៃដីរបស់កម្ពុជាមានទូលំទូលាយ ច្រើន ហើយយើងត្រូវការមនុស្សច្រើនទៀតដើម្បីនៅឲ្យសព្វក្នុងដីនៃព្រះរាជណាចក្រ -- នៃប្រទេស កម្ពុជានោះ។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

សំណួររបស់ខ្ញុំ តើគេបង្កើនចំនួនប្រជាជន<ដែលចង់រៀបការ>ឲ្យកើនបានច្រើនបែបនេះដោយ របៀបណា <បើ>អ្នកដែលចង់រៀបការហ្នឹងបានរៀបការរួចរាល់ហើយ?

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះសមស្របនឹងសួរបាន ហើយសាក្សីឆ្លើយតបទៅនឹងសំណួរ។ សូមបដិសេធនូវ សេចក្ដីជំទាស់ មិនមែនជាប្រភេទសំណួរច្រំដែលទេ។

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ អ្នកដែលរៀបចំការហើយ គ្មានអ្នកណាគេ -- អត់រៀបចំការឲ្យទៀតទេ គឺ រៀបចំអ្នកដែលមិនទាន់មានគូ អ្នកថ្មី កម្លោះក្រមុំ ចង់និយាយថាកម្លោះក្រមុំគឺរៀបចំឲ្យ។ តែអ្នកដែល មានគូហើយគឺអត់ទេ គឺគេមានផន់គេហើយ គឺអត់មានរៀបចំ ឲ្យគេយកផន់គ្នាគេទៅ គូស្រករគេទេ។

[០៩:៤៩:២០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ ខ្ញុំយល់ហើយ។ តើគេបង្កើនចំនួនប្រជាជនតាមរយៈការបង្កើនការរៀបការនេះ ដើម្បី ឲ្យបានប្រជាជន<កើនឡើង>ពី<៧ ទៅ>២០<និង>៣០លាន បានដោយរបៀបណា?

**ឆ៖** អ៊ួ!ខ្ញុំឆ្លើយអំមិញរួច។ ខ្ញុំសូមបញ្ជាក់គឺ បើទើបតែរៀបចំគូស្រករ ដូច្នេះត្រូវមានការកូន មានចៅ ដូច្នេះបើអ៊ីចឹង ដូច្នេះវារៀបចំឲ្យច្រើនទៅ គឺបានកូនចៅច្រើន វាមានប្រជាពលរដ្ឋច្រើន អាហ្នឹង គឺអ៊ីចឹង។

**ស៖** យើងនឹងត្រឡប់មកនិយាយអំពីការរៀបការដោយបង្ខំនេះឡើងវិញ គឺនៅរសៀលនេះ តែ ពេលនេះ ខ្ញុំសូមចូលទៅសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងសារតាររបស់លោកក្នុងពេលដែលលោកធ្វើ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាកងទ័ពនោះ។ ខ្ញុំសួរកិច្ចការលោកមួយចំនួននៅពេលដែលលោកធ្វើជាកងទ័ព។ ខ្ញុំសូមសួរលោកអំពីបុគ្គលម្នាក់ដែលបានផ្តល់សក្ខីកម្មពីរដងរួចមកហើយ នៅចំពោះមុខអង្គជំនុំជម្រះយើងនេះ។ នៅក្នុងសក្ខីកម្មមុនរបស់លោក លោកមិនប្រាកដ<អំពីគាត់>នោះទេ ប៉ុន្តែខ្ញុំសូមសួរលោកឲ្យបានលម្អិតបន្តិចទៅចុះ អំពីបុគ្គលរូបនេះ។ សាក្សីរូបនេះ ឈ្មោះ មាស វឿន គាត់ជាមេបញ្ជាការវរសេនាធំលេខ១៦ កងពលលេខ១ ដែលឈរជើងនៅកោះកុង ហើយគាត់បានផ្តល់សក្ខីកម្មថា គាត់គឺជាអនុលេខាកងពលលេខ១ ភូមិភាគ<បស្ចិម>នៅក្រោម តាសឿង។ តើលោកស្គាល់បុគ្គលឈ្មោះ មាស វឿន នេះទេ?

[០៩:៥១:៣១]

**ឆ៖** បុគ្គល មាស វឿន នេះខ្ញុំអត់ស្គាល់ទេ។

**ស៖** លោកសាក្សីនេះ លោកគឺជាមេបញ្ជាការវរសេនា<ធំ>លេខ១៥ គឺថា មានវរសេនា<ធំ>បី<នៅក្នុងកងពលលេខ១។> តើអនុប្រធានរបស់ តាសឿង លោកស្គាល់ដែរទេ ជាអ្នកណា? <តើលោកស្គាល់ប្រធានវរសេនាធំបីផ្សេងទៀតទេ? ហើយតើលោកចាំអ្វីខ្លះ? តើនរណាដែលលោកចាំថា ជាប្រធានវរសេនាធំនៅកោះកុងនោះ>?

**ឆ៖** ខ្ញុំសូមបញ្ជាក់គឺ កាលនោះឃើញតែពេទ្យ សឿង តែឯងទេ គាត់ដើរចុះឡើងហ្នឹង គឺដឹកនាំកងទ័ព គឺមាន តាសឿង ឯអនុប្រធានទៀត ដឹងអ្នកណា អត់មានឃើញផង អត់ស្គាល់ផង អត់មាន។

**ស៖** ឥឡូវខ្ញុំសូមសួរចំណុចមួយ ចម្លើយរបស់ មាស វឿន ជាមួយសហចៅក្រមស៊ើបអង្កេតគឺ ឯកសារ E3/9738 – E3/9738 នៅត្រង់ចម្លើយលេខ១៥ គាត់បាននិយាយអំពីកងទ័ព កងពលលេខ១ ដែលឈរជើងនៅ<តំបន់៣៧>ភូមិភាគបស្ចិម។ "ខ្ញុំដឹងពីកងវរសេនាតូចលេខ១៨០ <នៃតំបន់៣៧> ឈ្មោះ តា<អេវ> មេបញ្ជាការ។ កងវរសេនាតូចនេះ ក្រោយមកក៏បានបញ្ជូនទៅព្រំដែនវៀតណាម។" បញ្ចប់ការដកស្រង់។ តើលោក<នឹកឃើញ>កងវរសេនាតូច លេខ១៨០ នេះទេលោកសាក្សី? <តើនេះជាកងវរសនាតូចរបស់លោកឬ?>

**ឆ៖** កងវរសេនាតូចលេខ៨០នេះ គឺខ្ញុំអត់ស្គាល់ទេ កងវរៈ១៨០ ព្រោះខ្ញុំនៅកងវរសេនាធំលេខ១៥។

**ស៖** នៅក្នុងកងវរសេនាធំលេខ១៥ហ្នឹង តើមានកងវរសេនាតូចឈ្មោះអ្វីខ្លះដែរ?

[០៩:៥៤:១៣]

**ឆ៖** ក្នុងវរសេនាធំលេខ១៥ មាន១២០, ១២១ និង១២២។ មានបីវរសេនាតូចហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំចូលទៅសួរអំពីពេលវេលា ដែលលោកត្រូវបានចាត់តាំងឱ្យនាំកងវរៈរបស់លោកទៅវាយប្រយុទ្ធជាមួយវៀតណាមនៅស្វាយរៀង។ លោកបានឆ្លើយរួចមកហើយថាគឺ ប៉ុល ពត ដែលបញ្ជាឱ្យលោកចេញពីភូមិភាគបស្ចិម ហើយនាំវរៈរបស់លោកហ្នឹងទៅប្រយុទ្ធជាមួយនឹងវៀតណាមនៅខេត្តស្វាយរៀង។ នៅពេលដែលលោកទទួលបញ្ជានេះពី ប៉ុល ពត តើលោកផ្ទាល់ឬក៏ សឿង មេបញ្ជាការរបស់លោក មានបានសួរ ប៉ុល ពត ដែរឬទេ ថា ប៉ុល ពត ហ្នឹងមានសិទ្ធិអំណាចយ៉ាងណាដែរ ដែលបញ្ជាឱ្យលោកហ្នឹងយកកម្លាំងពីបស្ចិមទៅស្វាយរៀង ដើម្បីប្រយុទ្ធជាមួយវៀតណាម?

**ឆ៖** ខ្ញុំដឹងថាស្រេចតែ ប៉ុល ពត ហ្នឹងគាត់ជាអ្នកដឹកនាំ ដូច្នេះគាត់មានសិទ្ធិបញ្ជាឱ្យយកទ័ពទៅខាងណាខាងណីអីហ្នឹង គឺគាត់មានសិទ្ធិ គឺយល់ ប៉ុណ្ណឹងគឺយល់។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាសិទ្ធិអំណាចរបស់ ប៉ុល ពត ហ្នឹងគឺគ្របដណ្តប់ទៅលើទ័ពភូមិភាគផង <ដែលគាត់មានអំណាចបញ្ជាកងទ័ពភូមិភាគ ក៏>ដូចជាខ្លួនលោកផ្ទាល់នេះ<>ឱ្យ<ទៅ> ប្រយុទ្ធ<>?

**ឆ៖** ខ្ញុំសូមបញ្ជាក់គឺមិនដឹងយ៉ាងម៉េច ព្រោះគាត់ជាអ្នកដឹកនាំរួមនៅក្នុងហ្នឹងហើយ ដូច្នេះគាត់មានសិទ្ធិហើយ ដូច្នេះខ្ញុំគ្រាន់ដឹងតែប៉ុណ្ណឹង ដឹងថាគាត់មានសិទ្ធិគ្របបញ្ជាទ័ពឱ្យទៅខាងណាក៏បានស្រេចនឹងគាត់។

**ស៖** សូមអរគុណលោកសាក្សី។ លោកបាននិយាយខ្លះរួចមកហើយម្សិលមិញក្នុងការឆ្លើយតបទៅនឹងមេធាវីការពារក្តី អំពីបុគ្គលម្នាក់ឈ្មោះ ធី ពូសសេ ដែលជាមេបញ្ជាការកងពលថ្មីមួយ ដែលត្រូវបានបង្កើតឡើងនៅឯខេត្តស្វាយរៀងនោះ។ លោកគឺជាអនុមេបញ្ជាររបស់ឈ្មោះ ធី ពូសសេ នេះ តើគាត់មកពីកងពលលេខ១ ភូមិភាគបស្ចិមដែរ ឬក៏គាត់មកពីខាងណាដែរ?

[០៩:៥៧:២៥]

**ឆ៖** ធី ពូសសេ នេះមិនមែនមកពីកងពលទី១ ឬនៅភូមិភាគបស្ចិមទេ មកពីខាងនិរតី។

**ស៖** លោកបាននិយាយថាលោកនាំទាហាន១.០០០នាក់មកពីកងវរសេនាធំរបស់លោក <តើ> ធី ពូសសេ ក៏យកទាហានពីកងពលរបស់គាត់ពីខាងនិរតីដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** មែន។

**ស៖** តើលោកដឹងទេថា គាត់នាំទាហានមកហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** មក អ្ហែអត់! រឿងបញ្ហានេះអត់ច្បាស់ដែរទេ គឺអត់ច្បាស់ថាមានចំនួនប៉ុន្មានមកទេ។ ដូច្នេះ

គ្រាន់ថា រៀបចំថាគ្រាន់តែប្រាប់ថា យកកម្លាំងមកពីខ្លះមកជាមួយ មកធ្វើមេដឹកនាំនៅជាមួយខ្ញុំដែលនេះហ្នឹង រៀបចំកងពលថ្មីហ្នឹង។ តែកម្លាំងគាត់យកមកប៉ុន្មាន អាហ្នឹងគឺអត់ច្បាស់ដែរ។

**ស៖** លោកបានផ្តល់ចម្លើយថា កងពលថ្មីដែលបង្កើតឡើងនោះ គឺកងពលដែលស្ថិតក្រោមមេបញ្ជាការរបស់ ធី ពូសសេ ហើយនិងលោក គឺជាអនុបញ្ជាការនោះ <គឺ>កងពល៣៤០។ <តើមានទាហានណានៅក្នុងកងពល៣៤០>ហ្នឹង មកពី<ឃោធា>ខាង<ភូមិភាគបូព៌ា>ទេ?

**ឆ៖** កងពល៣៤០ហ្នឹង គឺមកពីបស្ចិម គឺខ្ញុំនោះហើយ។ មកពីនិរតីគឺ ធី ពូសសេ ហ្នឹង។

**ស៖** ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់សួរលោកអ៊ីចេះ កងពល៣៤០ថ្មីហ្នឹងគឺ<បញ្ចូលគ្នារវាងកងកម្លាំងរបស់>លោកហើយនិង<កងកម្លាំងរបស់> ធី ពូសសេ <មកពីនិរតី តើវាមានបញ្ចូល>ទាហានដទៃទៀតមកពីខាងបូព៌ាដែរឬទេ?

**ឆ៖** អត់មានទេ គឺមានតែ មកតែ ធី ពូសសេ ហើយនិងខ្ញុំទេ អត់មានខាងបូព៌ា គឺអត់មានទេ។

[១០:០០:១៨]

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកបន្តទៀត អំពីកងពលដទៃទៀតដែលត្រូវបានគេបញ្ជូនទៅស្វាយរៀង ដូចដែលលោកបានបញ្ជាក់ម្សិលមិញ ប្រាប់មេធាវីការពារក្តីអ៊ីចឹងដែរ គឺលោកនិយាយអំពីកងអន្តរាគមន៍ពិសេសមួយ ដែលជាកងអន្តរាគមន៍២២១។ <>លោក<បាន>បញ្ជាក់<នៅក្នុងបទសម្ភាសន៍របស់លោក>ថា<>អ្នកណាជាមេបញ្ជាការកងពល២២១<នោះ។>

ឥឡូវនេះលោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់នូវឯកសារកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ព្រោះខ្ញុំមិនចង់និយាយអំពីឈ្មោះ អំពីបុគ្គលនេះទេ ព្រោះបុគ្គលនេះជាសាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅពេលបន្តខាងមុខ។ ឥឡូវនេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានផ្តល់<កំណត់ហេតុស្តាប់ចម្លើយទៅសាក្សីនេះ គឺ>ឯកសារ E3/419។ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីផ្តល់ឯកសារនេះជូនទៅដល់សាក្សី ដើម្បីឲ្យសាក្សីគាត់អាចបញ្ជាក់អំពីឈ្មោះបុគ្គលម្នាក់នេះបាន។ សូមលោកប្រធាន អនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សូមលោកមើលទៅលើឈ្មោះនៅចុងទំព័រទី១។ ហើយមានប្រវត្តិរូបសង្ខេបរបស់បុគ្គលនេះនៅទំព័រទី២ ប៉ុន្តែខ្ញុំសូមលោកកុំឲ្យអានឈ្មោះបុគ្គលនេះអី គ្រាន់តែលោកបញ្ជាក់ថាតើ

បុគ្គលដែលលោកឃើញហ្នឹង គឺជាមេបញ្ជាការកងអន្តរាគមន៍ពិសេស២២១ ដែលគេបញ្ជូនពីខាងនិរតីទៅស្វាយរៀង មែនឬក៏អត់?

[១០:០២:២៨]

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូម ដូចខ្ញុំបញ្ជាក់ពីម្សិលមិញហើយថា កងពលដែលរៀបចំថ្មី គ្រាន់តែគេប្រាប់លេខ ហើយនិងប្រាប់អីទេ គឺមក មិនមែនមកពីខាងភូមិភាគបស្ចិមទេ។ អ្នកដឹកនាំ ក៏គេរៀបចំមកហ្នឹងដែរ គ្រាន់តែគេប្រកាសថា កងពលនេះអ៊ីចេះ ហើយមានអ្នកដឹកនាំឈ្មោះនេះ ឈ្មោះនោះ។ គ្រាន់តែឮតែប៉ុណ្ណឹងទេ ខ្ញុំជម្រាបអ៊ីចឹង។ ហេតុដូចនេះ អត់មានស្គាល់គេ ហើយក៏អត់ដែលឃើញ ក៏អត់ដែលជួប ក៏អត់ដែលដែរ។ ខ្ញុំបញ្ជាក់ពីម្សិលមិញ បានជម្រាបអស់ហើយ។ តែគ្រាន់តែមានដឹងថា ឮថាឈ្មោះអ៊ីចឹងឈ្មោះហ្នឹង ហៅអីស្អីអ៊ីចឹងមែន តែគ្រាន់តែខ្ញុំមិនដែលឃើញឈ្មោះហ្នឹងទេ គ្រាន់តែឮគេថា គ្រាន់តែឮគេថាទៅ។ ហើយអង្គភាពវានៅដោយឡែកពីគ្នា ហើយគេមកពីខាងនិរតី ខ្ញុំនៅនឹងបស្ចិមហ្នឹង មានកម្លាំងខ្ញុំដែលទៅប៉ុន្មានហ្នឹង គឺនៅទីហ្នឹង អត់មានដែលបានជួបគ្នាទេ។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ ខ្ញុំមិនសួរលោកថា លោកស្គាល់គាត់ពីមុន ឬក៏អត់ទេ ប៉ុន្តែលោកបាននិយាយអំពីបុគ្គលនេះដោយហៅឈ្មោះគាត់ គឺផ្តល់ គឺប្រាប់ឈ្មោះត្រកូលគាត់ គឺជាមេបញ្ជាការកងអន្តរាគមន៍២២១។ ហើយខ្ញុំចង់បញ្ជាក់ឲ្យលោកមើលទៅលើកំណត់ហេតុស្តាប់ចម្លើយដែលខ្ញុំប្រគល់ជូនលោកហ្នឹង ថាតើបុគ្គលនៅក្នុងកំណត់ហេតុស្តាប់ចម្លើយហ្នឹង គឺជាមនុស្សតែមួយ ដូចដែលលោកបានបញ្ជាក់ ដូចដែលគេប្រាប់លោកថា ជាមេបញ្ជាការកងអន្តរាគមន៍ពិសេស<២២១>ហ្នឹងមែន ឬក៏មិនមែន?

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្ថែមថា ត្រង់ឈ្មោះហ្នឹងខ្ញុំឮគេថា ឯប្រវត្តិរូបអី គឺខ្ញុំថា មិនដែលស្គាល់គ្នាទៅហើយ គ្រាន់តែឮគេថាដែរទេ។ ដូច្នេះខ្ញុំមិនអាចសន្មតថា បុគ្គលហ្នឹង ឬក៏មិនហ្នឹង គឺខ្ញុំអត់ទេ គ្រាន់តែឮឈ្មោះគេថាអ៊ីចឹង។ ហើយមិនដែលឃើញ មិនដែលជួបមុខគ្នា។ ហ្នឹងអ៊ីចឹង ខ្ញុំសូមបញ្ជាក់អ៊ីចឹង។ ហេតុដូច្នេះខ្ញុំមិនធានាថា ហ្នឹង ឬមិនហ្នឹង ច្បាស់ និងមិនច្បាស់ ខ្ញុំអត់ធានាទេ។

[១០:០៤:៣៦]

**ស៖** មិនអីទេ ខ្ញុំនឹងសួរអំពីបុគ្គលម្នាក់នេះ នៅពេលក្រោយបន្តិចទៀត។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកបានបញ្ជាក់កាលពីម្សិលមិញហើយ លោកនិយាយអំពីកងពលចំនួនបួន

ដែលជាផ្នែកនៃកងពលរួម ដឹកនាំដោយ វាំង ដែលជាកូនប្រសារ តាម៉ុក – ឈ្មោះ រ៉ែន ដែលជាកូនប្រសា តាម៉ុក។ តើកងពលទាំងអស់ហ្នឹង មកដល់ស្វាយរៀងក្នុងពេលជាមួយគ្នា ឬមួយក៏មានកងពលផ្សេងដែលទៅមុនលោក ឬក៏ទៅក្រោយលោកដែរ?

**ឆ៖** បញ្ហានេះៗ ខ្ញុំក្តាប់អត់បានដែរ ព្រោះខ្ញុំទៅដល់ក៏អត់ទាន់មានឮគេប្រកាសថា មានកងពលណា គ្រាន់តែគេប្រាប់មុខសញ្ញាថា ឥឡូវចូលធ្វើការនៅមុខសញ្ញាត្រង់ណេះ ត្រង់ណោះទៅ។ គ្រាន់ថាកងពលណាមកមុន មកក្រោយអាហ្នឹង គឺអត់ក្តាប់បានដែរ ព្រោះគេអត់មានប្រាប់យើងផង។

**ស៖** ខ្ញុំព្យាយាមបញ្ជាក់ឲ្យច្បាស់អំពីទីតាំងដែលហេតុការណ៍ហ្នឹងកើតឡើង។ លោកបញ្ជាក់កាលពីម្សិលមិញថា នៅពេលដែលលោកទៅដល់ ទាហានរបស់លោកត្រូវបានគេបញ្ជូនទៅប្រយុទ្ធនៅព្រំដែន។ តើតំបន់ណាមួយនៅតាមព្រំដែនហ្នឹង ដែលគេបញ្ជូនទាហានលោកទៅវាយប្រយុទ្ធជាមួយវៀតណាមនោះ?

[១០:០៦:៣៤]

**ឆ៖** កន្លែងដែលខាងខ្ញុំទៅប្រយុទ្ធជាមួយកងទ័ពយួនហ្នឹង គឺចាប់ពីខាងកើតទន្លេវ៉ៃកូហ្នឹង គឺធ្វើត្រង់សេហ្នឹង ទាំងខាងកើតប្រសូត្រហ្នឹង មកទល់គ្នានឹងបាវិត គឺនៅប្រចាំការហ្នឹង នៅត្រៀមហ្នឹង។ កាលណា ហ្នឹងកន្លែង គឺនៅត្រង់នុ៎ង។

**ស៖** នៅពេលដែលលោកនិយាយថា តំបន់បាវិតហ្នឹង គឺសំដៅទៅលើទីប្រជុំជនដែលនៅតាមផ្លូវជាតិលេខ១ ដែលជាតំបន់ព្រំដែនកម្ពុជា-វៀតណាមនុ៎ង មែនទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា បាវិតហ្នឹងហើយ តែគ្រាន់ថា មុខសញ្ញាទៅធ្វើការកន្លែងហ្នឹង ឯដូច្នេះវាកាលនោះ បាវិតហ្នឹងក៏មិនមាន ម្តុំមានប្រជាជន មានអីនៅ គឺអត់មានទេ គឺជាមុខសញ្ញាហ្នឹងធ្វើវាយតាមហ្នឹងទៅ។ ដូច្នេះវាមិនមែនចំតែបាវិតហ្នឹងទទេទេ គឺមានវាយៗគ្នា នេះហ្នឹងទេ ពង្រាយគ្នាធ្វើ។

**ស៖** អ៊ីចឹងបានន័យថា នៅពេលដែលទាហានលោកទៅដល់ វៀតណាមនៅម្ខាងព្រំដែនទៀត ហើយនៅពេលនុ៎ងគឺថាខាងកម្ពុជាប្រជាធិបតេយ្យហ្នឹង នៅគ្រប់គ្រងតំបន់បាវិតហ្នឹងនៅឡើយ តើអ៊ីចឹងមែនទេ?

**ឆ៖** ពេលហ្នឹងគឺយួន គឺដកពីក្រុងស្វាយរៀងមែន ប៉ុន្តែនៅក្នុងទឹកដីយើង ចុងឯព្រំដែនខាងកើតហ្នឹង គឺខាងកើតបាវិតហ្នឹង។ ឈ្មោះបាវិតដែលថាទៅហ្នឹង គឺមិនមែនខ្ញុំអីទៅ ទ័ពទៅនៅនឹងបាវិតទេ គ្រាន់តែថា មុខសញ្ញាម្តុំបាវិតហ្នឹង ឈ្មោះបាវិតហ្នឹង គឺមានទំហំដីវាធំអ៊ីចឹងទៅ។ ដូច្នេះម្តុំបាវិតហ្នឹងមក

ហើយមកខាងកើតហ្នឹងមក ខាងកើតត្រង់ស្វាយរៀង មុំទន្លេវ៉ៃកូមក គឺពង្រាយខាងហ្នឹង។ ដូច្នេះយួនក៏វានៅខាងកើតហ្នឹង វាចូលនៅក្នុងទឹកដីខ្មែរយើងហើយ។ វ៉ៃគ្រាន់តែចេញពីក្រុងស្វាយរៀងទេ ប៉ុន្តែយួនវានៅក្នុងទឹកដីយើងនៅឡើយ។

[១០:០៨:៤៩]

**ស៖** អ៊ីចឹងគឺទាហានរបស់លោកនៅខាងកើត<ខេត្តស្វាយរៀង> ប៉ុន្តែលោកត្រូវទៅក្បែរៗខាងបាវិតហ្នឹង ដើម្បីវាយប្រយុទ្ធជាមួយទាហានវៀតណាមហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** មែន។

**ស៖** តើលោកហើយនិង ធី ពូសសេ ហ្នឹងមានទីតាំង ឬក៏បោះទីតាំងនៅមុំខាង<កើត>ស្វាយរៀងហ្នឹងដែរមែនទេ?

**ឆ៖** ខ្ញុំ និង ធី ពូសសេ បោះទីតាំងនៅនឹងស្វាយរៀងហ្នឹងតែម្តង។

**ស៖** អ៊ីចឹងបានន័យថា ទាហានឈរជើងនៅខាងស្វាយរៀង នៅខាងកើត ហើយលោក ហើយនិង ធី ពូសសេ ហ្នឹងនៅក្នុងទីរួមខេត្ត តើអ៊ីចឹងមែនទេ?

**ឆ៖** ទីតាំង សួរបញ្ជាក់ ទីតាំងអ៊ីចឹងហើយ តែក្នុងនាមមេបញ្ជាការ គឺគ្រាន់តែមានទីតាំង ក៏ប៉ុន្តែដើរចល័តជាមួយទ័ពដែរ នៅតាមខ្សែត្រៀមមុខដែរ។

**ស៖** តើលោកចាំទេថា លោកត្រូវការពារព្រំដែនប៉ុន្មានគីឡូម៉ែត្រដែរ? ឧទាហរណ៍ថាតើគេមានបានបែងចែកថា ព្រំដែនចម្ងាយប៉ុន្មានគីឡូម៉ែត្រដែលត្រូវការពារ ឬក៏បែងចែកថា ពីស្រុកមួយទៅស្រុកមួយប្រវែងប៉ុន្មានស្រុកអី ដែលលោកត្រូវការពារដែរឬអត់ទេ?

**ឆ៖** គេអត់មានកំណត់អ៊ីចឹងទេ គ្រាន់តែថាយើងព្រំដែនយើង ដែលយើងមុខសញ្ញាយើងធ្វើអ៊ីចឹងទៅ គឺបើយើងត្រូវការពារ កុំឲ្យតែយួនចូលមកខ្លាំងពេក ព្រោះដូចខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង ថាយួនវាមានមនុស្សច្រើន កងទ័ពច្រើន ឯយើងមានតិច កងទ័ពក៏មានតិច។ ដូច្នេះធ្វើទៅតាមសកម្មភាព ធ្វើម៉េចកុំឲ្យយួនវាមកបំផ្លិចបំផ្លាញយើងខ្លាំងពេក ហើយទប់ទល់។ ហ្នឹងគ្រាន់តែពិនិត្យអ៊ីចឹង គឺឲ្យថាមានព្រំប្រទល់ប៉ុណ្ណេះត្រង់នោះអី ទល់នេះ ទល់នោះ គឺអត់មានកំណត់ទេ។

[១០:១១:៣៦]

**ស៖** វ៉ែន ដែលជាមេបញ្ជាការកងពលរួមហ្នឹង តើគាត់មានមន្ទីរនៅកន្លែងណាដែរ?

**ឆ៖** ក្តាប់អត់បាន។

**សៈ** ឥឡូវនេះខ្ញុំជួយ អាចជួយលោកដើម្បីឲ្យលោកនឹកឃើញនូវព័ត៌មានខ្លះ។ ខ្ញុំសូមអាននូវចម្លើយរបស់សាក្សីមួយរូបផ្សេងទៀត ដែលជាមេបញ្ជាការកងវរសេនាធំ<នៅក្នុងកងពល><៧០៣> នៅស្វាយរៀងដែរ គឺកំណត់ហេតុស្តាប់ចម្លើយ <E3/361>។ ខ្មែរមានលេខ <00194471>, អង់គ្លេសមានលេខ <00766457>, និងបារាំងមានលេខ 00268889។ សាក្សីរូបនេះបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ការដឹកជញ្ជូនធ្វើឡើងដោយដកពួកគេ ហើយយកពួកគេទៅទីតាំងកងពលរបស់ រ៉ែន នៅព្រលានយន្តហោះខាងលិចស្វាយរៀង។" តើវាអាចធ្វើឲ្យលោកនឹកឃើញដែរទេថា រ៉ែន គឺបោះទីតាំងនៅទីតាំងមួយនៅខាងព្រលានយន្តហោះខាងលិចស្វាយរៀង?

**ឆៈ** ខ្ញុំអត់នឹកឃើញទេ ព្រោះកាលដែល រ៉ែន – តារ៉ែន ហ្នឹងមកជួបជុំ ហៅប្រជុំ គឺមិនមែនមកនេះទេ គឺមកខាងមុខហ្នឹង គឺមកជួបជុំនៅកន្លែងណាមួយហ្នឹង មិនមែនជុំកន្លែងគេនៅទេ គឺកន្លែងផ្សេងត្រូវមកជួបជុំគ្នា ហើយត្រង់ហ្នឹងហើយ ជុំទៅវិញ គឺអត់មានដឹងថាកន្លែងគាត់នៅត្រង់ណាទេ រឿងប្រជុំ។ ឯកង៧០២ហ្នឹង គឺខ្ញុំអត់មានដែលឮស្គាល់ឈ្មោះដែរទេ។

[១០:១៣:៥៣]

**សៈ** ខ្ញុំគិតថាប្រហែលមានបញ្ហាគឺ៧០៣ គឺសាក្សីហ្នឹង គឺជាទាហាននៅក្នុងកងវរសេនាធំ<នៃកងពល>៧០៣។ <ទីតាំងមួយផ្សេងទៀត> ដែល<សាក្សីមួយចំនួនបាន>បញ្ជាក់<គឺ>ក្រោលគោ។ ប្រសិនបើលោកមើលទៅលើទីតាំងក្រោលគោនោះ ប្រសិនបើលោកមើលចម្លើយរបស់មេបញ្ជាការកងពល២២១ និងពេលដែលលោកមើលទៅសំណួរចម្លើយលេខ៨ គាត់បាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ខ្ញុំចូលរួមនៅក្នុងការប្រជុំជាមួយ សុន សេន នៅស្វាយរៀងជាច្រើនដង ជាពិសេសក្រោលគោនៅពេលដែលខ្ញុំត្រូវបានគេបញ្ជូនទៅស្វាយរៀង។" សូមបញ្ចប់ការដកស្រង់។ តើលោកចាំទីតាំងឈ្មោះក្រោលគោនេះទេ? ថាតើលោកអាចប្រាប់បានទេថា ក្រោលគោហ្នឹងនៅម្តុំណា? ហើយអ្នកណាបោះទីតាំងនៅក្រោលគោនោះ?

**ឆៈ** ខ្ញុំសូមបញ្ជាក់ ក្រោលគោនេះគឺខ្ញុំទៅនៅ កាលខ្ញុំដែលនាំទៅ គឺទៅដាក់ទ័ព ខ្ញុំទៅឈរជើងនៅក្រុងស្វាយរៀង។ ក្រោលគោ ខ្ញុំឮឈ្មោះ ប៉ុន្តែខ្ញុំអត់ដែលបានមកទេ អត់ដែលបានមកហ្នឹង ព្រោះខាងក្រោលគោវានៅខាង ទំនងជានៅខាងក្រោយក្រុងស្វាយរៀង។ ដូច្នេះខ្ញុំអត់មានតួនាទីអីមកខាងក្រោយទេ ខ្ញុំនៅខាងមុខ។ ដូច្នេះ នេះសូមបញ្ជាក់។

**សៈ** តើលោក<បាន>ឮ<អ្វីខ្លះអំពីក្រោលគោ?>អ្នកណាដែលគេឈរជើងនៅក្រោលគោនោះ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ថាឈរជើងនៅក្រោលគោ ដឹងអ្នកណា ខ្ញុំក្តាប់អត់បាន។

[១០:១៥:៥៧]

**ស៖** សំណួរមួយទៀត ទាក់ទងទៅនឹងទីតាំងដែលលោកត្រូវបានគេបញ្ជូនទៅនោះ គឺថាតំបន់នៅក្នុងខេត្តស្វាយរៀងដែលកងពលលោក ហើយនិងកងពលដទៃទៀតរបស់ អ៊ែន ហ្នឹងបានទៅនោះ តើមានតំបន់ណាមួយដែលគេហៅថា "ចំពុះទា" ទេ?

**ឆ៖** តំបន់ដែលខ្ញុំហ្នឹងដែលទៅនៅខាងនេះហ្នឹង ដូច្នេះតំបន់ដែលខ្ញុំចូលទៅជ្រៅហ្នឹង ដូច្នេះវានៅក្នុងតំបន់ចំពុះទាហ្នឹងហើយ វាចូលផុតពីខាងកើតស្វាយរៀង មុំខាងកើតផ្លូវលេខ១ហ្នឹង វាតំបន់ហ្នឹងក្នុងតំបន់ចំពុះទា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្រ្តីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៧ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:០៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំបានប្រគល់កំណត់ហេតុស្តាប់ចម្លើយដែលលោកស្គាល់ថាជាមេបញ្ជាការអន្តរាគមន៍ កងវរសេនាធំលេខ២២១ -- កងពលតូចលេខ ២២១។ <ជាការពិត នៅក្នុងបទសម្ភាសន៍ផ្ទាល់របស់គាត់នេះ គាត់ទទួលស្គាល់ថា គាត់ជាមេបញ្ជាការកងពលតូចអន្តរាគមន៍ ២២១។> ខ្ញុំមានសំណួរទូទៅមួយ តើមុខងាររបស់កង<ពល>តូច ឬក៏កងពលអន្តរាគមន៍នេះ<ធ្វើអ្វី?> ព្រោះលោក<បញ្ជាក់>ថាកង<ពល>តូចលេខ២២១ <>កងអន្តរាគមន៍<មានតួនាទីនោះ។ ហើយនៅពេលលោកនិយាយអំពីកងពលមុនរបស់លោកនោះ គឺកងពលលេខ១ នៅភូមិភាគបស្ចិម> នេះនៅក្នុងកិច្ចសម្ភាសន៍របស់លោក E3/4593 <ចម្លើយលេខ១២> លោកថា កងពលលេខ១ ជាកងពលដែលមានវរសេនាធំ១៤, ១៥, ១៦ -- ១៥, ១៦, ១៧ <កងវរសេនាធំកាំភ្លើងធំ និងកងអន្តរាគមន៍> ជាពិសេសពាក់ព័ន្ធទៅនឹងអង្គភាពមួយដែលឈរជើងនៅស្វាយរៀងនោះ។ តើកងពលតូចអន្តរាគមន៍នេះ មានមុខងារធ្វើអ្វីដែរ?

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ ព្រោះកងអន្តរាគមន៍នេះ មិនមែនជារបស់ថ្មើរជើង គឺរបស់ខាងកងពលធំខាង តារ៉ែន នេះគេគ្រប់គ្រង ដូច្នេះវាភារកិច្ចគេ គេចាត់ចែងជួយ ក្រែងលោ មានជួយទៅបន្ថែមបន្ថយកន្លែងណា អាហ្នឹងខ្ញុំមិនដឹងដែរ អាហ្នឹងគឺខ្ញុំអត់ដឹងដែរ គឺគ្រាន់អ៊ីចឹង ភារកិច្ចផងគេ ខាងអន្តរាគមន៍។

[១០:៣៥:៤៤]

**ស៖** សំណួរខ្ញុំជាសំណួរទូទៅទេ។ តើ<កងពលតូច>អន្តរាគមន៍<ខុសពីកងវរសេនាធំផ្សេងទៀតនោះ>របៀបម៉េច? ហើយមានមុខងារខុសពីកងវរសេនាធំដទៃទៀត យ៉ាងដូចម្តេចដែរ?

**ឆ៖** កងអន្តរាគមន៍នេះ ភារកិច្ចរបស់ខ្លួនទី១ គឺនៅរ៉ៃធម្មតា តែបើមានមុខសញ្ញាផ្សេងដែលមានដែលថា ដែលត្រូវយ៉ាប់ ដូច្នេះពួកគេទៅជួយ គាំទ្រ ទៅជួយ។

**ស៖** តើត្រឹមត្រូវទេថា កងពលតូចអន្តរាគមន៍នោះត្រូវបានចាត់ទុកថា ជាកងពលតូចមួយដែលអាចចល័តទៅកាន់ទីតាំងផ្សេងៗ អាស្រ័យទៅតាមសភាពការណ៍នោះ? តើអាចថាអ៊ីចឹងបានទេ?

**ឆ៖** ចាបាន។

**ស៖** លោកបានបញ្ជាក់ថា នៅឯសមរភូមិមុខ នៅពេលដែលលោកទៅដល់នៅឯស្វាយរៀងនោះ គឺលោកទៅដល់នៅឯទីតាំងមួយ គឺនៅតំបន់បារិត។ រវាងពីខែមិថុនា ឆ្នាំ១៩៧៨ ទៅដល់យ៉ាង

ហោចណាស់គឺដើមខែធ្នូ ៧៨ តើវាមានការចល័តទ័ពទៅមុខ ទៅក្រោយ ឬក៏វាមានស្ថានភាពហ្នឹងប្រែប្រួលយ៉ាងដូចម្ដេចដែរ នៅពេលដែលលោកឈរជើងនៅឯស្វាយរៀងរយៈពេល៥ខែនុ៎ង?

**ឆ៖** ក្នុងពេលសភាពដែលខ្ញុំឈរជើងនៅរយៈប៉ុណ្ណឹងខែ ចំនួនពេលវេលាហ្នឹងគឺមានសភាពការណ៍តឹងដែរ ជួនកាលទៅ។ ជួនកាលយួននោះវានាំបុក យករថក្រោះមកបុកយើង ផ្ដោងកាំភ្លើងធំដាក់យើង អាហ្នឹងគឺបាញ់គ្នាតទល់ តមកហ្នឹង ខ្លាំងដែរហ្នឹង គឺសភាពការណ៍ គឺតឹងតែងដែរនៅកន្លែងនៅពេលហ្នឹង។

[១០:៣៨:១៨]

**ស៖** សំណួររបស់ខ្ញុំថា យ៉ាងហោចណាស់ មុនខែធ្នូ ឆ្នាំ១៩៧៨ មុនពេលកងទ័ពវៀតណាមចូលមកដល់ហ្នឹង តើកងទ័ពវៀតណាមរុញច្រានកងរបស់លោកចេញពីព្រំដែនថយមកខាងក្រោយ <ឬក៏ការប្រយុទ្ធគ្នានោះបន្តស្ថិតនៅ>ទីតាំង<ដដែលគឺ>នៅបាវិត<>?

**ឆ៖** មុននឹងយួនចូលមក បុកធ្លាយ ចូលពេញស្រុកខ្មែរហ្នឹង គឺពួកហ្នឹង គឺព្រំដែនវ៉ៃ គឺពួកយើងខ្ញុំ មកថយ មកធ្លាយមកជិត មកដល់ផ្លូវលេខ១ ឬក៏ខ្លះនៅលើផ្លូវលេខ១ ខ្លះនៅក្រោមផ្លូវលេខ១ គឺបុកខ្លាំងមកតាមហ្នឹង ពីកើត និងតាមផ្លូវលេខ១។

**ស៖** មេធាវីការពារក្ដីបានសួរទៅលោកកាលពីម្សិលមិញអំពីជនស៊ីវិល។ ហើយលោកបានឆ្លើយថា លោកមិនបានឃើញថា មានជនស៊ីវិលនៅក្រុងបាវិត ខេត្តស្វាយរៀងនេះទេ។ ហើយមេធាវីការពារក្ដី ខៀវ សំផន ក៏បានអានរបាយការណ៍ដែលចេញពីតំបន់២៣ និង២៤។ ពេលនោះគេហៅថាជាតំបន់ភ្លោះ <>របាយការណ៍ពីខែឧសភា ឆ្នាំ១៩៧៨។ ខ្ញុំសូមអានរបាយការណ៍ចេញពីតំបន់ភ្លោះទាំងពីរនេះ ដែលបានរាយការណ៍ នៅខែឧសភា ៧៨ ស្ដីអំពីជនស៊ីវិលនេះគឺឯកសារ E3/862 – E3/862, ERN ជាភាសាខ្មែរ 00021019, អង់គ្លេស 00185207 ដល់08, បារាំង 00814597។ របាយការណ៍នេះគឺរបាយការណ៍ពីតំបន់២៣ និង២៤ រាយការណ៍ដូចតទៅ៖ “យើងបានដកប្រជាជនពីបួនស្រុក <ឲ្យមក>រស់នៅក្នុងទឹកដីរបស់យើង។ ស្រុកទាំងអស់នោះមាន ស្រុកចន្ទ្រា ស្រុកកំពង់រោទិ៍ ស្រុកសំរោង និងស្រុក<ប្រសូត្រ>។”

ហើយខាងក្រោមមកទៀតនេះ គេនិយាយអំពីជីវភាពរបស់ប្រជាជន។ ERN ជាភាសាខ្មែរ 000 21027, អង់គ្លេស 00185212, បារាំង 00814603 សូមដកស្រង់៖ “ដោយសារប្រជាជននៅ<ប្រសូត្រ> កំពង់រោទិ៍ ចន្ទ្រា និងស្រុកសំរោង ត្រូវត្រលប់ទៅសមរភូមិក្រោយ មូលដ្ឋានក្រោយ អ៊ីចឹង

ពួកគេខ្វះខាតចំណីអាហារបន្លែ សាច់ជ្រូក សាច់ត្រី ឬក៏សាច់ទា។ ដោយសារតែស្រូវអង្ករទាំងអស់ហ្នឹង គឺថាត្រូវបានបំផ្លិចបំផ្លាញ និងលួចយកពីសំណាក់ខ្មាំងជាច្រើនលើកច្រើនសា។" បញ្ចប់ការដកស្រង់។

អ៊ីចឹងប៉ុន្មានខែមុនពេលដែលលោកទៅដល់ហ្នឹង គឺជនស៊ីវិលនៅក្នុងបណ្ដាស្រុកទាំងបួននេះ នៅឯបារិតហ្នឹង គឺប្រជាជនហ្នឹងគេត្រូវបានបញ្ជូនមកមូលដ្ឋានខាងក្រោយ។ តើអ្វីដែលបានរាយការណ៍នេះជួយរំឭកដល់ការចងចាំរបស់លោកទេ? ហើយតើលោកដឹងទេ ថាទីតាំងនៅឯខាងក្រោយដែលគេបញ្ជូនជនស៊ីវិលមកនៅក្នុងខែមិថុនា ៧៨ ហ្នឹងទីតាំងហ្នឹងនៅឯណាដែរ?

[១០:៤២:៤៤]

**ផ៖** ខ្ញុំសូមបញ្ជាក់ ដូចខ្ញុំបានជម្រាបហើយថា ដែលខ្ញុំទៅដល់ស្វាយរៀងហ្នឹង គឺអត់មានឃើញប្រជាជននៅកន្លែងណាអី អត់មានប្រជាជនម្នាក់ ក៏អត់មានផង។ ដូច្នេះ ហើយខ្ញុំក៏អត់ស្គាល់ថាយ៉ាងម៉េចដែរ គឺទៅដល់ គឺដឹងតែគេដាក់នៅមុខ គិតតែរឿងទៅ ឯខាងក្រោយគឺយើងខ្ញុំអត់មានទទួលដឹង អត់មានទទួលស្គាល់ ឮថាប្រជាជនគេនៅកន្លែងណា ហើយជីវភាពរស់នៅ ការហូបចុកខ្វះខាតអី អាហ្នឹងគឺខ្ញុំដឹងពីការគ្រប់គ្រងខាងយោធាហ្នឹង គឺដឹកនាំប្រយុទ្ធ ការយល់នឹងខ្មាំងប៉ុណ្ណឹងទេ ឯខាងក្រោយខ្ញុំក្ដាប់អត់បាន ហើយខ្ញុំក៏អត់ស្គាល់ទៀត។

**ស៖** ហើយលោកក៏ត្រូវបានសួរសំណួរខ្លះៗរួចមកហើយអំពី សុន សេន ខ្ញុំនឹងសួរលោកច្រើនបន្តិចអំពី សុន សេន នៅពេលក្រោយ។ ប៉ុន្តែដោយសារខ្ញុំត្រូវបញ្ចប់សំណួរអំពីការរៀបចំចាត់ចែង និង <>រចនាសម្ព័ន្ធរបស់កងទ័ពនេះ ខ្ញុំសូមអានកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីម្នាក់ជាមួយសហចៅក្រមស៊ើបអង្កេតដែលចេញមកពីសេនាធិការ ដែលធ្វើការជាមួយ សុន សេន ហើយទៅជាមួយ សុន សេន ទៅសមរភូមិមុខនៅឯបូព៌ា នៅឆ្នាំ៧៧។ នេះគឺសាក្សី 2-TCW-942 ឯកសារគឺ E3/426 – E3/426, ERN ជាភាសាខ្មែរ 00357492, អង់គ្លេស 00364071, បារាំង 00403068។ នេះគឺជាអ្វីដែលគាត់បានឆ្លើយ សូមដកស្រង់៖ "ក្រោយមកនៅក្នុងឆ្នាំ១៩៧៧ គណៈមជ្ឈិមបានចាត់តាំងឲ្យ សុន សេន ទៅឈរជើងនៅឯសមរភូមិមុខ នៅពេលដែលកងទ័ពវៀតណាមហ្នឹង វាយប្រយុទ្ធនៅស្វាយរៀង។ ហើយក្រោយមក សុន សេន ឲ្យខ្ញុំទៅធ្វើការនៅកន្លែងវិទ្យុទាក់ទង និងភស្តុភារ នៅមន្ទីរស្វាយរៀងនៅចុងឆ្នាំ១៩៧៧។" បញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកឲ្យបានជាក់លាក់អំពីអង្គភាពវិទ្យុទាក់ទង និងភស្តុភារដែលនៅឯស្វាយរៀង។ តើលោកស្គាល់មន្ទីរនេះទេ? ហើយបើស្គាល់ហ្នឹង លោកដឹងថាមន្ទីរហ្នឹងមានទីតាំងនៅកន្លែងណាដែរ? <តើនរណាធ្វើការនៅទីនោះ?>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៤៥:៥២]

**ឆ៖** ខ្ញុំៗសូមសួរម្ដងទៀត ស្ដាប់អត់បានទេ។

**ស៖** តើលោកដឹងមន្ទីរវិទ្យុទាក់ទង និងភស្តុភារនៅឯស្វាយរៀងនោះ មន្ទីរនេះត្រូវបានគេប្រើប្រាស់ថាជាមន្ទីរវិទ្យុទាក់ទង និងភស្តុភារ នៅពេលដែលលោកទៅដល់ឯស្វាយរៀង លោកស្គាល់មន្ទីរនេះទេ?

**ឆ៖** ខ្ញុំអត់ស្គាល់។

**ស៖** ឥឡូវខ្ញុំសូមសួរលោកលម្អិត អំពីការប្រយុទ្ធគ្នា។ តើលោកអាចជម្រាបជូនតុលាការឲ្យលម្អិតបន្តិចបានទេ អំពីការប្រយុទ្ធគ្នារវាងកងទ័ពរបស់លោក ហើយនិងជាមួយនឹងកងទ័ពវៀតណាម? តើសភាពការណ៍ ស្ថានភាពប្រយុទ្ធគ្នាហ្នឹង វាយ៉ាងដូចម្ដេចដែរ? លោកចាំទេ?

**ឆ៖** ខ្ញុំជម្រាបអត់បានទេ ព្រោះៗអត់សូវចាំច្បាស់ដែរ ព្រោះយូរហើយ វាភ្លេចអស់ហើយ។

**ស៖** ក្នុងរយៈពេលប្រហែល៦ខែ ដែលលោកឈរជើងនៅឯស្វាយរៀង តើកងទ័ពរបស់លោកហ្នឹង បានពើបប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាមហ្នឹង ញឹកញាប់ប៉ុនណាដែរ? តើកងទ័ពរបស់លោកប្រយុទ្ធរៀងរាល់ថ្ងៃ ឬប្រយុទ្ធម្ដងម្កាលទេ?

**ឆ៖** កងទ័ពខ្ញុំ ហើយនិងកងទ័ពយួន នៅជាប់គ្នាគឺប្រយុទ្ធរាល់តែថ្ងៃ ព្រោះនៅទល់មុខគ្នាតែម្ដងគឺប្រយុទ្ធរាល់តែថ្ងៃ។

[១០:៤៨:១៣]

**ស៖** តើកងទ័ព<នៅក្នុងកងពល៣៤០>របស់លោកហ្នឹង <>មានរងរបួស <ឬក៏ស្លាប់>ច្រើន<ទេ? តើលោកអាចប្រាប់បានទេមានអ្នករបួស>ប៉ុន្មាននាក់ដែរទៅ ក្នុងរយៈពេលប្រយុទ្ធគ្នា៦ខែនុ៎ង?

**ឆ៖** ក្នុងៗពេលប្រយុទ្ធគ្នា៦ខែហ្នឹង គឺមានការរបួស និងស្លាប់បន្តិចបន្តួចទេ ព្រោះៗយើងមានត្រង់សេ មានកន្លែងយើងត្រៀមការពារអស់ហើយ ដូច្នេះយើងមិនមែនទៅប្រយុទ្ធទាំងកម្រោលឯណាគឺទៅ វាសុទ្ធតែមានត្រង់សេយើងទៅអីហើយ អស់ហើយ ដូច្នេះអត់សូវមានគ្រោះថ្នាក់ប៉ុន្មានទេ។

**ស៖** អ៊ីចឹងលោកកំពុងតែនិយាយថា នៅពេលដែលការវាយប្រយុទ្ធហ្នឹងចប់ទៅ ហើយនៅពេលកងទ័ពវៀតណាមបុកចូលមកហ្នឹង អ៊ីចឹងកងទ័ពភាគច្រើននៅក្រោមការបញ្ជារបស់លោក គឺថារស់រានមានជីវិតជាធម្មតាទេ អ៊ីចឹងមែនទេ?

**ឆ៖** ក្រោយពេលដែលកងទ័ពយួនបុកឈ្លានពានមក ពេលហ្នឹងគឺបែកខ្ញែកគ្នាអស់ហើយ មិន

ដឹងអ្នកណាស្តាប់ប៉ុន្មាន រស់ប៉ុន្មាន គឺអត់ដឹងដែរ។ ពេលដែលយួនបុកមក គឺម្នាក់ៗរត់យកតែរួចរៀងខ្លួនដែរហ្នឹង គឺក្តាប់អត់បាន ពេលហ្នឹង។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែមុនពេលរត់យករួចខ្លួនហ្នឹង គឺថាកងទ័ព<១.០០០>នាក់ ដែលស្ថិតនៅក្រោមការបញ្ជារបស់លោក ដែលយកពីភូមិភាគបស្ចិមទៅបូព៌ាហ្នឹង តើមានការរងរបួសហ្នឹងតិចតួចទេឬ?

[១០:៥០:១៦]

**ឆ៖** មុននឹងនេះ គឺមានការរបួសតិចតួច ប៉ុន្តែយើងយកមកពេទ្យ មកក្រោយអស់ហើយ ដឹកឡានដឹកអីចេញមកក្រោយអីអស់ហើយ មានអីនៅ មកសមរភូមិក្រោយ មកមន្ទីរពេទ្យគេក្រោយអស់ហើយ។ ហើយកម្លាំងដែលនៅសល់ហ្នឹងក៏យើងដឹងថា បែកខ្ញែក បែកខ្ចាត់ខ្ចាយគ្នាអស់ហើយរត់ ព្រោះអង្កាល់នុំងយន្តៗហោះក៏មាន ថ្មើរជើងក៏មក ដូច្នេះវាបែកខ្ញែកគ្នា មិនដឹងជាទៅខាងណាខាងណីទេ ក្តាប់អត់បាន។

**ស៖** តើមានការប្រយុទ្ធពីសំណាក់យន្តហោះវៀតណាមដែរ នៅកន្លែងដែលលោកឈរជើងហ្នឹង? ហើយបើសិនណាជាមានការបាញ់ផ្លោងពីសំណាក់យន្តហោះនេះ តើលោកដឹងថា <នៅពេល> ណាដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ គឺកាំភ្លើងធំក៏ផ្លោង ហើយឡានហោះបាញ់ ហោះពីលើហ្នឹង គឺបាញ់តាមម្តុំផ្លូវលេខ១ហ្នឹងមកកើតមក ពេលដែលកងទ័ពរត់ខ្ចាត់ខ្ចាយហ្នឹង គឺមានឡានហោះទម្លាក់ គ្រាប់កាំភ្លើងធំបាញ់ផ្លោង ហ្នឹងគឺមកតាមហ្នឹង គឺកងទ័ពរត់បែកខ្ញែកគ្នាពេលហ្នឹង គឺ--។ នេះខ្ញុំសូមបញ្ជាក់អ៊ីចឹង។

**ស៖** តើរយៈពេលប៉ុន្មានដែរ បន្ទាប់ពីលោកបានទៅដល់ស្វាយរៀងជាលើកដំបូង ហើយលោកត្រូវបានប្តូរទីតាំងនុំង?

**ឆ៖** អត់មានប្តូរទៅកន្លែងណាផង។

**ស៖** លោកថា ទ័ពរបស់លោកហ្នឹង គឺថារត់គេចចេញអំពីការទម្លាក់គ្រាប់បែកពីសំណាក់យន្តហោះនេះ អ៊ីចឹង លោកនិយាយថាអ៊ីចឹងមែនទេ?

[១០:៥២:៣៨]

**ឆ៖** ខ្ញុំថា កងទ័ពខ្ញុំរត់ពេលដែលយួនបុកខ្លាំង ចូលខ្លាំងហ្នឹងហើយហ្នឹង គឺកងទ័ព ឡានហោះក៏ទម្លាក់ កាំភ្លើងធំ អាថ្មើរជើងក៏វាបុក អាឡានហោះក៏ទម្លាក់ គ្រាប់ផ្លោងក៏ផ្លោង ដូច្នេះកងទ័ពនៅមិនបាន

ក៏នាំគ្នារត់មកថយក្រោយមក បែកខ្ញែកគ្នាអស់ត្រឹមហ្នឹង។ ការប្រយុទ្ធនោះគឺវាចប់ត្រឹមហ្នឹងហើយ គឺអស់កងទ័ពហ្នឹងបណ្តោយ។ មេក្តាប់កូនអត់បាន កូនក្តាប់មេអត់បាន មិនដឹងរត់ទៅណា ម្នាក់ៗយកតែអាយុរៀងខ្លួន។

**ស៖** សូមសួរបញ្ជាក់ឱ្យបានច្បាស់។ លោកថាការបាញ់ផ្តោងកាំភ្លើងធំនិងការទម្លាក់គ្រាប់បែកពីសំណាក់យន្តហោះហ្នឹង គឺនៅ<ចុង>ឆ្នាំ១៩៧៨ហ្នឹងឯង នៅពេលដែលកងទ័ពរបស់លោកហ្នឹង គឺថាចាញ់រត់ទៅចោលកន្លែងនុ៎ង។ អ៊ីចឹងមែនទេ?

**ឆ៖** មែន។

**ស៖** លោកដឹងទេ ពេលហ្នឹងវៀតណាមប្រើយន្តហោះប្រភេទអីដែរ<ដើម្បីទម្លាក់គ្រាប់បែកនោះ>?

**ឆ៖** ពេលហ្នឹងយន្តហោះ គឺខ្ញុំក៏មិនស្គាល់ម៉ាកដែរ តែគ្រាន់តែឮកអាកាច្រើប សួរម៉ាស៊ីនរ៉ឹងៗលឿនហ្នឹងមកទម្លាក់។

**ស៖** តើកងពលរបស់លោកមានកាំភ្លើងបាញ់យន្តហោះអី ដើម្បីទប់ស្កាត់ការពារការបាញ់ពីសំណាក់យន្តហោះនេះដែរទេ?

**ឆ៖** សម្រាប់អង្គភាពខ្ញុំ គឺអត់មានកាំភ្លើងអីបាញ់ការពារយន្តហោះទេ។ តែក្រែងតែកងទ័ពរបស់ខាងលើ អាហ្នឹងគឺខ្ញុំក្តាប់មិនបាន ព្រោះថាសម្រាប់អង្គភាពខ្ញុំ មានតែសម្រាប់បាញ់ថ្មើរជើងហ្នឹងទេ អត់មានសម្រាប់បាញ់យន្តហោះទេ។

[១០:៥៤:៥៧]

**ស៖** ម្សិលមិញលោកបាននិយាយអំពីប្រធានបទមួយ គឺការប្រើប្រាស់គ្រាប់មីន។ បើខ្ញុំយល់មិនច្រឡំទេ គ្រាប់មីនហ្នឹងត្រូវបានគេដាក់បង្កប់ដើម្បីទប់ស្កាត់ខ្មាំងវៀតណាមហ្នឹង។ តើគ្រាប់មីនទាំងអស់ហ្នឹង គេបង្កប់វានៅកន្លែងណាដែរ?

**ឆ៖** នេះពេលៗដែលយួនបុកធ្លាយហើយ ដូច្នេះពេលនោះគឺគ្មានបានបង្កប់មីនបង្កប់អី គឺរត់ចោលអីវ៉ាន់ទាំងអស់ គឺអត់មាននេះទេ អត់មានបានដាក់មីនអី តែកាំភ្លើងយកមិនទាំងទាន់ផង ព្រោះវាមកច្រើនមកហើយ នៅទប់មិនបាន អត់មានបានដាក់មីនដាក់អីទេ។

**ស៖** ខ្ញុំមិនសួរអំពីបំណាច់ឆ្នាំ៧៨ ពេលវៀតណាមបុកមកនោះទេ។ ខ្ញុំសួរពេលដែលលោកទៅដល់ជាលើកដំបូងនៅខែឧសភា ៧៨ តើគេមានប្រើប្រាស់មីនដាក់នៅតាមព្រំដែនទេ នៅពេលដែល

លោកទៅដល់ជាលើកដំបូងនោះ?

**ធ៖** ពេលខ្ញុំទៅដល់ជាដំបូង អត់ទាន់ អត់មានដាក់មីនតាមព្រំដែនទេ ព្រោះកងទ័ពចុះឡើងខ្លាចច្រឡំដែរ អត់ហ៊ានដាក់ទេ អត់ទាន់មានដាក់ទេ។

**ស៖** ចុះចម្រូងវិញ តើលោកមានប្រើប្រាស់ចម្រូងដើម្បីដាក់បង្កើវាការពារដែរទេ នៅឯទីតាំងបារិតនោះ?

[១០:៥៧:១៤]

**ធ៖** ចំពោះចម្រូងនៅទីតាំងបារិត អត់មានដាក់ទេ ដាក់នៅតាមព្រំដែន ជម្រូងបិតឫស្សីហ្នឹងធ្វើដោតទៅ គ្រាន់តែនេះទៅ មានដោតចម្រូងនេះហ្នឹង ឯក្រុងបារិត អត់មានដាក់ទេ ព្រោះឯនុំង ខាងក្រោយនោះគឺចល័តទ័ព ចល័តដើរចុះឡើង ម៉េចនឹងហ៊ានដាក់ ខ្លាចមុតដែរ។

**ស៖** ទាក់ទងទៅនឹងចម្រូងនេះ ខ្ញុំអានសម្រង់មួយ ខែឧសភា ៧៨ របាយការណ៍មួយគឺរបាយ-ការណ៍មកពីតំបន់២៣។ នេះគឺឯកសារ E3/862, ERN ជាភាសាខ្មែរ 00021020, អង់គ្លេស 00185208, បារាំង 00814598។ នេះជាផ្នែកទី១នៃរបាយការណ៍ កម្មវត្ថុ ខ្មាំងផ្ទៃក្រៅនៅក្នុងតំបន់<២៣>។ សូមដកស្រង់៖ “យើងបានជំរុញប្រជាជនឲ្យជួយធ្វើចម្រូង១.៦៣៥.៣៨០ចម្រូង ដើម្បីទៅដាក់នៅឯសមរភូមិ។” ខ្ញុំសូមអានតួលេខនេះឡើងវិញគឺ ១.៦៣៥.៣៨០ចម្រូង។ នេះគឺជារបាយការណ៍នៅសម័យកាលនោះ។ អ៊ីចឹងគឺគេឲ្យជំរុញទឹកចិត្តប្រជាជនឲ្យជួយធ្វើចម្រូងនេះ។ តើចម្រូងទាំងអស់ហ្នឹងសុំលោករៀបរាប់បន្តិចមើល វាមានរាងរៅយ៉ាងដូចម្តេចដែរ? ហើយចម្រូងហ្នឹងគេដាក់បង្កើវា បង្កប់វា<នៅកន្លែង>ណាដែរ<នៅតាមព្រំដែននោះ? តើចម្ងាយប៉ុន្មានពីព្រំដែន>?

**ធ៖** ចម្រូង សូមបញ្ជាក់ គឺចម្រូងដែលធ្វើពីឫស្សី ប្រវែងប្រហែលជាពាក់តឹកអីហ្នឹងទេ ដូច្នេះបិតស្រួច បិតឲ្យស្រួច ឲ្យរាងកន្ទុយអន្ទង់។ ហ្នឹងគឺដើរដោតតាមកន្លែងណាដែលយើងផុតខ្សែត្រៀមយើងហើយ គ្រាន់ដាក់នេះប៉ុណ្ណឹង អ៊ីចឹង។ ឯពួកខ្ញុំនេះមិនមានអីដាក់ ព្រោះនៅកណ្តាល អង្គភាពនៅកណ្តាលគេ មិនមានអីនឹងដាក់ចម្រូងអីផងទេ គឺដាក់ទៅខ្លាចទ័ពចល័តទៅមុត។ តែគេយកទៅដាក់កន្លែងដែលទំនេរ ដែលទ័ព មិនមានទ័ពទៅដល់។

[១១:០០:២៦]

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកបន្ថែម អំពីឯកសាររបស់គណៈអចិន្ត្រៃយ៍ គឺជាឯកសាររបស់ថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៅទីក្រុងភ្នំពេញ។ គឺជាកំណត់ហេតុកិច្ចប្រជុំ ខែ<សីហា> ៧៥ ដែលគេ

និយាយអំពីការធ្វើដំណើរទៅពាយ័ព្យ គឺឯកសារ E3/216 <តំបន់ 2.1.B.2>គឺជានៅផ្នែកនៃកិច្ចប្រជុំ នៅរបាយការណ៍កិច្ចប្រជុំនោះ គឺនិយាយអំពីការបញ្ជារបស់ខាងគណៈអចិន្ត្រៃយ៍ឲ្យរៀបចម្រូងនៅតាម ព្រំដែន<នៅពាយ័ព្យ> ហើយជាការបញ្ជាដែលបានចេញ <សូមដកស្រង់៖> “គឺថា គឺត្រូវប្រើប្រាស់ ទាំងអាវុធទំនើប និងអាវុធបុរាណ ជាពិសេសគឺការរៀបចំចម្រូងនៅតាមព្រំដែន។ ចម្រូងគ្រប់ប្រភេទ ត្រូវបានប្រើប្រាស់ គឺត្រូវប្រើចម្រូង<ត្រឹមបាទ>ជើង <ខ្នងជើង ឡើងទៅដល់ត្រឹម>ពោះ។” ដូច្នេះ តើ <>ចម្រូងបែបនេះ ដូចដែលរៀបរាប់ហ្នឹង<ត្រូវបានគេដាក់នៅតាមព្រំដែន>នៅខេត្តស្វាយរៀងដែរទេ?

**ឆ៖** សូមបញ្ជាក់ចំពោះនៅខាងស្វាយរៀង អត់មានដែលចម្រូងដូចគេប្រាប់ថា ជីករណ្ដៅអី ដាក់ឲ្យមុតជ្រៅ មុតទ្រូង មុតអី អត់មានទេ មានដាក់ចម្រូងជើង ចម្រូងមុតជើងប្រហែលជាពាក់កហ្នឹង មុតខាង ដាក់ខ្លះ។ តែឲ្យមានចម្រូងមុតជ្រៅគឺអត់មានទេ អត់មានចម្រូងវែង មុតជម្រៅដល់ខ្លួនមនុស្ស អត់មានទេ។

**ស៖** តើមានទាហានវៀតណាមច្រើនទេ ដែលរងរបួសដោយសារចម្រូងទាំងអស់នោះ?

**ឆ៖** ក្លាប់អត់បានដែរ។ គ្រាន់វាមានមក វាក្លាប់អត់បានទេ បើមក គ្រាន់តែឃើញទៅបាញ់ទៅ វាអត់មក ដូច្នេះត្រង់មុត មិនមុត អាហ្នឹងគឺក្លាប់អត់បាន។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកបន្ថែមអំពីការវាយប្រយុទ្ធចូលទៅវៀតណាម។ តើលោកហើយ និងកងពលរបស់លោក ឬមួយក៏កងពលដទៃទៀតដែលស្ថិតក្រោមការបញ្ជារបស់ វ៉ែន ចូលរួមនៅក្នុង ការវាយប្រយុទ្ធណាមួយនៅក្នុងទឹកដីវៀតណាមដែរឬទេ?

[១១:០៣:២៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់ អង្គភាពខ្ញុំនៅទល់មុខ គឺអត់មានបានវ៉ៃចូលក្នុងទឹកដីយួនទេ គឺវ៉ៃតែនៅ ការពារតែព្រំដែនរបស់ផងខ្លួន ទឹកដីរបស់ផងខ្លួន គឺអត់មានទៅណាទេ នៅទល់នៅនឹង។

**ស៖** ឥឡូវនេះ ខ្ញុំចង់លើកអំពីភស្តុតាងមួយចំនួនដែលហាក់ដូចជាបង្ហាញថា អ្វីដែលកើតឡើងគឺ ផ្សេងពីនេះ គឺមានបញ្ហាមួយចំនួនដែលខ្ញុំនឹងសួរលោក។ ជាដំបូងខ្ញុំសូមចាប់ផ្ដើមលើកអំពីការសម្លាស--

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ទោះបីថាមិនទាន់មានសួរសំណួរ ប៉ុន្តែព្រះរាជអាជ្ញាបានលើកនូវប្រធានបទនេះ ហើយ ហើយយើងដឹងទាំងអស់គ្នានៅក្នុងអង្គជំនុំជម្រះហើយថា ការវ៉ៃលុកចូលទៅក្នុងទឹកដីវៀតណាម ដោយកងកម្លាំងបដិវត្តន៍កម្ពុជា គឺវានៅក្រៅវិសាលភាពនៃសវនាការនេះ។ ដូច្នេះការសួរសំណួរអំពីអ្វី

01376882



ដែលកើតឡើងនៅក្នុងទឹកដីវៀតណាម គឺថាសំណួរទាំងអស់ដែលទាក់ទងនឹងបញ្ហានេះគួរតែត្រូវបានហាមឃាត់ដោយអង្គជំនុំជម្រះ ព្រោះវា<>មិនអាចនាំទៅដល់អ្វីមួយ<ទេ។ ខ្ញុំយល់ពីការសម្រេចទាក់ទងនឹង>សំណួរ<ដែលបានសួរអ្នកជំនាញកាលពីសប្ដាហ៍មុន> ព្រោះការឈ្លានពានហ្នឹង គឺវាប៉ះពាល់ទៅដល់គោលនយោបាយការបរទេសជាមួយវៀតណាម។ <ប៉ុន្តែការសួរសំណួរត្រង់ៗ -- ហើយនេះជាបញ្ហាតែមួយគត់ដែលសាក្សីនេះអាចឆ្លើយបាន -- ដែលអាចនាំទៅរកស្ថានការណ៍ពាក់ព័ន្ធនឹងបញ្ហាខាងក្រៅ -- ជាពិសេស>គឺនៅក្រៅវិសាលភាព។

[១១:០៥:៣៣]

**កញ្ញា អង់តា ហ្គីសសេះ**

ដើម្បីបន្ថែមលើការជំទាស់របស់លោក កូប៉េ <ខ្ញុំពិតជាយល់ស្របជាមួយគាត់។> ខ្ញុំកត់សម្គាល់ថា ចម្លើយមុន ហើយនិងចម្លើយមុនទៀតហ្នឹង គាត់និយាយថា គាត់ជាអ្នកទទួលបន្ទុកអង្គភាពគាត់ ហើយអង្គភាពគាត់មិនបាន<ចូល>ទៅវៀតណាមទេ។ អ៊ីចឹងមានហេតុផលអីដែលចោទសំណួរគាត់ទៅលើអ្វីដែលគាត់មិនដឹង។ អ៊ីចឹងសួរគាត់ទៅលើអ្វីដែលគាត់ដឹងទៅ បានហើយ។ ហើយវានៅក្រៅពីវិសាលភាពនៃសំណុំរឿងយើងនេះផង។ អ៊ីចឹង ខ្ញុំសូមជំទាស់ត្រង់ការសួរបែបនេះ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតប <វាមិនត្រឹមត្រូវទេក្នុងការនិយាយថា វានៅក្រៅវិសាលភាពនោះ។> ព្រោះថាការឈ្លានពានចូលទៅក្នុវៀតណាម គឺជាឧក្រិដ្ឋកម្ម ប៉ុន្តែទោះបីថា វាមិនមាននៅក្នុងវិសាលភាព ប៉ុន្តែវាគឺជាផ្នែកមួយនៃការចោទប្រកាន់ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ។ ហើយប្រសិនបើយើងមើលទៅក្នុងដីកាដំណោះស្រាយ ហើយយើងមើលនៅក្នុងកថាខណ្ឌទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធនានា ដែលយើងទទួលយក គឺកថាខណ្ឌ១៥៣នៃដីកាដំណោះស្រាយ ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ គឺរួមបញ្ចូលការឈ្លានពានរបស់កងទ័ពបដិវត្តកម្ពុជាចូលទៅក្នុងទឹកដីវៀតណាម។ ដូច្នេះប្រាកដណាស់ថា ភស្តុតាងនេះ គឺវាអាចទាក់ទងទៅនឹងជម្លោះ។ ហើយខ្ញុំសូមឆ្លើយតបថា មេធាវីការពារក៏បានលើកឡើងជាញឹកញាប់ផងដែរ អំពីថាតើអ្នកណាជាអ្នកបង្ករឿងនៅក្នុងជម្លោះប្រដាប់អាវុធមួយនេះ។

[១១:០៧:១៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់សហមេធាវីការពារក្ដីទាំងពីរក្រុម ដោយសារកន្លងមក យើងបានសម្រេចឱ្យអាចសួរបាន ព្រោះមានទំនាក់ទំនងគ្នា រវាងពាក្យថាជម្លោះប្រដាប់អាវុធតាមព្រំដែននេះ គឺវាមានទៅ មានមក។ ពិតហើយយើងមិនឱ្យភាគីសួរដេញដោលអំពីជម្លោះដែលកើតមានឡើងនៅទឹកដីវៀតណាមលម្អិតទេ គ្រាន់តែសួរពីភាពពាក់ព័ន្ធគ្នា ដើម្បីរំលេចអំពីភាពពាក់ព័ន្ធគ្នា រវាងជម្លោះតែប៉ុណ្ណោះ។ ហើយចំណែកឯសំណួរមួយទៀតហ្នឹង ដែលមួយទៀត គឺថាសាក្សីមិនទាន់ឆ្លើយទេ រឿងដឹង មិនដឹង ព្រោះអាការដឹង មិនមែនចាំបាច់ទៅដល់ បានដឹងទេ។ អាការដឹង វាព័ត៌មានផ្សេងៗ ព្រោះយើងសួរកន្លងមក គ្រាន់តែឮគេថា ក៏សួរដែរ រួមទាំងមេធាវីការពារក្ដីទាំងសងខាងផង។ សូមអញ្ជើញបន្តសំណួរ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំសូមចាប់ផ្ដើមសួរ ដោយលើកនូវចម្លើយរបស់សាក្សីមួយ ដែលជាទាហានមួយរូបដែលត្រូវបានគេបញ្ជូនទៅវាយប្រយុទ្ធគ្នាជាមួយវៀតណាមនៅខាងបូព៌ា <ឈ្មោះ គង់ គីម>។ គឺជាកំណត់ហេតុស្ដាប់ចម្លើយជាមួយខាងមជ្ឈមណ្ឌលឯកសារកម្ពុជា<គឺឯកសារ E3/3960> ខ្មែរមានលេខ 00054862 ដល់63, អង់គ្លេសមានលេខ 00633897 ដល់<98>, បារាំងមានលេខ 00403373 ដល់74។ <នេះគឺអ្វីដែលបុគ្គលនេះបាននិយាយ៖ “សំណួរ៖> គឺថានៅពេលដែលលោកវាយប្រហារ ហើយចូលទៅដល់តៃនិញតើមានវាអ្វីកើតឡើងចំពោះប្រជាជននៅទីនោះ?” នេះគឺជាឯកសារលេខE3/3960 ដូច្នេះខ្ញុំចង់សួរលោកថា តើតៃនិញគឺជាខេត្តមួយនៅក្នុងប្រទេសវៀតណាមដែលជាប់ទល់មុខជាមួយនឹងព្រំដែនកម្ពុជា មកខាងស្រុកបាវិតហ្នឹង មែនទេ?

[១១:០៩:៣៧]

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំអត់ស្គាល់ច្បាស់រឿងខេត្តតៃនិញទេ ហើយកម្លាំងខ្ញុំ គឺអត់មានបានចូលទៅវៃដល់ស្រុកយួន ស្រុកអីទេ គឺមានបញ្ហាអី គឺខ្ញុំក្ដោបអត់បាន ព្រោះខ្ញុំអត់បានទៅប្រព្រឹត្ត ទៅធ្វើនៅនុ៎ង កន្លែងនុ៎ង។

**ស៖** សាក្សីរូបនេះ គឺជាកងទ័ព ហើយគាត់រៀបរាប់អំពីការចូលទៅដល់តៃនិញ ហើយគាត់បានរៀបរាប់អំពីវាយប្រហារតាមភូមិ។ ខ្ញុំមិនអានលម្អិតទេ ប៉ុន្តែខ្ញុំសូមរំលងទៅដល់ផ្នែកដែលខ្ញុំចាប់

អារម្មណ៍មួយ។ "សំណួរ៖ តើមេបញ្ជាការកងពលបានចេញបញ្ជាបែបនេះមែនទេ? ឆ្លើយ៖ បាទ គឺមេបញ្ជាការបានចេញបញ្ជាដល់មេបញ្ជាការបន្ទាប់ៗ។ សំណួរ៖ តើមេបញ្ជាការកងពលលោកឈ្មោះអ្វីដែរ ដែលបញ្ជាឲ្យលោកទៅវ៉ៃវៀតណាមនោះ? ចម្លើយ៖ គឺ ផន។ សំណួរ៖ តើ ផន មកពីខាងណាដែរ? ឆ្លើយ៖ គាត់មកពីខាង ខេត្តតាកែវ។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់សួរលោកថា នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាមួយ ក.ស.ច.ស របស់លោក គឺលោកនិយាយអំពីកង<ពលតូច ឬកងពល>ដែលស្ថិតក្រោមបញ្ជារបស់ រ៉ែន។ ថាតើកងពល<មួយ ក្នុងចំណោមកងពល>ទាំងបួន គឺមានកងពល៤៦០ ហ្នឹង តើកងពល៤៦០ហ្នឹងស្ថិតនៅក្រោមបញ្ជារបស់ ផន ដែលមកពីខាងនិរតីមែនទេ?

**ផ៖** ឈ្មោះ ផន ហ្នឹងមកពីនិរតី។

[១១:១១:៣២]

**ស៖** តើកងពលរបស់គាត់ គឺកងពល៤៦០ហ្នឹងស្ថិតនៅក្រោមកងពលរួមដែលដឹកនាំដោយ រ៉ែន ហ្នឹងតើមែនទេ?

**ផ៖** មែន។

**ស៖** សាក្សីម្នាក់ទៀត ឈ្មោះ <ឡាយ អ៊ាន> គឺជាកំណត់ហេតុ E3/376 ខ្មែរមានលេខ 00270173 <ដល់>74, អង់គ្លេសមានលេខ 00278690 ដល់91 និងបារាំងមានលេខ 00486094។ គាត់និយាយថា៖ "ប្រហែលជា៧ខែ មុនថ្ងៃ០៧ មករា ៧៩ គេបញ្ជាឲ្យខ្ញុំរៀបចំអតីតយុទ្ធជនដើម្បីវាយប្រហារជាមួយវៀតណាម។ ប្រធានក្រុមទាំងអស់ ក៏ដូចជាប្រធានកងពលធំ និងកងវរសេនាធំ គឺសុទ្ធតែជាកម្មាភិបាល មកពីនិរតី។ យើងទៅប្រយុទ្ធនៅតាមផ្លូវទៅក្រែក ក្នុងខេត្តកំពង់ចាម និងឆ្លងកាត់បន្ទាយវៀតណាម លេខ<៤២៧> ចូលទៅក្នុងខេត្តតៃនិញ។ ក្រុមខ្ញុំដែលជាអ្នកវាយប្រហារហ្នឹង មានប្រហែលជា២០០នាក់។ <ស៊ន> គឺជាប្រធានកងវរសេនាធំ, ញ៉ គឺជាប្រធានកងពលតូច២០៧ ហើយតា<ពិន> គឺជាប្រធានកងពលធំ។ ក្រុមរបស់ខ្ញុំ <បានវាយចូលប្រហែល១៥ ទៅ២០គីឡូម៉ែត្រតាមបញ្ជា។ ការប្រយុទ្ធនោះបន្ត>ប្រហែលជា៣ខែ ហើយយើងទទួលបញ្ជាពី តា<ស៊ន> ឲ្យ<ដុត>កម្ទេចអ្វីៗទាំងអស់។ ហើយគាត់មិនបាននិយាយអំពីគោលការណ៍ ឬក៏វិន័យសង្គ្រាមអ្វីឡើយ។ ក្នុងពេលដែលយើងវាយប្រហារនៅក្នុងវៀតណាម ក្រុមខ្ញុំហើយនិងខ្ញុំបានគប់គ្រាប់បែក ដុតផ្ទះ ដុតពេទ្យយោធា<>។" គាត់បាននិយាយ<បន្តទៀត។ សំណួរខ្ញុំសម្រាប់លោកនៅពេលនេះ គឺគាត់បានបញ្ជាក់ឈ្មោះ>កងពលតូចមួយមកពីខាងនិរតី<បញ្ជាដោយ>ឈ្មោះ ញ៉ គឺតាញ៉។ តើលោកធ្លាប់ឮឈ្មោះកងពលតូចដែល

ដឹកនាំដោយ តាញ៉ ដែរទេ?

**ឆ៖** កងពលតូចដឹកនាំដោយ តាញ៉ ខ្ញុំអត់ដែលឮឈ្មោះផង។ ខ្ញុំអត់ដែលឮឈ្មោះ ញ៉ ហ្នឹង។

[១១:១៤:៤៤]

**ស៖** ឥឡូវនេះខ្ញុំនឹងលើកហេតុការណ៍ជាក់លាក់មួយដែលរាយការណ៍ដោយភ្នាក់ងារវៀតណាម គឺ <វី>.អិន.អេ នៅខែតុលា ៧៨។ គឺជារបាយការណ៍ដែលរៀបរាប់ថា កងពលរបស់លោក គឺកងពល ៣៤០ ហើយនិងកងអន្តរាគមន៍ពិសេស២២១ បានចូលរួមនៅក្នុងការវាយប្រហារចូលទៅក្នុងខែ ទៅក្នុងតំបន់ប៉ិនខារ នៅក្នុងខេត្តតៃនិញ គឺឯកសារ E3/3 -- គឺ E3/1608។ ខ្មែរមានលេខ 00810114 ដល់ 15, អង់គ្លេសមានលេខ S00013179 ដល់180, បារាំងមានលេខ 00793493 ដល់94។ របាយ-ការណ៍ វី.អិន.អេ ហ្នឹងគឺរបាយការណ៍នៅ<ថ្ងៃទី១២> ខែតុលា ៧៨ បានបញ្ជាក់ថា "នៅថ្ងៃ០១ តុលា--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

អញ្ជើញមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ជាថ្មីម្តងទៀត ចំពោះការតាំងសំណួរនេះ។ គាត់លើកឡើងថាគឺជាកងពល៣៤០ <ហើយ>គាត់<បានផ្តល់ចម្លើយដែលសាក្សីបាន>និយាយថា ក្នុងការរៀបចំការប្រយុទ្ធហ្នឹងគាត់មិនមានទាក់ទងទៅនឹងកងពលផ្សេង កងពលតូចផ្សេងទៀតទេ។ ឥឡូវនេះគាត់និយាយអំពីប្រយុទ្ធនេះដែលគាត់និយាយថា ដោយសារសាក្សីនេះគាត់និយាយថា គាត់មិន<បានដឹកនាំ ឬក៏ចូលរួមពាក់ព័ន្ធ>នោះទេ អ៊ីចឹងទិន្នន័យនេះវាខុសបាត់ទៅហើយ ការសន្មតជាមុននេះ សម្មតិ-កម្មនេះវាខុសទៅហើយ ដល់អ៊ីចឹងសំណួរដែលសួរចេញទៅ ចម្លើយចេញក៏ខុសដែរ។ <ព្រោះថា សាក្សីនឹងមិនអាចបំភ្លឺលើបញ្ហានេះបានទេ។ គាត់បានឆ្លើយពីបញ្ហានេះរួចហើយនៅក្នុងចម្លើយខាងដើមរបស់គាត់។> អ៊ីចឹងខ្ញុំជំទាស់ លោកប្រធានត្រង់ចំណុចនេះ។

[១១:១៧:១៦]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមបន្ថែមបន្តទៅទៀត។ សំណុំរឿង០០២/០២ គឺជាសំណុំរឿងធំ យើងការពារ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កូនក្ដីរបស់ខ្ញុំ ដោយផ្អែកលើការសន្មតថា មិនមានការពិភាក្សាអំពីការឈ្លានពានចូលទៅក្នុងទឹកដីវៀត-ណាម<ទេ ដូច្នេះយើងមិនបានត្រៀមខ្លួនឡើយ>។ យើងមិនដឹងថា កម្មាភិបាលដែលទើបតែអានមកហ្នឹង គឺមានសក្ខីកម្មអាចជឿទុកចិត្ត ឬក៏អត់ទេ ឬក៏វាមានភស្តុតាងអ្វីឬក៏អត់ ព្រោះយើងមិនបានធ្វើការសិក្សាស្រាវជ្រាវទៅលើរបាយការណ៍របស់វៀតណាម ព្រោះយើងគិតថា យើងមិនត្រូវធ្វើការសិក្សាអំពីចំណុចទាំងអស់នេះ។ ប៉ុន្តែឥឡូវនេះវាធ្វើឱ្យយើងមានការលំបាកមួយ ដោយថាហេតុអ្វីក៏លើកយករបាយការណ៍បែបនេះ ឬក៏កំណត់ត្រាបែបនេះ ព្រោះថាមេធាវីការពារក្ដីត្រូវដឹង ថាតើសវនាការហ្នឹងធ្វើអំពីអ្វី វាមិនអាចថាយើងគ្រាន់តែនិយាយថាយើងនិយាយស្អីក៏បានតាមចិត្តនោះទេ ព្រោះថាមេធាវីការពារក្ដីគេត្រូវតែមានស្ថានភាពមួយដែលអាចត្រៀមការពារខ្លួនបានយ៉ាងល្អ។ ហេតុដូច្នេះខ្ញុំគិតថា នៅពេលដែលលើកយកភស្តុតាងអង្គហេតុគឺចាំបាច់ ណាស់ដែលត្រូវឱ្យយើងច្បាស់ថា យើងមិនពិភាក្សាអំពីការឈ្លានពានចូលទៅក្នុងទឹកដីវៀតណាមនោះទេ។ ដូច្នេះខ្ញុំសូមដល់អង្គជំនុំជម្រះមេត្តាហាមឃាត់ចំពោះសំណួរបែបនេះ។

[១១:១៨:៥១]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំគិតថា វាជារឿងគួរឱ្យកត់សម្គាល់មួយ ដែលថាលោកមេធាវី កូប៉េ ឡើងម្ដងហើយម្ដងទៀត ម្ដងហើយម្ដងទៀត ដែលថាគាត់និយាយថា វៀតណាមគឺជាអ្នកចាប់ផ្ដើមបង្ករឿង ប៉ុន្តែឥឡូវហ្នឹងបែរជាគាត់និយាយទៅវិញថា គាត់មិនបានត្រៀមអំពីបញ្ហានេះ <ដែលផ្ទុយពីអ្វីដែលគាត់បានលើកឡើង។ ខ្ញុំអាចនិយាយបានថា រឿងនេះមិនសមហេតុផលទេ>។ ខ្ញុំសូមបញ្ជាក់ថាប្រាកដណាស់ថា វាគឺជាការនិយាយអំពីជម្លោះប្រដាប់អាវុធដែលទាក់ទងទៅនឹងសាក្សីរូបនេះ។ ហើយកងពលរបស់គាត់ គឺមានបញ្ជាក់ច្បាស់នៅក្នុងរបាយការណ៍តែម្ដង គឺជារបាយការណ៍ដែលខ្ញុំគ្រោងនឹងលើកយកមកអាននេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីទាំងពីរក្រុម ចំពោះសំណួរនេះ ហើយមានភាពពាក់ព័ន្ធអំពីជម្លោះប្រដាប់អាវុធ វាមានទំនាក់ទំនងគ្នា។ យើងបានបញ្ជាក់ហើយថា ពិតមែនតែវាមិនសួរដេញដោលស៊ីជម្រៅទៅលើអង្គហេតុលម្អិត លើអង្គហេតុនៅក្រៅវិសាលភាព ប៉ុន្តែពាក្យជម្លោះប្រដាប់អាវុធ ពាក្យឈ្លោះនេះ បានន័យថាវាមានទៅ វាមានមក។ អ៊ីចឹងហើយបានយើងវា

ចង់ដឹង ថាតើវាមានភាពពាក់ព័ន្ធគ្នាយ៉ាងដូចម្ដេចខ្លះ អំពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនេះ បានវាកើតឡើងជាជម្លោះឡើង។

ហើយសាក្សី អាចៗឆ្លើយបាន ព្រោះមេធាវីដូចយើងបានប្រាប់អ៊ីចឹង យើងបានរំឭកហើយថា សួររបហួតដល់គាត់ដឹងឮពីណាមក ក៏គាត់សួរដែរ មិនមែនសួរសាក្សីបានឃើញផ្ទាល់ ដឹងផ្ទាល់ បានសួរបានទេ។ ហើយអំមិញគាត់បានឆ្លើយហើយ អំពីកងពលផ្សេងៗទៀត គាត់បានដឹង។ អ៊ីចឹងពាក្យថា ដឹងនេះ គឺមានន័យទូលំទូលាយជាងអ្វីដែលបានឃើញផ្ទាល់នឹងភ្នែក បានមកសួរដេញដោល។

សូមអញ្ជើញបន្ត លោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:២០:៤៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នេះគឺជារបាយការណ៍មួយ ពាក់ព័ន្ធទៅនឹងបញ្ហានៅខែតុលា ៧៨។ ខ្ញុំសូមអាន៖ "នៅថ្ងៃ ០១ តុលា កងទ័ព ប៉ុល ពត, អៀង សារី នៅក្នុងកងពលធំ២២១ គឺកងពល២២១ បានធ្វើការវាយប្រហារជាទ្រង់ទ្រាយធំ ក្នុងគោលដៅដើម្បីគ្រប់គ្រងទឹកដីនៅក្នុងបរិវេណរបស់ប្រទេសវៀតណាម គឺនៅខាងលិចប៊ិនខាវ ក្នុងស្រុកតៃនិញ។ កងវរសេនាធំរបស់កម្ពុជាមួយ បានទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ គឺទាហានជាងមួយរយនាក់ ត្រូវបានសម្លាប់នៅក្នុងសមរភូមិ។ ចំណែកអ្នកដទៃទៀត ត្រូវបានចាប់ខ្លួន<រួមជាមួយនឹងអាវុធជាច្រើន>។ នៅថ្ងៃតែមួយហ្នឹង គឺថាកងកម្លាំងវៀតណាមបានបោសសម្អាតកងពលរបស់កម្ពុជា គឺកងពលលេខ៣៤០ ដែលមានចម្ងាយប្រហែលជា៣គីឡូម៉ែត្រពីខាងលិចប៊ិនខាវ<ទៅខាងអាគ្នេយ៍> ហើយសម្លាប់ និងចាប់អ្នកឈ្លានពានប្រហែលជា២៥០នាក់ និងដណ្ដើមបានអាវុធ៧៨<ដើម>។"

លោកសាក្សី ថាតើវាអាចធ្វើឱ្យលោកនឹកឃើញដែរឬទេថា មានហេតុការណ៍មួយដែលថាទាហានមួយចំនួនមកពីកងពលធំ៣៤០របស់លោក និងទាហានមួយចំនួនមកពីកងពល២២១ ជាកងពលអន្តរាគមន៍ បានធ្វើការវាយប្រហារចូលទៅក្នុងតំបន់ដែលគ្រប់គ្រងដោយវៀតណាមនៅក្នុងតំបន់ខាងប៊ិនខាវខាងលិច<នៅក្នុងទឹកដីវៀតណាម>?

[១១:២២:៤៦]

**លោក ជួន ធី៖**

**ធ៖** ខ្ញុំៗសូមបញ្ជាក់ហើយ ក៏សូមបញ្ជាក់ថែមទៀតថា ចំពោះខ្ញុំ គឺអង្គភាពខ្ញុំដែលគេថា ទៅចូលទៅវាតដីវៀតណាមអីណា គឺខ្ញុំអត់ទេ គឺខ្ញុំវែនៅនេះហ្នឹង ខាងលិចហ្នឹង អត់មានបានចូលទៅទឹកដីយួនអីណាទេ តែវៃតែតែនិញ គឺខ្ញុំទប់នៅម្តុំប្រសូត្រ ម្តុំអីហ្នឹងទេ គឺខ្ញុំអត់មានបានរៀបចំកម្លាំងទៅទេ អត់ដឹង។ ឯកងពលផ្សេង ដូចខ្ញុំបញ្ជាក់អ៊ីចឹងថា គ្រាន់តែឮឈ្មោះ ប៉ុន្តែមិនដែលស្គាល់ ហើយក៏មិនដែលឃើញ ព្រោះខាងលើ ខ្ញុំជួបប្រាប់ថា ឥឡូវមកប្រយុទ្ធនៅមានកងពលនេះ កងពលនោះមកថែម នៅកន្លែងហ្នឹងដែរ តែគ្រាន់គេថា តែយើងមិនដែលជួបមុខផង ហើយក៏មិនដែលស្គាល់គេទៀត។ ហ្នឹងខ្ញុំសូមបញ្ជាក់អ៊ីចឹង។ មិនមែនថា គ្រាន់តែឮឈ្មោះហើយថាហ្នឹង វាច្បាស់លាស់ជាងឃើញជាក់ស្តែង គឺអត់ទេ ខ្ញុំត្រង់ហ្នឹង ក៏ខ្ញុំអត់ទាន់ ខ្ញុំឆ្លើយអត់កើតដែរ។

**ស៖** លោកសាក្សី លោកបានបញ្ជាក់ច្រើនដងដែរ នៅក្នុងការសម្ភាស ហើយក៏ដូចជាម្សិលមិញ គឺថាកងពលដែលដឹកនាំដោយ ធី ពូសសេ ដែលលោកជាអនុប្រធានកងពលហ្នឹង គឺកងពល៣៤០។ ឥឡូវនេះខ្ញុំសួរអ៊ីចេះវិញ ថាតើមានទាហានណាមួយនៅក្នុងកងពលរបស់លោក គឺកងពល៣៤០ធ្លាប់ត្រូវបានទាហានវៀតណាមចាប់ខ្លួនទេ?

**ធ៖** ពេលនោះខ្ញុំក្តាប់អត់បានដែរ អត់ ព្រោះការប្រយុទ្ធវាមិនដឹងគេចាប់បានយើង យើងចាប់បានគេ អាហ្នឹងគឺខ្ញុំក្តាប់អត់បាន។

[១១:២៤:៣៣]

**ស៖** ឥឡូវនេះខ្ញុំសួរលោកអ៊ីចេះវិញ។ របាយការណ៍ពីភ្នាក់ងារសារព័ត៌មានវៀតណាម បានបញ្ជាក់ច្បាស់អំពី<លេខកងពលទាំងពីរ គឺ>កងពល៣៤០ និងកងពលអន្តរាគមន៍២២១។ ដូច្នេះខ្ញុំចង់សួរថា តើលេខកងពលរបស់លោកហ្នឹង <>ត្រូវបានគេដឹងជាទូទៅ គេទទួលស្គាល់ជាសាធារណៈ ឬមួយក៏ថា លេខកងពលរបស់លោកហ្នឹង<គេដឹងបានដោយសារវៀតណាមចាប់ទាហានកងពលរបស់លោកបាន? តើលោកអាចប្រាប់បានទេ លេខកងពលលោកហ្នឹងគេដឹងជាទូទៅ ឬក៏ព័ត៌មាននេះដឹងតែក្នុង>ជួរទាហាននោះទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គិសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមជំទាស់ជាថ្មីម្តងទៀត លោកប្រធាន ទៅនឹងរបៀបនៃការសួរសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។ គាត់និយាយអំពីកងពល៣៤០ ក៏ប៉ុន្តែច្បាស់ណាស់ សាក្សីបាននិយាយនៅក្នុងចម្លើយមុនៗរួចហើយ ជាពិសេសនៅពេលដែលគាត់ឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ ពាក់ព័ន្ធទៅនឹងការរៀបចំផែនការនៅសមរភូមិនោះ គាត់ថា កងពលតូចរបស់គាត់ហ្នឹងឈរជើងនៅកន្លែងជាក់លាក់មួយតែម្តង ហើយគាត់មិនដឹងពីហេតុការណ៍ដែលកើតឡើងនៅក្នុងកងពលផ្សេងទៀតទេ ដូចជាកងពលអន្តរាគមន៍នេះ ជាដើមនេះ។ អ៊ីចឹងឥឡូវ សហព្រះរាជអាជ្ញាបានយកចម្លើយរបស់គាត់មកតទល់ជាមួយនឹងកងពលអន្តរាគមន៍មួយដែលគាត់មិនស្គាល់ ហើយគាត់មិនបានដឹកនាំទេ ហើយគាត់ក៏មិនបានទាក់ទងអីជាមួយនឹងកងពលហ្នឹងដែរ។ អ៊ីចឹងការធ្វើអ៊ីចឹងគឺមិនត្រឹមត្រូវទេ។ គាត់បានផ្តល់សេចក្តីពន្យល់រួចទៅហើយ ពាក់ព័ន្ធនឹងការរៀបចំការងាររបស់គាត់ នៅក្នុងកងពលតូចរបស់គាត់ ហើយនិងរបៀបនៃការគាត់ការពារព្រំដែន។ ឥឡូវសហព្រះរាជអាជ្ញាអន្តរជាតិរងហ្នឹង យកព័ត៌មានមកតទល់ជាមួយគាត់ហ្នឹង នូវអ្វីដែលគាត់មិនបានដឹងទេ។ អ៊ីចឹងវាមិនត្រឹមត្រូវទៅនឹងអ្វីដែលយើងត្រូវធ្វើក្នុងការសួរដេញដោលសាក្សីទេ។ ដូច្នេះខ្ញុំសូមជំទាស់ដាច់អហង្ការទៅសំណួរនេះ។

[១១:២៧:០៣]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន បន្ថែមទៅលើនេះទៀត គឺថានេះជាការឃោសនារបស់វៀតណាម។ ដូច្នេះហេតុអ្វីក៏យើងឱ្យតម្លៃខ្ពស់ វាគ្រាន់តែជាការឃោសនារបស់វៀតណាមតែប៉ុណ្ណោះ។ <ហើយសហព្រះរាជអាជ្ញាមិនបានបញ្ជាក់ឱ្យច្បាស់ទេ។ ហេតុអ្វីបានជា>យើងគួរតែជឿទៅលើមេ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីមិនមែនជាពេលដែលលោកវាយតម្លៃនោះទេ។ <វាជាពេលសួរសាក្សី។>

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាឥឡូវហ្នឹងសហព្រះរាជអាជ្ញាគាត់កំពុងតែធ្វើការផ្ទុញជាមួយនឹងសក្ខីកម្មរបស់សាក្សី ហើយយើងមិនដឹង--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ហើយលោកនឹងអាច -->

01376890



**លោក វ៉ិចទ័រ កូប៉េ៖**

<អាចសន្និដ្ឋានបាន -->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកនៅមានពេល។>

**លោក វ៉ិចទ័រ កូប៉េ៖**

<-- ជាការឃោសនារបស់វៀតណាម។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកនឹងអាចលើកបញ្ហានេះបាន។>

[១១:២៧:៣៩]

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើសុំឲ្យមានគម្លាតនៅក្នុងការជជែកគ្នា។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវនេះខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ ដើម្បីឲ្យច្បាស់អំពីកងពល៣៤០របស់លោក។ <> របាយការណ៍ហ្នឹង បានបញ្ជាក់ច្បាស់<>អំពីកងពល៣៤០<របស់កម្ពុជាប្រជាធិបតេយ្យ។> ថាតើលេខកងពលរបស់លោកហ្នឹងត្រូវបានគេផ្សព្វផ្សាយ ឬក៏គេប្រកាសជាសាធារណៈ ឬមួយក៏វាជាលេខសម្ងាត់ដែលដឹងតែក្នុងកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ?

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់លេខកងពល៣៤០នេះ គឺទើបតែដែលទៅកើត ទៅបង្កើតដែលដាក់ឈ្មោះហ្នឹង នៅឆ្នាំ៧៨ហ្នឹង ដែលទៅវៃនៅយួនហ្នឹងទេ ទើបបង្កើតហ្នឹងទេ។ ដូច្នេះត្រង់ថា មិនបានដូចជាផ្សាយដឹង មិនដឹងជាទូទៅ អាហ្នឹងគឺមិនដឹង គ្រាន់ថាមករៀបចំកងពល៣៤០ហ្នឹង ដែលមានខ្ញុំ ហើយ ធី ពូសសេ ហ្នឹងដឹកនាំហ្នឹង គឺគ្រាន់តែប្រកាសតែប៉ុណ្ណឹង។

[១១:២៨:៤៧]

**ស៖** ខ្ញុំចង់សួរលោក ថាតើលោកមានប្រកាសជាសាធារណៈអំពីលេខកងពលរបស់លោក ឬមួយក៏វាជាព័ត៌មានសម្ងាត់ដែលដឹងតែក្នុងចំណោមកងទ័ពទេ?

**ឆ៖** លេខនេះគឺដឹងតែក្នុងកងទ័ពទេ ព្រោះប្រយុទ្ធនៅឆ្នាំ៧៨ និងប្រយុទ្ធជិតចាញ់យួនហ្នឹង

ហើយ គឺរៀបចំកម្លាំងឈ្មោះលេខកងហ្នឹង ឈ្មោះកងហ្នឹង លេខហ្នឹង គឺ៧៨ ដែលជិតៗ យួនបុកធ្លាយហ្នឹងទេ គឺអត់មានបានប្រកាសទៅពីខាងណាខាងណីទៀត អាហ្នឹងគឺខ្ញុំពីដើមគ្រាន់ឮ បានដឹងតែប៉ុណ្ណឹងក្នុងចំណោមអង្គភាពដែលរស់នៅជុំវិញហ្នឹង ប៉ុណ្ណឹង។

**ស៖** ឥឡូវនេះខ្ញុំនឹងបន្តទៅប្រធានបទថ្មីមួយទៀត ទាក់ទងបញ្ហាថាតើកងពលរបស់លោកមានបានចាប់ខ្លួនទាហានវៀតណាមដែរឬក៏អត់ ក្នុងរយៈពេល៦ខែ ដែលលោកនៅស្វាយរៀងនេះ។ ដូច្នេះថាតើលោកមានចាប់ខ្លួនទាហានវៀតណាមទេ? ហើយប្រសិនបើចាប់ តើចាប់ខ្លួនទាហានវៀតណាមប្រហែលជាប៉ុន្មាននាក់ដែរ នៅក្នុងពេលវាយប្រយុទ្ធប្រហែលជា៦ខែនោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ក្នុងពេលប្រយុទ្ធជាមួយយួន៦ខែនេះគឺ អត់មានបានចាប់យួនអីមួយ ម្នាក់ក៏អត់។ តែគ្រាន់តែបានមកបាញ់គ្នាទៅវិញទៅមកហ្នឹង អាហ្នឹងគឺប៉ុណ្ណឹង តែឲ្យចាប់រស់បានគឺអត់មាន។

**ស៖** តើលោកអាចពន្យល់បានទេ ហេតុអ្វីបានជាក្នុងរយៈពេលដល់ទៅ៦ខែ លោកមិនបានចាប់ខ្លួន សូម្បីតែទាហានម្នាក់បែបនេះ?

**ឆ៖** សូមបញ្ជាក់ចាប់ម៉េចបាន បើគេមានកាំភ្លើង គេបាញ់គ្នាដែរ ដែលគេនៅគេក៏ប្រយ័ត្នដែរ យើងប្រយ័ត្នទៅចូលចាប់គេម៉េចបាន បាញ់គឺយើងវ៉ៃគ្រាន់តែការពារកុំឲ្យតែយួនចូលរុកមកក្នុងទឹកដីយើងជ្រៅហ្នឹង គឺទប់ គ្រាន់តែទប់តើ មានៗលទ្ធភាពណាទៅចាប់រស់ខ្មាំងបានទេ។

[១១:៣១:១៤]

**ស៖** ឥឡូវនេះខ្ញុំសូមលើកភស្តុតាងផ្សេងទៀតដើម្បីមកសួរលោក។ ខ្ញុំសូមចាប់ផ្តើមដោយលើកយកឯកសារផ្សព្វផ្សាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា "ការឈ្លានពានរបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ" គឺ E3/8403 ខ្មែរមានលេខ 00744492, អង់គ្លេសមានលេខ 00749682, បារាំងមានលេខ 00419636។ ដែលបានបញ្ជាក់ដូចតទៅនេះ៖ "ក្នុងពេលថ្មីៗនេះនៅថ្ងៃ២៤ កក្កដា ១៩៧៨ គឺ២៤ កក្កដា ១៩៧៨ វៀតណាមបានទទួលរងនូវការកម្ទេចម្តងទៀតនៅពេលដែលវៀតណាមព្យាយាមបញ្ជូនទាហានមកវាយប្រហារក្នុងតំបន់បាវិត ខេត្តស្វាយរៀងរបស់កម្ពុជា។ កងទ័ពបដិវត្តន៍កម្ពុជាយើងបានវ៉ៃប្រហារខ្លាំងយ៉ាងក្លាហាន ហើយបានកម្ទេចកង<វរសេនាតូច>របស់<>វៀតណាម<ឈ្លានពានទាំងស្រុង> គឺ<វរសេនា>តូចលេខ៥ របស់កងពល<តូច>លេខ៧។ ទាំងមនុស្សនិងកម្មាភិបាលរបស់ទាហាននេះត្រូវបានសម្លាប់ ហើយមានអ្នកនៅរស់ម្នាក់គឺអនុសេនាធំ <ង្វៀន> វ៉ាន់ កេ ដែលនៅរស់ ហើយត្រូវបានទាហានយើងចាប់ខ្លួន។" លោកសាក្សី ការផ្សព្វ

ផ្សាយរបស់ខាងវិទ្យុកម្ពុជាប្រជាធិបតេយ្យ ក៏បានលើកឡើងអំពីចម្លើយសារភាពរបស់ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួននេះដែរ គឺឯកសារE3/75 អង់គ្លេសមានលេខ <00168931> ហើយឯកសារនេះកំពុងតែដាក់នៅបកប្រែនៅឡើយ។ លោកសាក្សី នៅថ្ងៃ១២ កញ្ញា ៧៨ វិទ្យុកម្ពុជាប្រជាធិបតេយ្យនៅទីក្រុងភ្នំពេញបានផ្សព្វផ្សាយអំពីចម្លើយសារភាពមួយរបស់ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួន <នៅបាវិតផងដែរ>កាលពីខែសីហា ៧៨ គឺឯកសារ E3/1322។ ថាតើអ្វីដែលខ្ញុំអានហ្នឹងវាអាចធ្វើឲ្យលោកនឹកឃើញដែរឬទេ? <តើវាមិនពិតទេឬ>ដែលថាមានទាហានវៀតណាមមួយចំនួនត្រូវបានចាប់ខ្លួននៅក្នុងសមរភូមិនៅបាវិត នៅក្នុងកក្កដា និងសីហា ឆ្នាំ៧៨<>?

[១១:៣៤:២៤]

**ឆ៖** ខ្ញុំៗសូមបញ្ជាក់ឲ្យច្បាស់ ព្រោះការដែលព័ត៌មាន ឬដំណឹងអីនៅពេលនោះគឺជួនកាលក៏ខ្ញុំក្តាប់អត់បានដែរ អត់សូវបានស្តាប់ដែរ ព្រោះគ្មានវិទ្យុឯណាបានស្តាប់នោះទេ។ ហើយបើនិយាយពីការវ៉ៃលុកចូលទៅជ្រៅក្នុងទឹកដីយួន អីអានេះ ក៏ខ្ញុំនិងអង្គភាពខ្ញុំ ហើយខ្ញុំក៏គ្មានលទ្ធភាពនឹងទៅធ្វើកើតដែរ ដូច្នេះខ្ញុំធ្វើត្រឹមតួនាទីខ្ញុំដែលខ្ញុំវ៉ៃទប់នៅព្រំដែនទេ។ ដូច្នេះសំណួរដែលសួរទាំងអស់ហ្នឹង គឺខ្ញុំឆ្លើយអត់កើត ហើយខ្ញុំឆ្លើយអត់បាន ព្រោះខ្ញុំអត់បានទៅដឹកនាំធ្វើ ក៏ខ្ញុំមិនដឹងឆ្លើយថាម៉េច នេះខ្ញុំបញ្ជាក់។

**លោក ឌេល លីសាក់៖**

លោកប្រធាន តើខ្ញុំគួរបន្តទៅទៀត ឬក៏ឈប់សម្រាកសិន?

**ប្រធានអង្គជំនុំ៖**

យើងប្រធានអង្គជំនុំជម្រះ យើងនឹងលៃពេល ព្រោះដើម្បីជួសជុល ការបាត់បង់ពេលវេលាភាគីពាក់ព័ន្ធ ទុកលទ្ធភាពយើងអ្នកសម្របសម្រួលលើបញ្ហាពេលវេលា។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកនៅគ្រប់គ្រងទាហាននៅបាវិត នៅក្នុងខែកក្កដា, សីហា ឆ្នាំ៧៨ តើអ៊ីចឹងមែនទេ?

[១១:៣៥:៥២]

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំក្តាប់អត់សូវបានថ្ងៃខែហ្នឹងទេ។ នៅបាវិត គឺបើតាមខ្ញុំដែលទៅនៅនុំង ហើយទៅដល់នុំង

មិនដែលឃើញវៀតយួន ហើយចាប់បានយួនដែរ អត់ដែលឃើញ អត់មានដែលប្រយុទ្ធគ្នាធំនៅបារិតហ្នឹងផង អត់ដែលមានទេខ្ញុំ។ ហើយអង្គភាពខ្ញុំទៅដល់ អត់ដែលឃើញបានប្រយុទ្ធអី ហើយចាប់យួនបានអត់មាន។

**ស៖** ឥឡូវនេះខ្ញុំសួរលោកអ៊ីចេះវិញ។ តើលោកមានទទួលបញ្ជាពីមេខាងលើ ថាតើត្រូវធ្វើយ៉ាងម៉េច ប្រសិនបើលោកចាប់បានទាហានរបស់ខ្មាំង<>? តើមានការបញ្ជាថាតើត្រូវធ្វើយ៉ាងណាចំពោះទាហានដែលលោកចាប់ខ្លួនបានទេ <ហើយត្រូវបញ្ជូនពួកគេទៅកន្លែងណា>?

**ឆ៖** ហ្នឹងគឺមានបទបញ្ជាដែរ។ ចំពោះឈ្លើយសឹក គឺមានច្បាប់ គឺហាមឃាត់ដែរ ក្នុងសីលធម៌របស់កម្ពុជាប្រជាធិបតេយ្យ គេសឹក ថាឈ្លើយសឹកដែលចាប់បានមក គឺអត់ឲ្យជេរ ឲ្យវាយដំអីទេ គឺអត់ឲ្យមានធ្វើបាបធ្វើអីទេ អាហ្នឹងគឺឈ្លើយសឹក គឺច្បាប់មាន។ ប៉ុន្តែខ្ញុំអត់ដែលមានចាប់បានឈ្លើយសឹកអីមួយទេ អត់។

**ស៖** ថាតើគេមានបញ្ជាថា ទាហានវៀតណាមដែលចាប់បានហ្នឹង ឬក៏ទាហានដែលចាប់ខ្លួនបានហ្នឹង ត្រូវបញ្ជូនទៅណា ឬក៏យកទៅណាដែរ?

**ឆ៖** អត់មានបញ្ជាក់អីផង។ បើឧទាហរណ៍ថា បើយើងចាប់បាននៅក្នុងសមរភូមិណា អាហ្នឹងបញ្ជូនមកមេខាងក្រោយមកមេ បញ្ជូនមកក្រោយទៅ ថានៅសមរភូមក្រោយ អាហ្នឹងដឹងគេយកទៅខាងណា អាហ្នឹងក៏ក្តាប់អត់បានដែរ បើសិនជាចាប់បានទេ ប៉ុន្តែខ្ញុំ អង្គភាពខ្ញុំមិនដែលចាប់បានទេ។

[១១:៣៧:៥០]

**ស៖** នៅលើប្រធានបទនេះ ខ្ញុំចង់ឲ្យលោកសាក្សីស្តាប់នូវកំណត់ហេតុស្តាប់ចម្លើយរបស់មេបញ្ជាការកងវរសេនាធំ<មួយនៃកងពល៧០៣> គឺជាផ្នែកនៃកងពលរួមដែលដឹកនាំដោយ រ៉ែន គឺឯក-សារ E3/361 គឺឯកសារ E3/361 ខ្មែរមានលេខ 00194469, អង់គ្លេសមានលេខ 00766454 ដល់ 55 និងបារាំងមានលេខ 00268887។ នេះគឺជាអ្វីដែលគាត់បាននិយាយ សូមដកស្រង់៖ “ទាហានវៀតណាមទាំងអស់ដែលត្រូវបានចាប់ខ្លួននៅតាមព្រំដែនជិតខេត្តស្វាយរៀង និងព្រៃវែងត្រូវបញ្ជូនទៅភ្នំពេញ។ ដំបូងពួកគេត្រូវបញ្ជូនទៅ រ៉ែន នៅទីបញ្ជាការ ហើយគាត់ជាអ្នកសម្រេចថាតើត្រូវធ្វើយ៉ាងម៉េច។ វិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សព្វផ្សាយព័ត៌មានអំពីចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាម ដែលត្រូវបានចាប់ខ្លួននៅភូមិភាគបូព៌ា ហើយត្រូវបានបញ្ជូនទៅភ្នំពេញនៅក្នុងឆ្នាំ៧៧, ៧៨។” ថាតើវាជារឿងត្រឹមត្រូវដែរឬទេ ដែលថា ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួន <ទោះបីជា>ចាប់ខ្លួនបាន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

<ដោយកងពលរបស់លោក ឬក៏ចាប់បានដោយកងពលផ្សេងៗទៀតក្រោមបញ្ជារបស់> អ៊ែន <គឺ> ដំបូង<>ត្រូវបញ្ជូនទៅ អ៊ែន នៅបញ្ជាការដ្ឋានសិន តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំក៏សូមឆ្លើយហើយ ក៏បញ្ហានេះ វាហួសពីតួនាទីខ្ញុំ ហើយហួសពីភារកិច្ច ដូច្នេះខ្ញុំឆ្លើយទៅក្នុងនាមស្មាន ប៉ុន្តែបើតាមច្បាប់តាមក្រឹត្យក្រមវា គឺខាងក្រោម បើចាប់ពីកងពលតូចយកពីយកអង្គភាពយកទៅបាត់ មុខតែបញ្ជូនទៅហ្នឹងហើយ មុខបញ្ជូនទៅមេធំនោះគឺ អ៊ែន ហ្នឹងហើយ វរសេនីយ៍ហ្នឹងហើយ។ ប៉ុន្តែនេះក៏ ខ្ញុំគ្រាន់ជម្រាបអ៊ីចឹង បើជួនតាមគេធ្វើទៅ តាមខ្សែរយៈ តាមការចាត់តាំងរបស់គេ គេលើកពីរឿងកងពលតូចទៅកងពលធំអ៊ីចឹង តាមហ្នឹង។ ហើយត្រង់គេបញ្ជូនទៅណាទៀត អាហ្នឹងក៏ក្ដាប់មិនបានដែរ ព្រោះការទាំងអស់ហ្នឹងហួសពីសមត្ថភាពខ្ញុំ ហួសពីតួនាទីខ្ញុំ បើខ្ញុំជម្រាបជូន លែងត្រូវហើយ ខ្ញុំជម្រាបជូនលែងត្រូវហើយ។

[១១:៤០:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មវិញនៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀល។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រលប់ទៅកាន់កន្លែងបន្ទប់ស្នាក់នៅ ហើយនិងឱ្យអញ្ជើញគាត់មកកាន់ មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឱ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤១ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:២៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី យើងបាននិយាយគ្នាអំពីកងទ័ពវៀតណាមដែលអាចត្រូវបានចាប់ខ្លួននៅក្នុងសមរភូមិ។ តើលោកធ្លាប់ឮការផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ អំពីចម្លើយសារភាពរបស់កងទ័ពវៀតណាមដែលគេចាប់បាននេះទេ?

**លោក ជួន ធី៖**

**ធ៖** ខ្ញុំសូមបញ្ជាក់ នៅពេលនោះ រឿងវិទ្យុ នៅតាមអង្គភាពអត់មានវិទ្យុស្តាប់ផងទេ។ ដូច្នេះមិនបានទទួលដំណឹងពីសភាពការណ៍ខាងណេះខាងណោះយ៉ាងម៉េច គឺអត់បានស្តាប់បានដែរ អត់ស្តាប់បាន។

[១៣:៣៣:២៦]

**ស៖** ខ្ញុំសូមសួរអំពីវិទ្យុផ្សាយសំឡេងកម្ពុជាប្រជាធិបតេយ្យពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៣ តុលា ១៩៧៨ គឺនិយាយអំពីជ័យជម្នះ<ពី>ថ្ងៃ១៦ <ដល់ថ្ងៃ៣០> កញ្ញា ទៅលើកងទ័ព<សាធារណរដ្ឋសង្គមនិយម>វៀតណាម គឺឯកសារ E3/294។ អង់គ្លេស 00170239 មិនមាន ERN ជាភាសាខ្មែរ ឬក៏ជាភាសាបារាំងនៅឡើយទេ។ មិនទាន់មានការបកប្រែទេ ខ្ញុំសូមដកស្រង់អំពីការផ្សាយតាមវិទ្យុនាពេលនោះ។ សូមដកស្រង់៖ “ថ្មីៗនេះពួកអាខ្មាំងយួនបានបញ្ជូនកម្លាំងរបស់វា មកធ្វើការឈ្លានពានយ៉ាងបើកចំហ មកចូលមកក្នុងបូរណភាពដែនដីកម្ពុជា នៅព្រំដែនស្វាយរៀង ប៉ុន្តែពួកវាគឺថាត្រូវបានទទួលបរាជ័យយ៉ាងអាម៉ាស់។ <ខាងក្រោមនេះគឺចំនួនដែលបានកត់ត្រាពី>ថ្ងៃទី១៦ ទៅថ្ងៃ< ខែ> កញ្ញា ៧៨ កងទ័ពបដិវត្តរបស់យើងបានសម្លាប់កងទ័ពវៀតណាម៤២២នាក់ និងចាប់បានមួយចំនួន។ ហើយយើងបានរឹបអូសអាវុធបេ-៤០ ១១ដើម, បេ-៤១ ប្រាំមួយដើម, អឹម-៧៩ បីដើម, អឹម-៧២ ១២៨ដើម,

01376896



អាវុធម៉កជេ ៦០មិល្លីម៉ែត្រ បីដើម, ដេកា-៨២ មួយដើម, ដេកា-៧៥ <បី>ដើម<>។" <ហើយមានរៀបរាប់បន្តទៀតនូវបញ្ជីអាវុធមួយចំនួនដែលគេបានកត់ត្រា។>

អ៊ីចឹង<ថាតើរបាយការណ៍នេះធ្វើឡើងដោយ>លោក<> ឬក៏ ធី ពូសសេ <ពាក់ព័ន្ធទៅនឹង> សកម្មភាពទាំងឡាយនៅសមរភូមិ<ផ្តល់ជូន>ទៅ វ៉ែន <មេបញ្ជាការកងពល>? ឬក៏សួរម្យ៉ាងទៀតថា តើកងពលរបស់លោកមានបានរាយការណ៍ទៅ វ៉ែន អំពីការប្រយុទ្ធគ្នាមួយចំនួននៅតាមសមរភូមិនោះដែរឬទេ?

[១៣:៣៦:១២]

**ធ៖** ខ្ញុំសូមបញ្ជាក់អំពីសភាពការណ៍ប្រកាសជ័យជម្នះប៉ុន្មានៗ និងសភាពការណ៍យ៉ាងម៉េចដែលវិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សាយមក គឺខាងខ្ញុំអត់បានស្តាប់ និងបានទទួលទេ។ ដូចខ្ញុំបញ្ជាក់អ៊ីចឹងថាគ្មានវិទ្យុអីនឹងស្តាប់ទេ នៅមុខ ហើយក៏គ្មានពេលនឹងស្តាប់ដែរ។ ហេតុដូច្នេះចំពោះការរាយការណ៍ទៅខាងលើ ក៏មិនច្បាស់លាស់ដែរ ព្រោះមិនសូវបានរាយការណ៍ដែរទេ ព្រោះនៅវ៉ៃនៅនឹងស្វាយរៀងនៅព្រំប្រទល់ហ្នឹងដែរ ដូច្នេះមិនមានបញ្ហាអីនឹងរាយការណ៍ទៅផងទេ។ អត់ៗបានរាយការណ៍អីទេ រាយការណ៍ពេលខ្លះ។ ប្រាប់ខ្វះគ្រាប់ ខ្វះរំសេវអី អាហ្នឹងប្រាប់។ រឿងសភាពការណ៍ ដូចមិនមានអីនឹងប្រាប់ផង អត់មានរឿងអីប្រាប់ មានការដែលនេះផង សូមបញ្ជាក់មានប៉ុណ្ណឹង។

**ស៖** តើមានពេលណាមួយដែលកងពលរបស់លោក អាចទទួលបានអាវុធ និងគ្រាប់រំសេវ រឹបអូសបានអាវុធគ្រាប់រំសេវពីកងទ័ពវៀតណាមដែរឬទេ?

**ធ៖** កងទ័ពរបស់ខ្ញុំអត់ដែលបានរឹបនិងយកបានគ្រាប់ និងកាំភ្លើងពីកងទ័ពវៀតណាមទេ ព្រោះជីក ព្រោះខ្ញុំវ៉ៃនៅនឹងទល់មុខហ្នឹង គឺអត់មានវ៉ៃរុកទៅណា គឺទប់នៅហ្នឹង។

**ស៖** ពាក់ព័ន្ធទៅនឹង វ៉ែន ដែលជាមេបញ្ជាការកងពលចម្រុះនោះ <តើលោកដឹងទេថា>តើគាត់<រាយការណ៍ទៅមេដឹកនាំនៅភ្នំពេញដែរឬទេ? តើលោកដឹងទេ ថាតើគាត់>មានឡើងមកភ្នំពេញ ដើម្បីចូលរួមប្រជុំអ្វីមួយដែរទេ?

**ធ៖** បញ្ហានេះខ្ញុំក្តាប់អត់បាន ព្រោះៗវានៅឆ្ងាយ ហើយគេក៏មានការងារអី ក៏គេអត់ប្រាប់យើងដែរ ព្រោះអាហ្នឹងការងារគេផ្សេង ការងារខ្ញុំខាងក្រោម ដូច្នេះអត់មានប្រាប់អីទេ។ ទៅថ្មើរណា មកវិញក៏គេអត់ប្រាប់។

[១៣:៣៨:៤៣]

**សៈ** ខ្ញុំសូមអានសក្ខីកម្មមួយដែលបានឆ្លើយដោយមេបញ្ជាការកងអន្តរាគមន៍នៃកងពលតូច ២២១ គឺខ្ញុំបានប្រគល់ឯកសារនេះជូនលោកពីមុនមកហើយ គឺ 2-TCW-<1046> ជាចម្លើយដែលបានឆ្លើយជាមួយសហចៅក្រមស៊ើបអង្កេតគឺ E3/419 – E3/419 ត្រង់ចម្លើយលេខ១២។ នេះគឺជាចម្លើយរបស់អតីតមេបញ្ជាការកងពលលេខ២២១ សូមដកស្រង់៖ “វ៉ែន បានធ្វើការប្រកាសក្នុងពេលប្រជុំអំពីអំពើក្បត់របស់កម្មាភិបាលភូមិភាគបូព៌ា ដែលថាអ្នកទាំងអស់នោះ គឺត្រូវបានចាប់ខ្លួន និងបញ្ជូនទៅថ្នាក់លើ ហើយអ្នកខ្លះហ្នឹងបានរត់គេចខ្លួនទៅវៀតណាម។ អ៊ីចឹងនៅពេលនោះ គឺថាមិនមានកម្មាភិបាលនៅភូមិភាគបូព៌ាទៀតទេ។ កិច្ចប្រជុំនេះនិយាយអំពីអង្គប្រជុំនៃការវាយប្រយុទ្ធបកទៅលើកងទ័ពវៀតណាម។ ខ្ញុំដឹងថា វ៉ែន នេះបានឡើងមកប្រជុំនៅភ្នំពេញ<ជាញឹកញាប់> គឺគាត់<បានសរសេរសំបុត្រមកប្រាប់ខ្ញុំថា គាត់>ឡើងមកប្រជុំនៅភ្នំពេញ ហើយ<ស្នើឱ្យអ្នកនៅមូលដ្ឋានគ្រប់គ្រងការប្រយុទ្ធដោយប្រុងប្រយ័ត្ន>។ ការឡើងមកប្រជុំនៅភ្នំពេញនេះ គឺពិតជាប្រជុំជាមួយ ប៉ុល ពត និង សុន សេន ហើយ។” នៅត្រង់ចម្លើយលេខ១៣ <គាត់>ថា៖ “ក្រោយពីត្រឡប់ពីក្រុងភ្នំពេញទៅវិញ វ៉ែន គឺបានហៅគ្រប់មេបញ្ជាការកងពលតូច កងពលធំទាំងអស់ឡើងមកប្រជុំ <ដើម្បីប្រាប់>នូវអ្វីដែលគាត់បានទទួលព័ត៌មានពីភ្នំពេញទៅ។” បញ្ចប់ការដកស្រង់។

តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ លោកសាក្សី? តើលោកដែលបានចូលរួមប្រជុំជាមួយ វ៉ែន ដែល វ៉ែន ប្រាប់ថា គាត់បានទទួលសេចក្ដីបញ្ជា ទទួលបញ្ជាពីភ្នំពេញនោះ ឬក៏<> ធី ពូសសេ <មានដែលរាយការណ៍ទៅឱ្យលោកទេ អំពីកិច្ចប្រជុំជាមួយវ៉ែន>?

[១៣:៤១:០៧]

**ឆៈ** ខ្ញុំសូមបញ្ជាក់ គឺការប្រជុំ តាវ៉ែន ជាមួយ តាវ៉ែន ក៏ខ្ញុំអត់ដែលបានប្រជុំជាមួយទេ ព្រោះប្រធាន ធី ពូសសេ គេប្រធាន ដូច្នេះគេត្រូវប្រជុំអី ដូច្នេះតែដល់ពេលក្រោយមក ក៏អត់ដែលមានឮនិយាយពីរឿងថាបូព៌ា ចាប់កម្មាភិបាលបូព៌ាអ៊ីចេះអ៊ីចុះ ក៏អត់មានដែលឮដែរ អត់មានដែលឮនិយាយអីពីរឿងអស់ហ្នឹងទេ គឺគិតគូរតែរៀបចំកម្លាំងយ៉ាងម៉េច កុំឱ្យយួនបុកចូលមកទឹកដីយើងបាន គឺមានតែការពិគ្រោះគ្នា ពិភាក្សាប៉ុណ្ណឹង។ ឯការក្ដាប់សភាពការណ៍ផ្សេងៗ ដូចជាជនក្បត់នៅបូព៌ា បូអី គឺខាងខ្ញុំអត់ដែលបានឮ ហើយបានទទួលទេ។ សូម្បីតែមួយម៉ាត់ ក៏អត់ដឹងផង អ្នកណាយ៉ាងម៉េច អីយ៉ាងម៉េច ក៏អត់ដឹង ព្រោះខ្ញុំនៅ គ្រាន់តែថ្នាក់ហ្នឹងមែន ប៉ុន្តែតួនាទីតូច ទាប ហើយមិនៗបានត្រូវដឹងអីក្នុងការងារនេះ ជាការងាររបស់ខាងលើ វាហួសៗសមត្ថភាពខ្ញុំដែលខ្ញុំត្រូវដឹង ត្រូវឮហើយ។

**ស៖** ទាក់ទងទៅនឹងព័ត៌មានអំពីសមរភូមិនានាដែលគាត់បានរាយការណ៍មកភ្នំពេញ ខ្ញុំសូមលើកយកភស្តុតាងមួយមកសួរលោក គឺឯកសារ E3/3751– E3/3751 ដែលចុះថ្ងៃទី០៣ មករា ៧៩ របាយការណ៍របស់អា.ប៉េ និយាយអំពីការគាំទ្រពីសំណាក់សូវៀតចំពោះទីក្រុងហាណូយ<ក្នុងការឈ្លានពានកម្ពុជា> ដែលមាន រាយការណ៍ដូចតទៅ៖ “កម្ពុជាបានចោទប្រកាន់ពីម្សិលមិញថា វៀតណាមបានឈ្លានពានចូលយ៉ាងជ្រៅមកបូរណភាពដែនដី ទិសខាងកើត ហើយពួកឧទ្ទាមដែលគាំទ្រដោយក្រុមហាណូយបានគ្រប់គ្រង<ទីប្រជុំជននៅតាមដងទន្លេមេគង្គ>។ ប្រធានាធិបតី ខៀវ សំផន បានចោទប្រកាន់<សហភាព>សូវៀត ចំពោះការ<គាំទ្រវៀតណាម>ឈ្លានពាននេះ <ដោយនិយាយថាចាប់តាំងពីថ្ងៃបុណ្យគ្រីស្មាស់> ពួកកងទ័ព<ថ្មើរជើង>វៀតណាម <រថក្រោះ និងយន្តហោះចម្បាំង>បានចូលយ៉ាងជ្រៅមកទិសបូព៌ានៃប្រទេសកម្ពុជា។ ប្រធានាធិបតី ខៀវ សំផន និយាយថា ការវាយប្រហារចម្បងៗរបស់វៀតណាម គឺនៅរតនគិរី និងនៅខេត្តក្រចេះ ព្រមទាំងតាមបណ្តោយផ្លូវជាតិលេខ៧ផងដែរ ហើយនិងតាមផ្លូវមកកាន់ក្រុងកំពង់ចាម។ ប្រភពដែលគួរឲ្យជឿជាក់បាននៅទីក្រុងបាងកក បញ្ជាក់ថា <ទីប្រជុំជន>ទន្លេមេគង្គ នៅខេត្តក្រចេះ ត្រូវបានវៀតណាមរឹបអូស ហើយ ខៀវ សំផន រាយការណ៍ថា កងទ័ពវៀតណាមប្រហែលជា១០.០០០នាក់ ត្រូវបានសម្លាប់ និងរងរបួសនៅ<កម្ពុជាក្នុង> រយៈពេល<៣>ខែចុងក្រោយនេះ<ក្នុងឆ្នាំ១៩៧៨>។” បញ្ចប់ការដកស្រង់។

សំណួរដំបូងរបស់ខ្ញុំ លោកសាក្សី យើងនិយាយអំពីការបាញ់ផ្តោងពីសំណាក់កងទ័ពវៀតណាម នៅចុងឆ្នាំ៧៨ តើលោកចាំថា វានៅថ្ងៃទី២៥ ខែធ្នូ ៧៨ឬ គឺការវាយប្រយុទ្ធទ្រង់ទ្រាយរបស់វៀតណាមហ្នឹង តើនៅថ្ងៃទី២៥ ធ្នូ ៧៨ ឬក៏យ៉ាងណា?

[១៣:៤៤:៤៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ ខ្ញុំអត់បានចាំពេលវេលាទេ គឺថាខែណា អីខែណាទេ គឺពេលនុំង គឺដល់ដឹងថា ខ្ញុំក៏មិនដឹងកំណត់ដែលចិត ចុងចិត ដើម៧៩ មិនដឹង ឬក៏ចុង៧៨ ដែលពេលហ្នឹងយួនបុកខ្លាំង គឺចូលគ្រប់ទីកន្លែងទាំងអស់ ទាំងស្វាយរៀង ទាំងគេ ទាំងខ្ញុំ គឺដែលខ្ញុំថាបាក់ទ័ពរត់ខ្ចាត់ខ្ចាយអស់។ ទ័ពលែងស្គាល់មេ មេលែងស្គាល់កូន លែងស្តាប់អ្នកណាអ្នកណី គឺម្នាក់ៗរត់រករួចខ្លួន ដូច្នេះលែងទទួលផែនការអី ផែនការទាំងអស់បាននៅ៧៩ ពេលដែលយួនបុកធំមក គឺផែនការហ្នឹងគឺត្រូវរលាយ។ ការទប់ទល់ជាមួយយួនក៏ត្រូវអស់ហើយ អស់មានសិទ្ធិ អស់មានកម្លាំង អស់មានបញ្ជាពីអ្នកណា ហើយអស់មានអ្នកណាឧបត្ថម្ភមេខាងលើ ខាងក្រោម អត់មានអ្នកណាឧបត្ថម្ភទេ។ ដូច្នេះស្វែងរស់ រត់ទៅរកតាម

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ស្រុកតាមភូមិ តាមប្រពន្ធ តាមកូន រៀងៗខ្លួនហើយពេលហ្នឹង។

**ស៖** តើលោកចាំទេ ក្រោយការវាយប្រយុទ្ធទ្រង់ទ្រាយធំនេះ ដែលកងទ័ពរបស់លោកបានចុះចាញ់ តើរយៈពេលប៉ុន្មានថ្ងៃ ឬក៏រយៈពេលប៉ុន្មានម៉ោងក្រោយពីការវាយទប់ទល់ហើយ កងទ័ពរបស់លោកក៏ត្រូវបានខ្ចាត់ខ្ចាយ ដកថយនោះ?

**ឆ៖** គឺចាញ់នោះ គឺអត់មាន គឺចាញ់រហូតតែម្តង គឺអត់មានរកទ័ពប្រមូលវិញមិនងាយបានរាប់ខែ រាប់ឆ្នាំក៏ប្រមូលមិនបានផង។ គេរត់ទៅផ្ទះ ទៅសម្បែង អាខ្លះគេជួបជុំម៉ែឪគេវិញទៅ ដូច្នេះរកមិនដែលឃើញផង។ ដូច្នេះពេលវេលាហ្នឹងក៏ចប់ការប្រយុទ្ធជាមួយយួន គឺពេលហ្នឹង គឺលែងធ្វើអីកើតហើយ ព្រោះអត់កម្លាំង គឺគ្រាន់តែនៅដើម្បីរស់ការពារអាយុជីវិតខ្លួនអ៊ីចឹង ព្រោះចាញ់គេអស់ហើយមានធ្វើអីកើត។

**ស៖** ចុះលោកវិញ លោកទៅទីណាដែរ? ហើយលោកធ្វើអ្វីដែរនៅពេលដែលកងទ័ពវៀតណាមវាយបុកមកហើយ បែកបាក់ខ្ចាត់ខ្ចាយពីគ្នានុំង?

[១៣:៤៧:០០]

**ឆ៖** ពេលដែលកងទ័ពយួនបុកខ្ចាត់ខ្ចាយ ខ្ញុំអត់មានធ្វើអីទេ ត្រូវដើរពួនសំងំនៅជិតផ្ទះហ្នឹង នៅជិតស្រុកជិតភូមិហ្នឹង ដើម្បីរស់។ តែគ្រាន់តែមិនហ៊ានចូលភូមិទេ ខ្លាចយួនសម្លាប់ នៅជិតៗភូមិនុំង។ ហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹង។ អត់មានធ្វើអីទេ អត់មានធ្វើអីកងទ័ពទៀតអីទៀតពេលនុំង ព្រោះអស់កម្លាំងអស់អីរលីង គ្មានអ្នកណាឧបត្ថម្ភទេ មិនដឹងមេនៅឯណា កូននៅអីណា ឆ្នាំងបាយ ឆ្នាំងអីនៅឯណា គឺអត់មានទេ។ ដូច្នេះស្វែងរកកន្លែងរស់ កន្លែងសុខ។

**ស៖** នៅពេលថា លោកទៅផ្ទះទៅភូមិ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមអភ័យទោស ដែលខ្ញុំរំខានដល់សហព្រះរាជអាជ្ញា។ ខ្ញុំគិតថា ដូចជាមានសំឡេងរំខាននៅក្នុងកាសស្តាប់ត្រចៀក ជាពិសេសគឺភាសាបារាំង និងភាសាអង់គ្លេសនេះ។ ខ្ញុំមិនដឹងថាតើលោកប្រធានមានវិធីអ្វីដើម្បីដោះស្រាយបញ្ហាបច្ចេកទេសនេះ<បានទេ ខណៈ>ព្រះរាជអាជ្ញាសួរបន្ត<>ប៉ុន្តែ<គ្រប់ៗគ្នានៅខាងនេះមានបញ្ហាដូចគ្នា>។

**លោក ឌេល លីសាក់៖**

ប្រហែលជាវាចេញមកពីខាង *បេកក្រោន* ខ្ញុំអត់អីទេ ខាងកាណាល់របស់ខ្ញុំនេះ។

[១៣:៤៨:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន អស់អីហើយឥឡូវ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញៗបន្តទៀតសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីលោកបានបញ្ជាក់ថា នៅពេលដែលកងទ័ពវៀតណាមវាយបុកចូលមកលោកបានរត់ពួននៅផ្ទះ នៅភូមិរបស់លោកហ្នឹង លោកនិយាយអំពីទីកន្លែងនៅឯស្វាយរៀង ឬក៏លោករត់ទៅផ្ទះ និងភូមិហ្នឹងនៅឯណាដែរ?

**ឆ៖** ពេលដែលចាញ់យួនហ្នឹង គឺមិនមែននៅស្វាយរៀងទេ គឺទៅនៅព្រំដែន នៅស្រុកភូមិខ្ញុំ នៅខាងកំពង់ស្ពឺ ខាងឱរ៉ាល់ខាងអីនោះ គឺស្រុកកំណើតខ្ញុំនៅអីនុ៎ង។ នាំគ្នារត់ទៅពួននៅហ្នឹង។

**ស៖** មុននេះពីរបីនាទីនេះ លោកបាននិយាយថា លោកមិនធ្លាប់ដែលឮអំពីការចាប់ខ្លួនកម្មាភិបាលភូមិភាគបូព៌ាទេ។ នៅក្នុងអំឡុងពេល៦ខែ ដែលលោកពាក់ព័ន្ធក្នុងការប្រយុទ្ធនៅឯស្វាយរៀងនោះ តើកងទ័ពមកពីកងពលរបស់លោក<គឺកងពល៣៤០>មានត្រូវបានខាងណាចាប់ខ្លួន ឬបញ្ជូនមកភ្នំពេញដែរឬទេ?

**ឆ៖** កងទ័ពខ្ញុំដែលមកនេះនៅធ្វើការនៅស្វាយរៀងនេះ បំពេញបេសកកម្មនៅស្វាយរៀងនេះ គឺក្នុងនាមខ្ញុំជាអ្នកដឹកនាំ ខ្ញុំមិនដែលចាប់ទ័ពខ្ញុំ ឬនរណាមកចាប់ពីអង្គភាពខ្ញុំយកទៅឲ្យខាងលើគឺអត់មាន។

[១៣:៥០:៥១]

**ស៖** ខ្ញុំយល់ហើយ លោកហ្នឹងគឺថាមិនធ្លាប់ដែលចាប់ខ្លួនទាហានរបស់លោកទេ ក៏ប៉ុន្តែតើ<កងទ័ពក្នុង>កងពល<៣៤០>របស់លោកនេះ ខ្ញុំចង់និយាយអំពីរឿងកងទ័ពនៅក្នុងកងពលរបស់លោកហ្នឹង

តើមានគេចាប់ខ្លួនបញ្ជូនមកភ្នំពេញអីដែរទេក្នុងរយៈពេល៦ខែនោះ?

**ឆ៖** ក្នុងរយៈពេល៦ខែនេះ គឺឧទាហរណ៍ក្នុងរយៈពេល៦ខែនៅក្នុងអង្គភាពកងពលខ្ញុំគឺអត់មាននរណាចាប់មកភ្នំពេញទេ អត់មានទេ។

**ស៖** លោកសាក្សី មូលហេតុដែលខ្ញុំសួរលោកសំណួរនេះដោយសារថាការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលបញ្ជីអ្នកទោស ស-២១ ឯកសារ <E3/10604> – <E3/10604> ដែលមានយុទ្ធជន១៦នាក់មកពីកងពលតូច៣៤០ ត្រូវបានបញ្ជូនមកស-២១ នៅចន្លោះថ្ងៃទី២៤ កក្កដា ៧៨ និងថ្ងៃទី ០១ មករា ៧៩។ ដើម្បីប្រតិចារឹក លោកប្រធានគឺ យុទ្ធជនទាំង១៦នាក់មកពីកងពល ៣៤០ គឺមានលេខរៀង១០៤៤, <៤១៧១,> ៥២០៨, ៥៨៥៨, ៧៩០៩, ៨២៨៦, <៩៥៦២> និង <១២០០៧>, <ដល់ ១២០០៨>, <១២៥៤៩>, <១២៥៥១>, <១២៥៥៩>, <១២៨៤០ ដល់ ៨៤១, ១៤០៥៧> និងលេខរៀង <១៤១៩៤>។ សូមការអនុញ្ញាតដើម្បីបង្ហាញជូនសាក្សីនូវបញ្ជីអ្នកទោសនេះ។ ឯកសារមួយគឺ E3/10205 – E3/10205 ដែលមានបញ្ជីអ្នកទោសប្រាំបួននាក់មកពីកងពលតូច៣៤០ជូនមកស-២១ នៅខែតុលា។ លោកប្រធានសូមការអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារទាំងពីរនេះ។

[១៣:៥៣:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយក្រឡាបញ្ជីយកឯកសារជូនសាក្សីមកៗណេះ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីសហព្រះរាជអាជ្ញារងយកជូនសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឯកសារនេះមានតែជាភាសាខ្មែរទេ ក៏ប៉ុន្តែទំព័រខ្មែរហ្នឹង 01016474 ដល់75 ខ្ញុំបានដាក់*ហាយឡាយ*បញ្ជាក់នៅលើចំណុចនេះដែរ ដូចខ្ញុំបានជម្រាបជូនមានយុទ្ធជនប្រាំបួននាក់មកពីកងពលតូច៣៤០។ ខ្ញុំសូមសួរលោក ហើយចង់ដឹងថាតើលោកមានចាំយុទ្ធជនណាខ្លះដែរឬទេ? ជាពិសេសបុគ្គលចុងក្រោយ អ្នកទោសចុងក្រោយ លេខ៩ ឈ្មោះ រដ្ឋ ហាន ដែលជាលេខាកងពល<៣៤០>ដែលចូលមកស-២១នៅថ្ងៃទី២៦ ខែតុលា ៧៨។ លោកចាំលេខាកងវរសេនាតូចនេះទេ? ហើយតើលោកនៅចាំទេ ថាតើយុទ្ធជនមកពីកងពល<៣៤០>ហ្នឹង ត្រូវបានគេបញ្ជូនមកស-២១ ដោយមូលហេតុអីដែរ?

01376902



**លោក ជួន ធី៖**

**ធ៖** ខ្ញុំសូមបញ្ជាក់ឈ្មោះទាំងប្រាំបួននាក់ ដែលនៅក្នុង ថានៅក្នុងកងពល៣៤០នេះ ខ្ញុំអត់មានស្គាល់ទេ។ ហើយក៏នៅពេលនោះ ចំពោះខ្ញុំ និងអង្គភាព ក៏មិនដែលស្គាល់ព្រៃសផង គុកព្រៃសមិនដែលឮឈ្មោះផងទេ ហើយអត់មានការងារអីនឹងទៅ អត់មានត្រូវចាប់បញ្ជូនមកដាក់គុកព្រៃសទេ។ ខ្ញុំសូមបដិសេធថា ខ្ញុំអត់បានដឹងឮ ហើយក៏អត់បាននេះដែរ អត់ស្គាល់ដែរឈ្មោះប្រាំបួនរូបហ្នឹង។

[១៣:៥៦:១៦]

**ស៖** ចុះលោកមាននៅចាំទេ ថាយុទ្ធជននៅក្នុងអង្គភាពលោក នៅក្នុងតុលា ៧៨ ត្រូវបានគេហៅឈ្មោះមកហើយ បាត់ខ្លួននោះដែរឬទេ?

**ធ៖** ក្នុងខែតុលា ដែលគេហៅមក គឺខ្ញុំអត់មានដែលឮខាងលើណាហៅមកផង។ ដូច្នេះគិតតែនាំគ្នានៅមុខ ប្រយុទ្ធនឹង អត់មានឮគេហៅមកទេ ហើយក៏មិនដែលបានដឹងថា បាត់ខ្លួនមក គេចាប់អីអត់មានដែលដឹងផង។ ព្រោះខ្ញុំអត់មានបានទទួល បានដឹងនេះហើយ ក៏អង្គភាព បើសិនជាទៅ ក៏ខ្ញុំអាចដឹងដែរ តាគយ តាអីហ្នឹង។ ព្រោះខាងលើ បើខាងលើចាប់ចងអី ក៏មកសួរម្ចាស់អង្គភាពដែរ បើម្ចាស់អង្គភាពមិនអនុញ្ញាតទេ ក៏អត់ហ៊ានដែរ។ ដូច្នេះអង្គភាពខ្ញុំអត់មានដឹងឮថា ចាប់អី ថាទៅណា មកណាអត់មានទេ គឺអង្គភាពខ្ញុំនៅមុខទាំងអស់។ ហ្នឹងខ្ញុំសូមបញ្ជាក់អីចឹង។

**ស៖** ប្រហែលជាដោយសារការបកប្រែទេ គឺឈ្មោះមួយ ឈ្មោះ តាគុយ ឬក៏តាកុយ នេះ ជាអ្នកណាដែរ?

**ធ៖** អត់ស្គាល់។ តាគុយ, តាកុយ ក៏ដោយ។ តាកុយ ក៏មិនមានស្គាល់ អត់ស្គាល់។ តាគុយ ក៏អត់ដែរ។ អត់មានឈ្មោះទេ ក្នុងហ្នឹង។ ក្នុងកន្លែងខ្ញុំ អង្គភាពខ្ញុំអត់មាន។

**ស៖** ប្រហែលជាដោយសារបញ្ហាបកប្រែហើយ ជាភាសាអង់គ្លេស គឺប្រហែលដោយសារការបកប្រែសំណេរនេះឯង គឺឈ្មោះ តាគុយ។ តែយ៉ាងណា ខ្ញុំចូលទៅប្រធានបទមួយទៀតទៅចុះ។ លោកមកពីភូមិបស្ចិម តើលោកស្គាល់ទីតាំងមួយនៅភូមិភាគបស្ចិម លោកស្គាល់ព្រលានយន្តហោះកំពង់ឆ្នាំងដែលត្រូវបានគេកសាងនៅឆ្នាំ៧៧ និង៧៨ នោះដែរឬទេ? ស្គាល់ទីតាំងវាទេ?

[១៣:៥៨:៣៨]

**ធ៖** ខ្ញុំចំពោះព្រលានយន្តហោះ ដែលទី បោះទីតាំងសង់ថ្មីនេះហ្នឹង នៅកំពង់ឆ្នាំង ខ្ញុំអត់ស្គាល់ហើយក៏អត់ដែលចាំដែរ។ ប៉ុន្តែខ្ញុំគ្រាន់តែឮគេថា គេត្រូវទៅធ្វើព្រលានឡានហោះយោធាមួយ នៅកំពង់

ឆ្នាំង តែមិនដឹងធ្វើកន្លែងណា គ្រាន់តែឮគេថាទេ។ គេទៅធ្វើនៅកំពង់ឆ្នាំង ឮថាមែន ប៉ុន្តែគ្រាន់តែមិនដឹងធ្វើនៅកន្លែងណា អីៗ ព្រោះខ្ញុំអត់មានអីមកនេះហ្នឹងផង អត់ដឹងផង គ្រាន់តែដឹងថាប៉ុណ្ណឹង។

**ស៖** តើលោកមានដឹងទេថា <ថាតើ>កងទ័ពមកពីកង<វរសេនាធំ>របស់លោក <នៅពេលលោកនៅភូមិភាគបស្ចិម> ឬមួយក៏<កងទ័ព>មកពីកង<ពល>របស់លោក <នៅពេលលោកនៅខេត្តស្វាយរៀង> ថាតើមានទាហានរបស់លោកណាម្នាក់ត្រូវបានគេបញ្ជូនឱ្យទៅធ្វើការសាងសង់នៅព្រលានយន្តហោះកំពង់ឆ្នាំងនោះទេ?

**ឆ៖** ខ្ញុំឆ្លើយ ចំពោះទាហានរបស់ខ្ញុំ អត់មានដែលគេយកទៅឱ្យសាងសង់ទាហាន នៅព្រលានយន្តហោះកំពង់ឆ្នាំងទេ អត់មានទេ។

**ស៖** អាឡូវនេះ ខ្ញុំសូមសួរលោកអំពីសក្ខីកម្មមួយចំនួនរបស់មេបញ្ជាការកងវរសេនាធំ<នៅក្នុងកងពល៧០៣> ដែលខ្ញុំបានសួរលោកមុននេះ គឺកំណត់ហេតុស្តាប់ចម្លើយ E3/421 សំណួរ-ចម្លើយទី២។ សាក្សី<នេះ>បានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "សុន សេន ទៅស្វាយរៀង ហើយបានធ្វើការប្រជុំជាមួយមេបញ្ជាការទាំងអស់។ បន្ទាប់មកទៀត គឺគាត់និយាយអំពីមេបញ្ជាការ២២១ គឺមេបញ្ជាការ និងមេបញ្ជាការរងរបស់កងពល២២១ ហើយគាត់បន្តទៀតថា សុន សេន ប្រកាសថាទាហានទាំងអស់ដែលដកចេញពីបូព៌ាត្រូវបញ្ជូនទៅសាងសង់ព្រលានយន្តហោះនៅកំពង់ឆ្នាំង។ ចំណែកមេបញ្ជាការត្រូវចាប់ខ្លួន ហើយបញ្ជូនទៅស-២១។" ខ្ញុំសូមបញ្ចប់ការដកស្រង់។ ក្រៅពីទាហាននៅក្នុងកងពលរបស់លោក តើលោកមានឮថា មានទាហានរបស់កងពលដទៃទៀតនៅភូមិភាគបូព៌ា ថាពួកគាត់ហ្នឹងត្រូវបានគេបញ្ជូនទៅសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងទេ?

[១៤:០១:៣០]

**ឆ៖** ខ្ញុំសូមបញ្ជាក់ដើម្បីឱ្យច្បាស់ ហើយកុំឱ្យសង្ស័យថា ដូច្នេះអង្គភាពខ្ញុំដែលមករស់នៅ វ៉ៃនឹងយួននៅព្រំដែននេះ គឺដូច្នេះរស់នៅដូចដាច់ខាងមុខ ដាច់ខាងក្រោយអ៊ីចឹង។ ដូច្នេះមិនដឹងដំណឹងអី មិនដឹងព័ត៌មានអីទេ ដូច្នេះអត់ដឹងទេ ដឹងតែការពារ និងវ៉ៃប៉ុណ្ណឹងទេ។ ដូច្នេះអ្នកណាយកទៅណា អីយកទៅណានេះ ថ្នាក់លើគេអត់ឱ្យយើងដឹងទេ។ ដឹងខ្លាចខូចអារម្មណ៍ ខ្លាចខូចអារម្មណ៍ដែរ ប៉ះពាល់សាច់ឈាមគេ ក្រែងលោគេមិនទុកចិត្ត ខាងលើគឺមិនប្រាប់ឱ្យយើងដឹងទាំងអស់គ្នាទេ គឺអត់ដឹងទេ ការងារគេគេដឹង ការងារយើង យើងដឹង។ អាហ្នឹងសូមបញ្ជាក់អ៊ីចឹង។

**ស៖** ក្នុងពេលដែលលោកនៅសមរភូមិ តើលោកទំនាក់ទំនងជាមួយមេខាងលើរបស់លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ដោយរបៀបណា? តើ<លោកមាន>វិទ្យុទាក់ទង<ដើម្បីទាក់ទងជាមួយ> ធី ពូសសេ <ឬក៏ វ៉ែន ទេ នៅពេលលោកនៅសមរភូមិ>នោះ?

**ឆ៖** ការទាក់ទងមកខាងលើ ព្រោះខ្ញុំ និង ធី ពូសសេ នៅជិតគ្នា ដូច្នេះទាក់ទងមានការអីល្ងាចឡើងជួបជុំគ្នា ពិភាក្សាគ្នារឿងរៀបចំកម្លាំង ដូច្នេះអត់មានទាក់ទងអីទៅលើទេ។ ដូច្នេះវិទ្យុទាក់ទងអីក៏ដូចជាមិនសូវ ដូចជាអត់មានផងទេ។ បើមានអីនឹងប្រើកាលនុ៎ង មិនទាន់មានវិទ្យុអីណាស្រួលបួល អត់វិទ្យុទាក់ទងនោះ អត់មានទេ។ ហើយគ្រាន់តែវិទ្យុស្តាប់ហ្នឹង ក៏អត់មានដែរក្នុងអង្គភាពនោះ។ ដូច្នេះសភាពការណ៍ទាំងឡាយ ទាំងពួងហ្នឹង គឺមក គឺដូចជាអត់មានអីបានដឹង បានឮទេ។

[១៤:០៣:១៩]

**ស៖** ចុះប្រធាន<កងវរសេនា>តូច ឬកងវរសេនាធំ<របស់លោក>ជាដើមហ្នឹង តើពួកគាត់ទំនាក់ទំនងជាមួយលោកតាមរបៀបណា<នៅពេលកំពុងប្រយុទ្ធនៅសមរភូមិនោះ>? តើពួកគេមានប្រើនីរសារ ឬក៏គេប្រើវិទ្យុទាក់ទងអីដែរ?

**ឆ៖** ដូច្នេះទី -- ខ្ញុំសូមបញ្ជាក់ ទីបញ្ជាការកងទ័ពគឺនៅជាប់នឹងសមរភូមិហ្នឹង ប្រហែលជាដី ១០០ម៉ែត្រ ២០០ម៉ែត្រពីគ្នា ដូច្នេះមាននីរសារ។ ដូច្នេះនីរសារ ដូចខ្ញុំ នីរសារខ្ញុំឱ្យទៅហៅវរសេនាធំប្រធានៗគេមកជួបជុំហើយ ប៉ុណ្ណឹងទេ។ ដូច្នេះទៅវិញ គេហៅគ្នាគេធ្វើការតាមរយៈហ្នឹងទេ។ ដូច្នេះគ្មានតេ.អូ គ្មានទូរស័ព្ទអីទាក់ទងទេ។ ដូច្នេះទាក់ទងតាមនីរសារ តាមរយៈមនុស្ស។

**ស៖** សូមអរគុណ ឥឡូវខ្ញុំច្បាស់ហើយ។ ខ្ញុំសូមបន្តទៅលើហេតុការណ៍មួយចំនួនក្នុងពេលដែលលោកនៅភូមិភាគបស្ចិម<នៅក្នុងកងពលលេខ១>។ ព្រឹកនេះលោកបាននិយាយអំពីការប្រជុំខែមិថុនា ៧៨ ហើយលោកបានរៀបរាប់អំពី ប៉ុល ពត ដែលនិយាយអំពីបញ្ហា<រៀបការ ក្នុងចំណោមបញ្ហា>ជាច្រើន។ តើកិច្ចប្រជុំខែមិថុនា ៧៨ នោះ តើជាសមាជប្រចាំឆ្នាំរបស់ភូមិភាគបស្ចិម ឬមួយក៏វាជាកិច្ចប្រជុំអ្វីដែរ?

**ឆ៖** ដូចខ្ញុំបញ្ជាក់ពីដើមហើយថា ក្នុងនាមខ្ញុំកងទ័ព ដូច្នេះមិនមែនជាអ្នកចូលរួមក្នុងកម្មវិធីអង្គប្រជុំទេ តែគ្រាន់គេហៅទៅសង្កេតការណ៍គឺចាំស្តាប់។ ដូច្នេះការ អានេះមិនដឹងជាផែនការប្រជុំប្រចាំឆ្នាំ ឬប្រចាំអីទេ តែគ្រាន់តែពេលហ្នឹង គេប្រជុំគេលើកឡើងដូចខ្ញុំលើកឡើងទៅ ទិសដែល ប៉ុល ពត លើកក្នុងសាលាហ្នឹង គឺមានពីរជាសំខាន់។ ទី១គឺ កិច្ចការពារប្រទេស, ទី២ និងការកសាងប្រទេស។ នេះគឺគេលើកឡើងបញ្ហាប៉ុណ្ណឹង។ តែត្រង់ថា ការប្រជុំនេះវាជា បណ្តាច់ឆ្នាំ ឬក៏យ៉ាងម៉េច អាហ្នឹងខ្ញុំក្តាប់អត់បាន

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ដែរ។

[១៤:០៥:៥១]

**ស៖** នៅក្នុងសំណួរចម្លើយ៤០នៃកិច្ចសម្ភាសន៍ឆ្នាំ២០១៥ គឺE3/10713 <គេបានសួរលោកថា ៖ “ទាក់ទងនឹង>កិច្ចប្រជុំ<ដែលលោកចូលរួម>នៅកំពង់ឆ្នាំង ថាតើគេធ្វើជាទៀងទាត់ឬក៏អត់? លោកឆ្លើយថា៖ ការប្រជុំរបៀបហ្នឹងគឺគេធ្វើមួយឆ្នាំម្តង។” លោកសាក្សី ក្នុងនាមលោកជាកងវរសេនាធំ <មួយនៅភូមិភាគបស្ចិម> ថាតើលោក<មិន>បានដឹង<>ទេ<ឬ> អំពីការប្រជុំដែលគេធ្វើមានទាំងស៊ីវិល មានទាំងទាហានចូលរួមប្រជុំនោះ?

**ឆ៖** ពេលនោះគេធ្វើអ៊ីចឹងមែន ជួនកាលក៏ពេលខ្លះ ខាងយោធាជាប់ការងារបេសកកម្មនោះ គេអត់ហៅទេ គេធ្វើតែស៊ីវិលទៅក៏មាន ឬក៏ហៅនេះផ្សេង អាហ្នឹងវាអត់ទៀតទាត់ដែរ។ ខាងកងទ័ពអត់មានត្រូវការចាំបាច់ទេ បើត្រូវហៅប្រជុំក៏ហៅ មិនហៅក៏អត់ ក៏បាន ព្រោះការងារនេះ ការងាររបស់ខាងរដ្ឋបាល មិនមែនខាងការងារយោធាទេ។

**ស៖** តើដោយសារមានបេសកកម្ម ឬក៏មានអ្វីទើបលោកមិនចូលរួមប្រជុំនោះ? ព្រោះថាតាមសក្ខីកម្មម្សិលមិញគឺថា រហូតទៅដល់ខែមិថុនា ៧៨ ទើបលោកចូលសមរភូមិ ព្រោះមុនហ្នឹងគឺលោកនៅតែធ្វើស្រែទេ ប៉ុន្តែខ្ញុំចង់ដឹងថាតើមូលហេតុអ្វី ឬក៏មានហេតុផលអ្វីទើបលោកអាចថា អាចគេចមិនចូលរួមការប្រជុំប្រចាំឆ្នាំនោះបាន?

**ឆ៖** អត់មានគេចទេ គេអត់ហៅ គេអត់ប្រាប់។ ទាល់តែគេប្រាប់បានទៅ បើគេអត់ប្រាប់ អត់ទៅ ដឹងទៅម៉េច បើនេះ -- ធ្វើការគឺអ៊ីចឹង។

[១៤:០៨:១៥]

**ស៖** ឥឡូវនេះខ្ញុំសូមអាននូវសម្រង់មួយទៀត នូវកំណត់ហេតុស្តាប់ចម្លើយរបស់បុរសម្នាក់ដែលខ្ញុំបានបញ្ជាក់គឺ មាស វឿន ដែលជាមេបញ្ជាការកង<វរសេនាធំលេខ>១៦ <នៅក្នុងកងពលរបស់លោក គឺកងពលលេខ១របស់ភូមិភាគបស្ចិម> ហើយនិង<ជា>អនុបញ្ជាការ<កងពល>។ នៅក្នុងកិច្ចសម្ភាសន៍របស់គាត់ E3/80 <នៅចម្លើយទី១៤> គឺគាត់បាននិយាយថា៖ “ខ្ញុំបានចូលរួមការប្រជុំនៅ<ភូមិភាគ>បស្ចិមនៅខេត្តកំពង់ស្ពឺ ធ្វើនៅចម្ការដូង នៅក្នុងស្រុកច្បាររមន ឆ្នាំ៧៧។ ប៉ុន្តែខ្ញុំមិនចាំអំពីកាលបរិច្ឆេទច្បាស់លាស់នោះទេ។ អ្នកចូលរួមគឺរួមមាន<គណៈ>ភូមិភាគ <គណៈ>ស្រុក <គណៈ>តំបន់ ហើយនិងប្រធាន អនុប្រធានកងពល កងវរសេនាធំនៅភូមិភាគបស្ចិម។” សូមបញ្ចប់ការដក

01376906


ស្រង់។ តើលោកចាំអំពីការប្រជុំនៅចម្ការដូងនៅក្នុងស្រុកច្បារមនទេ?

**ធ៖** ខ្ញុំអត់ដែលទៅប្រជុំនៅហ្នឹងផង។

**ស៖** តើលោកដឹងថា នៅចម្ការដូង នៅស្រុកច្បារមនហ្នឹងមានមន្ទីរអ្វីដែរ?

**ធ៖** បើលោកសួរអ៊ីចឹង គឺច្បាស់ ខ្ញុំកាន់តែរឹតអត់ដឹងទៀត អត់ស្គាល់ទៀតហើយ មិនដឹងជាមានមន្ទីរអី។ ដូចខ្ញុំបញ្ជាក់អ៊ីចឹង ព្រោះការងាររបស់គេធ្វើ អ្នកណាធ្វើអ្នកហ្នឹងដឹង គឺក្រៅពីហ្នឹងគឺអត់មានដឹងទេ។ បើថាកងទ័ពដឹងថានៅសមរភូមិមុខ ដឹងតែបាញ់ ហើយវ៉ៃតែហ្នឹងទេ។ ឯការងារមន្ទីរអីៗផ្សេងៗ គឺកងទ័ពអត់មានដឹងទេ អត់មានដឹង មានឮអីទេ។ ហ្នឹងសូមបញ្ជាក់អ៊ីចឹង។

[១៤:១០:២៨]

**ស៖** ឥឡូវនេះគឺយើងនិយាយអំពីសមាជភូមិភាគមុនពេលដែល<គេ>បញ្ជូន<លោក>ទៅសមរភូមិ គឺមុនពេលខែមិថុនា ៧៨ គឺថា ក្នុងរយៈពេលដែលលោកនិយាយថាលោកនៅធ្វើស្រែនោះ។ ដូច្នេះលោកនិយាយអំពីវគ្គអប់រំនយោបាយដែលលោកបានទៅចូលរួម។ <នៅក្នុងតុលាការនេះ យើងបានស្ដាប់>ឮសួរកម្មាភិបាលដទៃនិយាយអំពីវគ្គ<រៀនសូត្រ>នយោបាយប្រចាំឆ្នាំ។ ដូច្នេះខ្ញុំចង់សួរ ថាតើលោកធ្លាប់ចូលវគ្គអប់រំនយោបាយប្រចាំឆ្នាំដែរឬទេ? ហើយប្រសិនបើលោកធ្លាប់ចូល តើវគ្គរៀនសូត្រនយោបាយហ្នឹងគេធ្វើនៅកន្លែងណាដែរ?

**ធ៖** ខ្ញុំសូមបញ្ជាក់វគ្គដែលធ្វើៗស្រែ ធ្វើអីហ្នឹង អាហ្នឹងវាធ្វើពីធម្មតាអ៊ីចឹងហើយ ប៉ុន្តែដែលខ្ញុំមិនបានចូលរួមក្នុងនេះហ្នឹង គឺខ្ញុំរវល់ស្រែអ៊ីចឹងទៅ។ ហេតុដូច្នេះហើយក៏ពេលខ្លះគេ ៗត្រូវហៅ គេហៅគេមិនហៅ អត់ហៅ។ ដូច្នេះអត់មានដែលបានចូលរៀននៅតាមនយោបាយណាទេ ខាងលើគឺដែលមានត្រឹមកងពលហៅមកបញ្ជាក់ពីការងារបច្ចេកទេសហ្នឹង ការងារធ្វើដើម្បីចិញ្ចឹមជីវិត -- ដើម្បីជីវភាពធ្វើស្រែធ្វើចម្ការហ្នឹងគឺមានបញ្ជាក់អ៊ីចឹង។ ហើយគ្រាន់ថាកងទ័ពប្រយ័ត្នយើង ប៉ុន្តែឲ្យប្រយ័ត្នប្រយែង។ គ្រាន់តែប្រាប់តែប៉ុណ្ណឹងអត់មានអីទេ។

**ស៖** ឥឡូវនេះខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិច អំពីកំណត់ហេតុស្ដាប់ចម្លើយ<របស់លោក>នៅខែកញ្ញា ២០១៥ គឺ E3/10713។ សំណួរ-ចម្លើយ៦២ លោកបានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ខ្ញុំជាមេបញ្ជាការកងវរសេនាធំ ដូច្នេះខ្ញុំធ្វើការនៅក្រោមកងពលដែលមាន តាសឿង ជាមេបញ្ជាការ។ ដូច្នេះរាល់ការប្រជុំនិងការរៀនសូត្រ គឺ តាសឿង ជាអ្នកទទួលខុសត្រូវ។ ប៉ុន្តែពេលខ្លះខ្ញុំឃើញមានម្នាក់ទៀតដែលតែងមកមើលការរៀនសូត្រ និងការប្រជុំយូរៗម្ដងដែរ គាត់មានឈ្មោះថា តាម៉ុក។" ខ្ញុំចង់ដឹង

ថាតើការប្រជុំ ឬក៏ការរៀនសូត្រដែលលោកនិយាយហ្នឹង តើសំដៅលើការប្រជុំ ឬក៏ការរៀនសូត្រអ្វីដែរ?

[១៤:១២:៥៦]

**ឆ៖** ពេលដែលខ្ញុំនិយាយហ្នឹង គឺការប្រជុំរៀនសូត្រហ្នឹងគឺ ជួបជុំគ្នាឲ្យកងទ័ពចេះគ្រប់គ្រងកម្លាំង ចេះការពារកម្លាំង ចេះមើលថែទាំយុទ្ធជនរបស់ផងខ្លួន។ ពេលខ្លួនឈឺអី ត្រូវយកទៅពេទ្យអីហ្នឹងគឺ ហើយអ៊ីចឹងហើយ និងមើលការហូបចុកឲ្យបានឆ្អែត បានសមរម្យ គឺមានការនិយាយអ៊ីចឹង។

**ស៖** តើការរៀនសូត្រដែលដឹកនាំឲ្យ តាសឿង ហើយនិងពេលខ្លះម្តងម្កាលដោយ តាម៉ុក ហ្នឹងគេធ្វើឡើងនៅកន្លែងណាដែរ?

**ឆ៖** រឿង អារឿងធ្វើនៅតាមកន្លែងហ្នឹងខ្ញុំចាំអត់បានទេ ភ្លេចហើយ។ បើធ្វើនៅ -- បើពិនិត្យទៅធ្វើមិនដឹងធ្វើនៅកន្លែងណាផង អត់មានអីកន្លែងច្បាស់លាស់ទេ។

**ស៖** តើ តាម៉ុក គាត់មកធ្វើអ្វីដែរនៅពេលដែលគាត់មកចូលរួមការប្រជុំ ឬក៏ការរៀនសូត្រនេះ?

**ឆ៖** តាមទម្លាប់ តាម៉ុក មកអត់មានប្រជុំទេ គ្រាន់តែសួរថាម៉េចកងទ័ពហ្នឹងសុខសប្បាយទេអ្វីហូបចុកវាម៉េចដែរ គ្រាន់តែសួរតែប៉ុណ្ណឹង អត់មានធ្វើអី អត់មានអីមករៀនសូត្រអីច្រើនទេ តាម៉ុក។

**ស៖** តើលោកដឹងថា អ្នកដែលមកហ្នឹងជា តាម៉ុក ដឹងដោយរបៀបណា?

**ឆ៖** បើឮៗគេហៅថា តាម៉ុក ហ្នឹងហើយ បើគេហៅថា តាម៉ុកៗ ហ្នឹងហើយ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងនិយាយបញ្ជាក់លម្អិតអំពីការប្រជុំខែមិថុនា ៧៨ ដែលនៅក្នុងការប្រជុំហ្នឹង ប៉ុល ពត បានថ្លែង។ នៅព្រឹកមិញនេះ លោកបានប្រាប់មេធាវី ខៀវ សំផន ថាលោកចូលរួមតែថ្ងៃទី១ប៉ុណ្ណោះនៅក្នុងការប្រជុំនោះ បន្ទាប់មកទៀតគឺគេបញ្ជូនលោកទៅស្វាយរៀង។ ប៉ុន្តែលោកនិយាយផ្សេងពីនេះ នៅក្នុងការសម្ភាសរបស់លោក។ ដូច្នេះខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិច អំពីចំណុចនេះ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយឆ្នាំ២០១៥របស់លោក គឺខ្ញុំអានអំពីសំណួរចម្លើយ៦០ ដល់៦១ នៃឯកសារ E3/10713។ លោកបានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ខ្ញុំប្រជុំតែ២ ឬ៣ថ្ងៃប៉ុណ្ណោះ។" ហើយបន្ទាប់មកទៀត អ្នកស៊ើបអង្កេតគឺគាត់សួរ៖ "ព្រឹកមិញលោកនិយាយថា លោកប្រជុំបានតែ១ថ្ងៃទេឥឡូវនេះម៉េចបានលោកនិយាយថា២ ឬ៣ថ្ងៃ? ឆ្លើយ៖ សូមបញ្ជាក់ថា ពេលនោះខ្ញុំបានចូលរួមប្រជុំបាន៣ថ្ងៃ។" ខ្ញុំដឹងថាវាជារឿងកើតឡើងយូរមកហើយ ប៉ុន្តែតើលោកអាចបញ្ជាក់បានទេ ថាតើនៅក្នុងការប្រជុំជាមួយ ប៉ុល ពត ហ្នឹងលោកចូល១ថ្ងៃ ឬក៏ចូល៣ថ្ងៃ ឬក៏លោកមិនច្បាស់ថា លោកចូលបានប៉ុន្មាន

ថ្ងៃនោះទេ?

[១៤:១៧:០៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់ គឺពេលដែលប្រជុំហ្នឹង គឺការងារចាំបាច់ខ្ញុំ ក៏មិនចាំច្បាស់ដែរ យ៉ាងៗយូរបានប្រហែល២ថ្ងៃអីប៉ុណ្ណឹងទេ គឺមិនដល់៣ទេ គឺប្រជុំហ្នឹងបានតែប៉ុណ្ណឹង ដូច្នេះផែនការទៅ គឺខ្ញុំចេញទៅប្រមូលទ័ពខ្ញុំទៅ។ ហ្នឹងគឺមានប៉ុណ្ណឹង អស់ត្រឹម២ថ្ងៃអីហ្នឹង ព្រោះខ្ញុំភ្លេចភ្លាំងដែរ អាហ្នឹងពីរបីថ្ងៃអាហ្នឹងវាធម្មតាទេ លើសខ្វះខ្លះ។

**ស៖** ក្នុងពេល១ថ្ងៃ ឬក៏២ថ្ងៃដែលលោកចូលរួមក្នុងកិច្ចប្រជុំខែមិថុនា ៧៨នោះ តើមានអ្នកថ្លែងសុន្ទរកថាផ្សេងទៀត ក្រៅពី ប៉ុល ពត ឬមួយក៏មានតែ ប៉ុល ពត ទេដែលមកថ្លែងនៅក្នុងកិច្ចប្រជុំ១ថ្ងៃ ឬក៏២ថ្ងៃ ដែលលោកបានចូលរួមនោះ?

**ឆ៖** ក្នុងពេល១ថ្ងៃ, ២ថ្ងៃដែលខ្ញុំបានចូលរួមនោះ គឺឃើញមានតែ ប៉ុល ពត ហ្នឹងទេដែលមកថ្លែងសុន្ទរកថា។

**ស៖** ជាតាមការប្រមាណមើល ថាតើមានមនុស្សប្រហែលជាប៉ុន្មាននាក់ដែរ បានចូលរួមនៅក្នុងការប្រជុំនុំង? ហើយតើពួកគាត់ហ្នឹងជាអ្នកណាដែរ មកពីណាដែរ?

[១៤:១៨:៣១]

**ឆ៖** ខ្ញុំឃើញក្នុងការប្រជុំនោះ ឃើញមានមនុស្សច្រើនដែរ ប្រហែលជារាប់រយ តែវាមិនដល់ប៉ុន្មាន ដូច្នេះមិនដឹងជាមកពីខាងណាអីខាងណា ដូចខ្ញុំៗបញ្ជាក់ខាងដើមអ៊ីចឹងថា ខ្ញុំក្នុងនាមខ្ញុំជាយោធាខ្ញុំគេហៅទៅ គ្រាន់តែសង្កេតការក្តាប់ទេ ដូច្នេះមិនមានសារៈសំខាន់អីនៅក្នុងអង្គប្រជុំនុំងទេ ដូច្នេះគ្រាន់តែទៅឲ្យយល់ពីបញ្ហាដែលគេប្រជុំហ្នឹង គេនិយាយពីរឿងអី គ្រាន់តែគេទៅប្រាប់ប៉ុណ្ណឹងទេ។ ដូច្នេះឲ្យបានន័យ យល់ន័យជ្រៅជ្រះអី អត់មានអីទេ ហ្នឹងគឺអត់ច្បាស់លាស់ទេ ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់អ៊ីចឹង។

**ស៖** លោកនិយាយអំពីអ្នកចូលរួមសំខាន់ ប៉ុន្តែតើលោកចង់សំដៅអ្នកចូលរួមសំខាន់ហ្នឹង គឺ <លោកសំដៅទៅលើប្រជា>ជន<ផ្នែកខាង>ស៊ីវិល <គឺប្រជាជនមកពីគណៈស្រុក និងគណៈឃុំមែនទេ>?

**ឆ៖** អ្នកដែលមនុស្សសំខាន់ដែលខ្ញុំនិយាយហ្នឹង គឺមានតែ តែខ្ញុំអត់មាន អត់ស្គាល់គេទេ ប៉ុន្តែគ្រាន់តែក្នុងឋានៈជាអ្នកដឹកនាំមូលដ្ឋានហ្នឹង ភូមិ ឃុំ ស្រុក ខេត្តអីហ្នឹង មានតែមនុស្ស មានមនុស្សអ៊ីចឹងដែលមកចូលរួមប្រជុំនុំង។

**ស៖** យើងបាននិយាយអំពីការដែល ប៉ុល ពត បញ្ជានៅក្នុងការប្រជុំហ្នឹង ទាក់នឹងការរៀបការ។ ឥឡូវនេះខ្ញុំចង់សួរលោកជាទូទៅអំពីការរៀបការ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាំងមុនពេល និងក្រោយពេលប្រជុំជាមួយ ប៉ុល ពត នុំង តើប្រជាជនអាចរៀបការតាមបែបប្រពៃណីបានទេ? ហើយថាតើគេអនុញ្ញាតឲ្យមានការរៀបការតាមប្រពៃណី និងមានការរៀបការតាមជំនឿសាសនាអីបានទេ?

**ឆ៖** ហ្នឹងខ្ញុំសូមបញ្ជាក់ គឺបញ្ហាការកសាងគ្រួសារ គឺដែលតាមខ្ញុំដឹង គឺអត់ដែលឃើញគេធ្វើតាមរបៀបទម្លាប់ ប្រពៃណីទំនៀមទម្លាប់ទេ គឺធ្វើតាមរបៀបដូចខ្ញុំបានបញ្ជាក់ពីព្រឹកអ៊ីចឹង។ ជួបជុំគ្នាហើយរៀបចំទៅ តាមការស្នើការអីហ្នឹង អ៊ីចឹងទេ ដូច្នេះមិនមាន--។

[១៤:២១:១៦]

**ស៖** ឥឡូវនេះខ្ញុំនឹងអាននូវចម្លើយឆ្នាំ២០១៥ E3/10713 គឺនៅសំណួរចម្លើយ<៣៧> គឺលោកនិយាយអំពីការប្រជុំជាមួយ ប៉ុល ពត។ “តាមដែលខ្ញុំចាំនៅក្នុងការប្រជុំ ប៉ុល ពត មិនបានបញ្ជាក់ថា ការរៀបការតាមប្រពៃណីត្រូវហាមឃាត់នោះឡើយ គឺគេឲ្យប្ដីប្រពន្ធមក<ចាប់ដៃ>គ្នា ហើយ<បន្ទាប់មកការរៀបការបាន>បញ្ចប់។ <ប៉ុល ពត មិនបាននិយាយអំពីការរៀបការច្រើនគូនោះទេ។>” ហើយបន្តមកសំណួរចម្លើយ៣៨, ៣៩ គឺសំណួរ<>៖ “តើគេមានដែលចេញបញ្ជាប្រាប់លោកថា ឲ្យឈប់ធ្វើពិធីបែរបន់ ឬពិធីសាសនាទេ? អត់មានទេ។ សំណួរ៖ ចុះហេតុអ្វីបានជាគេឈប់ធ្វើពិធីសាសនានៅសម័យនោះ? ឆ្លើយ៖ មកពីអត់មានវត្ត និងលោកសង្ឃ។” ខ្ញុំសូមបញ្ចប់ការដកស្រង់។ លោកសាក្សី ថាហេតុអ្វីបានជានៅពេលនោះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះអត់មានលោក និងអត់មានវត្តនោះ?

**ឆ៖** ខ្ញុំឆ្លើយបញ្ហានេះ អត់ ព្រោះខ្ញុំអត់ដឹងដែរ អត់យល់ដែរ ព្រោះខ្ញុំអ្នកតូចតាច មិនមែនអ្នកដឹកនាំប្រទេសដែលយល់បញ្ហាហ្នឹង ដឹងគោលនយោបាយរបស់គេដឹកនាំរៀបចំយ៉ាងម៉េច។ នេះខ្ញុំឆ្លើយអត់បាន។ គ្រាន់តែខ្ញុំធ្វើៗតាមគេទៅ។

[១៤:២៣:០៨]

**ស៖** ឥឡូវនេះខ្ញុំសូមអាននូវសក្ខីកម្មរបស់បុគ្គលដទៃទៀត ដែលនៅក្នុងកងទ័ពដែរនោះ គឺបុគ្គលម្នាក់ដែលលោកហៅថា ជាអនុបញ្ជាការវរសេនាធំ២២១ ដែលត្រូវបានបញ្ជូនពីនិរតីក្នុងពេលជាមួយគ្នាដែលលោកត្រូវបានគេបញ្ជូនទៅស្វាយរៀង គឺឯកសារ E3/428។ ខ្មែរមានលេខ 00373488, អង់គ្លេសមានលេខ 00374952 និងបារាំងមានលេខ 00485479។ នេះគឺជាអ្វីដែលគាត់ឆ្លើយ៖ “នៅ

ពេលដែលខ្ញុំចាប់ផ្តើមចូលរួមនៅក្នុងចលនាខ្មែរក្រហម នៅក្នុងដើមឆ្នាំ៧០ ពួកគេបង្រៀនខ្ញុំអំពីទ្រឹស្តីកុម្មុយនីស្ត ដែលនិយាយថា គ្មានប្រយោជន៍ដែលសម្រាប់ព្រះពុទ្ធសាសនា និងការធ្វើឱ្យប្រទេសជាតិរីកចម្រើននោះឡើយ។ ដូច្នេះហើយត្រូវតែលុបបំបាត់ចោល។ នៅពេលនោះ សៀវភៅត្រូវបានគេបោះពុម្ពហើយចែកចាយ <អំពីខ្លឹមសារនៃការលុបបំបាត់សាសនានោះ>។ ហើយក្រោយមកទៀត ខ្ញុំឃើញថា មិនមានវត្ត ហើយព្រះសង្ឃទាំងអស់ត្រូវបានគេផ្សឹក ឬក៏បង្ខំឱ្យចាកចេញពីជីវិតជាព្រះសង្ឃ។" តើលោកមានទទួលបានការបណ្តុះបណ្តាលនយោបាយប្រហែលគ្នាហ្នឹង ក្រោយពេលដែលលោកចូលបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ គឺទាក់ទងទៅនឹងការលុបបំបាត់ចោលសាសនានោះ?

**ឆ៖** ក្រោយពេលដែលខ្ញុំចូល និងធ្វើក្នុងចលនាធ្វើកងទ័ពហ្នឹង ដូច្នេះខាងអង្គភាពខ្ញុំ អត់ដែលឮនិយាយពីរឿងបិទសាសនា ឬក៏បើកសាសនាអីទេ អត់មាននិយាយទេ។ គឺនិយាយតែគិតគូរ តែនាំគ្នា រួមគ្នាការពារទឹកដីប៉ុណ្ណឹង ហើយនិងកាលនោះ យើងនិយាយមកថាធ្វើម៉េង ដង្ហែឱ្យសម្តេចឪហ្នឹងវិលមកស្រុកទេសវិញ។ អាហ្នឹង កាលនុ៎ងគឺមាននិយាយប៉ុណ្ណឹង។ ឯរឿងបិទវត្ត បិទវ៉ាអី អាហ្នឹងខ្ញុំអត់បានឮដែរ អត់ដែលទទួលដែរ។

[១៤:២៥:៣១]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងអន្តរជាតិ នៅមានការបែងចែកពេលវេលាជាមួយនឹងក្រុមសហមេធាវីនាំមុខយ៉ាងម៉េចដែរ ក្នុងការសួរដេញដោលសាក្សីរូបនេះ?

**លោក ខេល លីសាក់៖**

បាទ លោកប្រធាន គឺថាខ្ញុំដឹងថា នឹងទទួលបានកន្លះម៉ោង រហូតទៅដល់វគ្គ -- កន្លះម៉ោងនៃវគ្គ <បន្ទាប់>។ ដូច្នេះខ្ញុំគិតថា ខាងដើមបណ្តឹងរដ្ឋប្បវេណី គាត់អាចត្រូវការពេល១៥ ឬក៏២០នាទី។

**ប្រធានអង្គជំនុំ៖**

លោកអាចច្រឡំហើយ យើងបានថែមជួសជុលរួចហើយ។ ៥នាទី និង១០នាទី នៅពេលរហូតដល់ម៉ោងដប់មួយ សែសិបនាទី។ លោកគិតឡើងវិញ អត់មែនទេណា។ លោកអាចមានត្រឹមតែអស់អស់វគ្គនេះប៉ុណ្ណោះ។

**លោក ខេល លីសាក់៖**

សូមអរគុណសម្រាប់ការបញ្ជាក់បំភ្លឺ។ មេធាវីដើមបណ្តឹងបានបញ្ជាក់ថា គាត់អត់មានសំណួរទេ

ដូច្នេះខ្ញុំអាចប្រើប្រាស់ពេលវេលា<នៅសល់>។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកអំពីឯកសារដែលជាភស្តុតាងនៅក្នុងសំណុំរឿងនេះ គឺជារបាយការណ៍ពីខាង<បស្ចិម>។ គឺទាក់ទងទៅនឹងប្រធានបទដែលយើងបានពិភាក្សា។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់នូវឯកសារជូនដល់សាក្សី គឺឯកសារ E3/1094។ សូមលោកប្រធានអនុញ្ញាត។

[១៤:២៧:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំដឹងថា នេះគឺជារបាយការណ៍បញ្ជូនពីខាងបស្ចិម<ផ្ញើជូនអង្គការ> គឺជារបាយការណ៍<ប្រចាំ> ខែកក្កដា ហើយខ្ញុំដឹងថា លោកមិនដែលឃើញរបាយការណ៍នេះទេ ប៉ុន្តែខ្ញុំគិតថា លោកអាចនឹងដឹងអំពីចំណុចមួយចំនួន។ ឥឡូវនេះខ្ញុំចង់ឲ្យលោកមើលផ្នែក៤.១ នៃរបាយការណ៍នេះ។ ខ្ញុំសូមផ្តល់លេខ ERN ជូនអស់លោកទាំងអស់គ្នា។ លេខ ERN សម្រាប់ផ្នែក៤.១ នេះគឺខ្មែរមានលេខ 00143 611 ដល់12, អង់គ្លេសមានលេខ 00315376 និងបារាំងមានលេខ 00593532។ អ្វីដែលខ្ញុំចង់សួរលោក គឺការនិយាយនៅក្នុងពាក់កណ្តាលកថាខណ្ឌទី២ ដែលគេនិយាយអំពីការអប់រំដែលបង្រៀនដល់កម្មាភិបាលមកពីគ្រប់ផ្នែកទាំងអស់។ គេនិយាយអំពីឯកសារដែលបក្សបានប្រើប្រាស់ដើម្បីបង្រៀនយើងនៅក្នុងខែមិថុនា នៅក្នុង<ឆមាសទី១> ឆ្នាំ៧៨។ នៅពេលដែលគេនិយាយអំពីការប្រជុំរៀនសូត្រ ខែមិថុនា ឆ្នាំ៧៨ហ្នឹង តើវាជាការប្រជុំតែមួយ ជាមួយនឹងការប្រជុំដែលលោកចូលរួម ដែលថាលោកបានចូលរួមតែពីរថ្ងៃដំបូងហ្នឹង មែនទេ?

**លោក ជួន ធី៖**

**ឆ៖** ខ្លឹមសារទាំងអស់ដែលចូលនេះហ្នឹង ដូច្នេះការប្រជុំនេះ គឺខ្ញុំមិនទាន់បានក្តាប់ដល់ហ្នឹងទេ តែដឹងមាន ឬមិនមានទេ តែខ្ញុំចូលបានតែ២ថ្ងៃខ្ញុំចេញទៅ។ ដូច្នេះវាមិនដឹងជាគេមានបញ្ហាប្រជុំខ្លឹមសារយ៉ាងម៉េចទៀត អាហ្នឹងខ្ញុំអត់ដឹង។ ខ្ញុំក្តាប់អត់បាន។

[១៤:៣០:២១]

**ស៖** សូមលោកបើកទៅទំព័រចុងក្រោយ គឺនៅខាងក្រោយ មានលេខរៀងពាក់ព័ន្ធទៅនឹងព័ត៌-

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានដែលបានរាយការណ៍។ នេះគឺទំព័រចុងក្រោយបំផុតនៃឯកសារ ដែលបានប្រគល់ឲ្យលោកមើលនេះ។ លោកនឹងឃើញតារាងមួយពាក់ព័ន្ធទៅនឹង <“កើត> ស្លាប់ ហើយនិង<>រៀបការ។” នៅត្រង់ទំព័រចុងក្រោយបំផុត។ នៅក្នុងរបាយការណ៍ចេញពីមកពីភូមិភាគបស្ចិមនេះ មានតារាងនិយាយអំពី <ចំនួនកើត និង>ចំនួនគូស្រករដែលបានរៀបការ។ សំណួររបស់ខ្ញុំ តើអង្គភាពរបស់លោក គេតម្រូវឲ្យរាយការណ៍មកថ្នាក់លើអំពីចំនួនគូស្រករដែលបានរៀបការនោះដែរទេ?

**ឆ៖** ខ្ញុំ អង្គភាពដែលរៀងចំ ដែលឲ្យហើយ ដូចខ្ញុំបញ្ជាក់អ៊ីចឹង គឺមុននឹងរៀបចំការឲ្យហើយហ្នឹង គឺដូច្នេះស្នើខាងលើរួចបាត់ទៅហើយ។ ដូច្នេះដល់រៀបចំហើយ អត់មានអីរាយការណ៍ទៀតទេ គឺរៀបចំរួចហើយ ស្នើរួចហើយ ប្រាប់រួចហើយ។

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោក ខែកញ្ញា ឆ្នាំ២០១៥ គឺឯកសារ E3/10713 ត្រង់ចម្លើយលេខ៣០ គេបានសួរដូចតទៅ “សួរ៖ តើគេអាចបង្កើនចំនួនប្រជាពលរដ្ឋបានដោយរបៀបណា បើមិនមានគោលនយោបាយច្បាស់លាស់? ឆ្លើយ៖ ឧទាហរណ៍នៅក្នុងអង្គភាពរបស់ខ្ញុំ ខ្ញុំត្រូវរាយការណ៍អំពីគូស្រករ ដែលរៀបការទៅថ្នាក់លើ។ អង្គភាពដទៃទៀតក៏ត្រូវរាយការណ៍ដូចគ្នានេះដែរ។” តើលោករាយ-ការណ៍អ្វីខ្លះអំពីគូស្រករដែលបានរៀបការក្នុងខែនីមួយៗ?

[១៤:៣២:៤៨]

**ឆ៖** ខ្ញុំសូមបញ្ជាក់ ក្នុងការរាយការណ៍ហ្នឹង ដូចខ្ញុំបញ្ជាក់អំមិញអ៊ីចឹងថា មុននឹងការគឺត្រូវសាមីខ្លួនហ្នឹង គឺខាងយើងណេះត្រូវធ្វើថាប៉ុន្មានគូ ប៉ុន្មានគូហ្នឹងស្នើទៅខាងលើរួចទៅហើយ។ ដល់ពេលដែលយើងរៀបចំការឲ្យហើយនេះ ដូច្នេះយើងអត់មានប្រាប់អីទៅទៀតទេ ព្រោះបានយើងប្រាប់រួចទៅហើយ អត់មានប្រាប់អីទៀតទេ។ នេះខ្ញុំសូមបញ្ជាក់អ៊ីចឹង។

**ស៖** សូមលោកចូលទៅឯកសារដដែលហ្នឹង ខ្ញុំដាក់*ហាយឡាយ*ឲ្យលោកមើលដែរ គឺនេះគឺឯកសារដដែល E3/1094 បាទសូមមើលឯកសារ E3/1094។ មុនចូលទៅឯកសារនេះ ត្រង់ចំណុចរបាយការណ៍នេះ សូមលោកមើលទំព័រទី១នៃរបាយការណ៍សិន គឺដែលមានលេខរៀងដាក់ថា១.២ ផ្នែកមួយគេដាក់ចំណងជើងថា១.២ មានចំណងជើងថា “សកម្មភាពខ្មាំងស៊ីរូងផ្ទៃក្នុង”។ ហើយលេខយោងជាក់លាក់ត្រង់កថាខណ្ឌទី១ គឺដាក់ថា “បោសសម្អាតអង្គភាពកងទ័ពផ្សេងៗ រួមទាំងសមាសធាតុពួក ១៧មេសា និងអតីតមន្ត្រីរដ្ឋការ រួមទាំងចិននិងយួនផងដែរ។” ហើយនៅកថាខណ្ឌបន្ទាប់ សូមដកស្រង់ “យើងមានផែនការដើម្បីអនុវត្តមាគ៌ារបស់បក្សដើម្បីបោសសម្អាតពួកទាំងអស់នេះឲ្យបានជ្រះស្រឡះ”

បញ្ចប់ការដកស្រង់។ នៅក្នុងអង្គប្រជុំខែ<មិថុនា> ៧៨ ដែលលោកបានប្រជុំហ្នឹង តើមាននៅអង្គប្រជុំហ្នឹងមាននិយាយគ្នាអំពីខ្មាំងរបស់របបខ្លួនដែរឬទេ?

**ឆ៖** កាលដែលប្រជុំនៅកំពង់ឆ្នាំងនុ៎ង ដែលខ្ញុំទៅស្វាយរៀងហ្នឹង ដូចដែលខ្ញុំបានបញ្ជាក់ហើយថា ខ្ញុំធ្វើការបានតែពីរថ្ងៃទេ ដូច្នេះ ហើយខ្ញុំរៀបចំកម្លាំងទៅមុខទៅ ដូច្នេះនៅខាងក្រោយត្រង់ខ្ញុំភ្លាប់មិនបានទេ ត្រង់គេរៀប គេរៀនសូត្រ ឬក៏គេពន្យល់អំពីផែនការខ្មាំងស៊ីរូងបង្កប់អី អាហ្នឹងខ្ញុំភ្លាប់អត់បានដែរ ព្រោះខ្ញុំទៅផុតហើយ អត់មាននេះ។

**ស៖** ខ្ញុំសួរលោកអំពីអង្គប្រជុំដែលលោកបានចូលរួម ហើយ ប៉ុល ពត ជាអ្នកឡើងនិយាយ គឺអង្គប្រជុំរយៈពេល១ថ្ងៃ ឬ២ថ្ងៃនោះឯង។

[១៤:៣៦:១៤]

**ឆ៖** ហ្នឹងខ្ញុំបញ្ជាក់ហើយថា ពេលនោះដែលនិយាយ ដែលខ្ញុំចូលរួម២ថ្ងៃនោះ ៣ថ្ងៃហ្នឹង ២ថ្ងៃហ្នឹង ១ថ្ងៃ២ថ្ងៃហ្នឹង គឺមិនទាន់និយាយដល់ទេ គឺនិយាយត្រឹមបានត្រឹមតែការពារ និងកសាង ហើយនិងប៉ុណ្ណឹងនៅឡើយទេ។ ដូច្នេះខ្ញុំក៏ចេញទៅ មិនដឹងជាបន្តទៅទៀត គេពន្យល់ ឬគេនិយាយពីស្អីទៀត អាហ្នឹងខ្ញុំភ្លាប់អត់បាន។

**ស៖** នៅពេលលោកផ្តល់សក្ខីកម្មនៅឆ្នាំ២០១៣ នៅចំពោះមុខតុលាការយើងនេះគឺ សក្ខីកម្មថ្ងៃទី២៤ មេសា ២០១៣ <ឯកសារលេខ E1/183.1> នៅត្រង់ម៉ោង<១១:១៨> លោកឆ្លើយដូចតទៅ សូមដកស្រង់៖ “ខ្មាំងផ្ទៃក្នុងត្រូវបានលើកយកមកនិយាយនៅក្នុងអង្គប្រជុំ”។ ហើយម៉ោង១១:១២នាទីលោកបានឆ្លើយដូចតទៅ “សួរ៖ តើលោកចាំលម្អិតអំពីអ្វីដែល ប៉ុល ពត និយាយ<ពីអ្នក>ឈ្លានពានបរទេសទេ? ឆ្លើយ៖ នៅឆ្នាំ៧៨ អ្នកដែលមានឋានន្តរសក្តិផ្សេងៗចូលរួមប្រជុំ ហើយគេបង្រៀនយើងឲ្យប្រុងប្រយ័ត្នពាក់ព័ន្ធទៅនឹងគិញ ក.ហ្សេ.បេ, សេ.អ៊ី.អា ជាដើម។ល។ ហើយឲ្យយើងប្រុងប្រយ័ត្នខ្ពស់ ដើម្បីកុំឲ្យខ្មាំងហ្នឹង គេជ្រៀតចូលបង្កប់ខ្លួននៅក្នុងកន្លែងយើង។” តើលោកនៅចាំទេថា នែ៎ប្រធានបទនិយាយអំពីខ្មាំងស៊ីរូងផ្ទៃក្នុងនេះ ត្រូវបាន ប៉ុល ពត ឡើងនិយាយនៅ លើកយកមកនិយាយនៅក្នុងខែ<មិថុនា> ៧៨?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ខ្ញុំអត់ចាំដែរ។

[១៤:៣៨:០៩]

**ស៖**ចំណុចចុងក្រោយដែលខ្ញុំចង់សួរទៅលោក។ សូមលោកបើកទៅទំព័រដែលខ្ញុំដាក់ជា *ប៉ុស្តិ៍អ៊ីត*

ហ្នឹង គឺទំព័រជាភាសាខ្មែរ00143610, អង់គ្លេស00315374 ដល់75, បារាំង00593530។ គឺឯកសារ E3/1094 របាយការណ៍ដែលមានចំណងជើងថា “ការ<ស្វែងរក>គិញយួន, សេ.អ៊ី.អា, កា.ហ្សេ.បេ និងសមាសភាពមិនល្អ”។ “លេខ១ កម្ទេចខ្មាំងយួន១០០នាក់ រួមទាំងក្មេង ទាំងចាស់ និងកុមារផង។ ទី២ កម្ទេច៦០<នាក់>ពីជួរ<ដែលមានតួនាទី ក៏ដូច>ជាភ្នាក់ងាររបស់ចក្រពត្តិអាមេរិក ជាភ្នាក់ងារ សេ.អ៊ី.អា <ដែលបានលាក់ខ្លួននៅក្នុងកង និងសហករណ៍>។ លេខ៣ នៅក្នុងអង្គភាពកងទ័ព<តំបន់> យុទ្ធជន<>ចិន៤០នាក់ត្រូវបាន<រកឃើញ ហើយបញ្ជូនទៅកងផលិត>។” បញ្ចប់ការដកស្រង់។ នេះជារបាយការណ៍ស្ដីអំពីសកម្មភាពនៅក្នុងតំបន់នានានៅខែកក្កដា ៧៨ <គឺមួយខែក្រោយកិច្ចប្រជុំរបស់ ប៉ុល ពល នៅខែមិថុនា ៧៨>។ សំណួរ របស់ខ្ញុំសួរថា នៅក្នុងអង្គប្រជុំជាមួយនឹង ប៉ុល ពត ឬក៏អង្គប្រជុំផ្សេងទៀត តើលោកនេះ<>ដែលឮអំពីគោលនយោបាយរបស់របបនោះ ទាក់ទងនឹងជនជាតិវៀតណាមដែលនៅតែមាននៅក្នុងប្រទេសកម្ពុជានោះដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ដូចជាចំពោះសភាពការណ៍ដែលប្រាប់ថាកម្ទេចស្អីអស់ប៉ុន្មានៗនេះ គឺខ្ញុំអត់ដែលបានឮ ទទួលផែនការគេផ្សព្វផ្សាយថាយ៉ាងម៉េច គឺអត់ដែរទេ អត់ដែលបានឮផង កម្ទេចឯណា ១០០ស្អី ខ្មាំងយួនអស់១០០ក្បាល ហើយចំនួនចិនអី អស់៣០ក្បាល អីឯណាអីទៀត គឺអត់ដែល ខ្ញុំអត់ដែលបានទទួលដំណឹង ឬទទួលព័ត៌មានសោះ អត់រលីង។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ លោកសាក្សី។ សម្រង់ដែលខ្ញុំទើបតែអានចេញពីរបាយការណ៍នេះ និយាយអំពីយុទ្ធជនជនជាតិចិននៅក្នុងកងទ័ពតំបន់ តើលោកមានដឹងថា យុទ្ធជនដែលជាជនដើមកំណើតជនជាតិចិនហ្នឹង មាននៅក្នុងតំបន់ណាមួយ អង្គភាពណាមួយនៅភូមិភាគបស្ចិមដែរឬទេ? ហើយបើមានមែន លោកដឹងថាពាក្យថា “យុទ្ធជនចិន” នេះចង់និយាយថាម៉េចហ្នឹង?

[១៤:៤១:៣២]

**ឆ៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ព្រោះខ្ញុំនៅអង្គភាពដែរ គឺអង្គភាពកងទ័ពភូមិភាគបស្ចិម មួយទៀតនៅអង្គភាពតំបន់ ហើយនិងភូមិភាគ គឺចែកដាច់ដោយឡែកពីគ្នា គឺមិនមាន -- ដែលមេបញ្ជាការទទួលខុសត្រូវក៏ដោយឡែកពីគ្នាដែរ។ ដូច្នេះខ្ញុំក៏មិនដែលបានទទួលឮ ហើយខាងមេបញ្ជាខ្ញុំខាងភូមិភាគក៏អត់ដែលឮនិយាយថា មានចិន មានយួននៅក្នុងអង្គភាពហ្នឹងគឺអត់ដែលឮ អត់ដែលឮគាត់និយាយប្រាប់ អត់ដែលឮ។ ហ្នឹងខ្ញុំសូមបញ្ជាក់ដោយស្មោះត្រង់អស់ អត់មានអីទៅនេះទៀត អត់ដែលឮផង។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី និងខ្វះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៤:៥៧ នាទី)*

[១៤:៥៦:៥៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហាកមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះ -- សហមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយមេធាវី នួន ជា មានពេលវេលា៤៥នាទី មានពេលវេលា៤៥នាទី ក្នុងការសួរដេញដោលសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអភ័យទោស លោកប្រធាន ខ្ញុំស្តាប់អត់ទាន់ តើលោកប្រធាន ថាខ្ញុំមានពេលប៉ុន្មាននាទីដែរ?

**ប្រធានអង្គជំនុំ៖**

៤៥នាទី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១៤:៥៨:១៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំជាមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ហើយខ្ញុំមានសំណួរមួយចំនួន។ ឥឡូវនេះខ្ញុំសូមចាប់ផ្តើមទៅលើប្រធានបទដំបូងរបស់ខ្ញុំ។ លោកបានឆ្លើយទៅនឹងសំណួរ ទាក់ទងការចាប់ខ្លួនកងទ័ពវៀតណាម។ ហើយលោកបាននិយាយថា កងរបស់លោកមិនបានពាក់ព័ន្ធនឹងការចាប់ខ្លួនទាហានវៀតណាមនោះទេ។ ខ្ញុំចង់សួរលោកថា <អំពីអ្វីដែលបានកើតឡើងប្រសិនបើលោកដឹង> ក្នុងស្ថានភាពដែលទាហានវៀតណាមចាប់កងទ័ពខ្មែរវិញ ថាតើវាធ្លាប់មានកើតឡើងទេ? ហើយប្រសិនបើហេតុការណ៍នោះវាកើតឡើង តើមានអ្វីកើតឡើងចំពោះកងទ័ពខ្មែរដែលត្រូវវៀតណាមចាប់ខ្លួននោះ?

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ ព្រោះខ្ញុំនិយាយតែក្នុងក្របខ័ណ្ឌអង្គភាពខ្ញុំទេ ដល់ទូលាយពេក ខ្ញុំស្តាប់អត់បាន។ ដូច្នេះក្នុងអង្គភាពខ្ញុំដែលប្រយុទ្ធនៅសមរភូមិមុខហ្នឹង គឺៗអត់ យួនអត់ដែលចាប់បានទេ។

**ស៖** តើលោកធ្លាប់ឮថា អាចមានអ្វីកើតឡើងចំពោះកងទ័ពខ្មែរ ក្នុងពេលដែលមានការឈ្លានពាន ខែធ្នូ ៧៧ គឺប្រហែលជាប្រាំមួយ ប្រាំពីរខែ មុនពេលដែលកងទ័ពលោកទៅដល់? ថាតើធ្លាប់មានមេបញ្ជាការ ឬក៏អ្នកផ្សេងធ្លាប់ប្រាប់លោកថា មានអ្វីកើតឡើងចំពោះកងទ័ពខ្មែរដែលត្រូវបានចាប់ខ្លួនដោយកងទ័ពឈ្លានពានវៀតណាមដែរទេ?

[១៥:០០:៣៧]

**ឆ៖** មុនខ្ញុំមកព្រំដែន ដូច្នេះក៏មិនដែលបានឮថា កងទ័ពយួនចាប់បានខ្មែរដែរទេ។ តែគ្រាន់តែថាបានក្នុងកងពលដែលមាន តាសឿង ជាមេ គ្រាន់តែប្រាប់ថា យួនបានចូលមកទឹកដីយើងហើយ ដូច្នេះយើងនាំគ្នាប្រយ័ត្នប្រយែង ត្រៀមរៀបចំ គ្រាន់តែប្រាប់តែប៉ុណ្ណឹង អត់មានអីទេ គ្រាន់តែដឹងតែប៉ុណ្ណឹង។ ថាឲ្យយួនចាប់ខ្មែរ ទ័ពខ្មែរបាននៅកន្លែងណា អីកន្លែងណា គឺត្រង់ហ្នឹងគេអត់ប្រាប់ឲ្យយើងដឹងទេ ព្រោះយើងក៏អត់ដឹងដែរហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំសូមអានឲ្យលោកស្តាប់នូវសម្រង់ចេញពីសៀវភៅមួយ ដែលសរសេរដោយ

ជនជាតិអង់គ្លេសម្នាក់ ដែលគាត់បានមកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញនៅតុលាការនេះដែរ។ លោកប្រធាន ខ្ញុំយោងទៅលើឯកសារE3/9 ជាសៀវភៅរបស់ ហ្វីលីព ស្សូត នៅទំព័រ៣៧៧។ អង់គ្លេសមានលេខ 00396585, បារាំងមានលេខ <00639949> មិនមានភាសាខ្មែរនោះទេ។ ខ្ញុំសូមអានដូចតទៅនេះ៖ "នៅក្នុងពាក់កណ្តាលខែធ្នូ ៧៧ ទាហានវៀតណាម<៥០.០០០>នាក់ ដែលគាំទ្រដោយ<រថ-ក្រោះ> និងកាំភ្លើងធ្លោង បានវាយប្រហារឆ្លងកាត់ព្រំដែន តាមសមរភូមិ<មុខលាតសន្ធឹងជាងមួយ>រយម៉ាល ចាប់ពីចំណុចជំពុះទា <នៅខេត្តស្វាយរៀង> រហូតមកដល់ស្រុកស្នួល នៅខាងជើង។ នៅសប្តាហ៍ដំបូង ពួកគេជួបប្រទះការតស៊ូបន្តិចបន្តួច ហើយឈ្លានចូលផ្ទៃដី១២ម៉ាល ក្នុងទឹកដីកម្ពុជា។ ទាហានខ្មែរក្រហមដែលត្រូវបានចាប់ខ្លួន ឬក៏ធ្លាក់ចូលក្នុងដៃទាហានវៀតណាម ត្រូវបានសម្លាប់ភ្លាមៗតែម្តង។" តើលោកធ្លាប់ឮអំពីចំណុចទាំងអស់នេះទេ ក្នុងការវាយប្រហារខែធ្នូ ឆ្នាំ៧៧ គឺថាទាហានវៀតណាមសម្លាប់ទាហានខ្មែរជាប្រព័ន្ធតែម្តងនោះ?

[១៥:០៣:២០]

**ធ៖** ក្នុងខែធ្នូ ដែលបញ្ជាក់ឆ្នាំ១៩៧៧ ដែលថាកងទ័ពយួនចូលមកសម្លាប់ខ្មែរ ដូច្នេះខាងខ្ញុំខាងណោះ គឺអត់មានដែលឮគេផ្សាយអីទេ គេនិយាយអីទេ។ ដូច្នេះអត់មានដឹងឮ គ្រាន់តែប្រាប់សភាព-ការណ៍នៅព្រំដែនខាងកើត អត់ល្អហើយ យួនអាចនេះហើយ។ ដូច្នេះគ្រាន់តែប្រៀបថា គ្រាន់តែប្រាប់កងទ័ពប៉ុណ្ណេះ កុំទៅណា មកណា គឺត្រៀម ក្រែងលោយថាហេតុកើតឡើង។ អាហ្នឹងគ្រាន់ប៉ុណ្ណឹងទេ។ ឱ្យឮថាសម្លាប់យ៉ាងម៉េច ចាប់យ៉ាងម៉េច អាហ្នឹង គេអត់បញ្ជាក់ប្រាប់។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមបន្ត ទាក់ទងទៅនឹងអ្វីដែលគេបានសួរលោក គឺដោយព្រះរាជអាជ្ញាដែលបានសួរលោក។ គឺនិយាយអំពីការប្រយុទ្ធដែលលោកធ្លាប់ជួបប្រទះ នៅខែមិថុនា ៧៨។ លោកបានបញ្ជាក់ថា គឺមានកាំភ្លើងធំ ដែលបាញ់មកពីខាងកងទ័ពវៀតណាម ហើយលោកបាននិយាយអំពីការទម្លាក់គ្រាប់បែកតាមយន្តហោះ។ ឥឡូវនេះខ្ញុំសូមអាននូវអ្នកជំនាញមួយរូបទៀតរបស់តុលាការនេះ គាត់បានសរសេរ គឺសៀវភៅ គឺ <E3/2376> នៅទំព័រ៣១៨ គឺអង់គ្លេសមានលេខ 00192503, ខ្មែរមានលេខ 00191660, បារាំងមានលេខ <00237154> ជាសៀវភៅរបស់ណាយ៉ាន់ ចាន់ដា។ ហើយខ្ញុំសូមដកស្រង់៖ "នៅខែមិថុនា ឆ្នាំ១៩៧៨ នៅពេលដែលវៀតណាមទម្លាក់គ្រាប់បែបតាមយន្តហោះ គឺគេទម្លាក់ប្រហែលជា៣០ ទៅ៤០ដងក្នុង១ថ្ងៃ។" <ហើយបន្ទាប់មកគាត់បន្តនិយាយពីបញ្ហាការទូតមួយចំនួន។ ខ្ញុំចាប់អារម្មណ៍នឹងការ>ទម្លាក់គ្រាប់បែបប្រហែលជា៣០ដងក្នុង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

១ថ្ងៃ គឺបានន័យថា មកទម្លាក់ក្នុងទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ។” តើលោកចាំទេថា វាមានការទម្លាក់ដល់ទៅ៣០ដងក្នុង១ថ្ងៃហ្នឹង តើលោកចាំទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ទម្លាក់គ្រាប់បែកមាន ប៉ុន្តែត្រង់ថាចំនួនប៉ុន្មានដង ប៉ុន្មានដងក្នុង១ថ្ងៃ អាហ្នឹងខ្ញុំអត់ចាំទេ ហើយក្តាប់អត់បានដែរ។

[១៥:០៦:៣៤]

**ស៖** ខ្ញុំយល់ ប៉ុន្តែការទម្លាក់៣០ដងក្នុង១ថ្ងៃ តើវាស្តាប់ទៅវាសមស្របដែរ ឬមួយក៏ថាលោកពិបាកក្នុងការនិយាយ ថាវាដល់ថ្នាក់នោះ?

**ឆ៖** ត្រង់នេះខ្ញុំអត់មានបញ្ហាអីទេ ព្រោះបើយើងពិនិត្យមើលទៅ នៅពេលនោះខ្ញុំអត់មានពិបាកនិយាយទេ។ ដូច្នេះគ្រាន់ថា ខ្ញុំក្តាប់អត់បាន ហើយអត់ចាំថាយ៉ាងម៉េច អីយ៉ាងម៉េចទេ ព្រោះវាឆ្ងាយដែរពីគ្នាដែរ ពីស្វាយរៀងទៅខាងស្នួលខាងអីនោះ ដូចទម្លាក់តាមហ្នឹងទៅ។ ដូច្នេះវា បើទម្លាក់កន្លែងខ្ញុំទៅហ្នឹង ក្រែងលោខ្ញុំចាំបាន ខ្ញុំឃើញ តែបើឆ្ងាយពេក ក៏អត់ដែលឮ គេថាទម្លាក់ប៉ុន្មានដងៗ គ្រាន់ឮថាយន្តហោះយួន ទម្លាក់យន្តហោះនៅលើទឹកដីខ្មែរ តែចំនួនប៉ុន្មានៗ អាហ្នឹងគឺក្តាប់អត់បាន។

**ស៖** មិនអីទេ វាកើតឡើងយូរណាស់មកហើយលោកសាក្សី។ ឥឡូវនេះខ្ញុំសូមអាននូវសៀវភៅរបស់ ណាយ៉ាន់ ចាន់ដា ដដែល។ ហើយខ្ញុំនឹងសួរលោកថាតើលោកបានដឹងអំពីចំណុចទាំងអស់នេះទេក្នុងនាមលោកជាមេបញ្ជាការមួយរូបដែរ គឺទំព័រ<២១៨> គឺ <E3/2376>, អង់គ្លេសមានលេខ 00192403, បារាំងមានលេខ 00237082, ខ្មែរមានលេខ 00191553។ ចាន់ដា បាននិយាយអំពីខែមេសា ឧសភា គឺមុនពេលដែលលោកទៅដល់ ហើយគាត់បានសរសេរដូចតទៅនេះ៖ “នៅក្នុងរយៈពេល៤ខែ ក្នុងពេលដែលមានទំនាក់ទំនងការទូតអាក្រក់រវាងកម្ពុជាវៀតណាម មានជំរំសម្ងាត់ត្រូវបានរៀបចំឡើងនៅវៀតណាមខាងត្បូង ដើម្បីជ្រើសរើស ហើយនិងបណ្តុះបណ្តាលកងឧទ្ទាម។” ហើយក្រោមបន្តិច៖ “អតីតមូលដ្ឋានយោធាអាមេរិក ស៊ន់ ឡុក ហើយនិង ឡុង យ៉ាវ នៅជិតទីក្រុងហូជីមិញនោះ ហើយនិងមូលដ្ឋានកងឧទ្ទម្កាគចក្រនៅមីតាន់ នៅតាម<ដីសណ្តទន្លេ>មេគង្គត្រូវបានកែប្រែទៅជាមូលដ្ឋានថ្មីដើម្បីដឹកនាំទ័ពប្រឆាំង ប៉ុល ពត។ នៅ<ថ្ងៃទី២២> ខែមេសា ឆ្នាំ៧៨ កង<ពលតូចដំបូងរបស់កងទ័ពខ្មែរដែលរត់ចោលជួរត្រូវបានបង្កើតឡើងនៅក្នុងពិធីសម្ងាត់មួយ>។ នៅចុងឆ្នាំ៧៨ កង<ពលតូច>បែបនេះ<ជាច្រើន>បានចូលរួមជាមួយនឹងវៀតណាមដើម្បីរុញច្រានកម្ពុជាប្រជាធិបតេយ្យ។”

ខ្ញុំចង់សួរលោកថា លោកសាក្សី តើលោកដឹងអំពីជំរំសម្ងាត់ដែលមានឧទ្ទាមខ្មែរ ដែលមានកង

ឧទ្ទាមខ្មែរបានចូលរួមនៅក្នុងសង្គ្រាមឈ្លបប្រឆាំងកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ គឺខ្ញុំអត់បានឮ ហើយក៏អត់បានដឹងថា នៅព្រំដែនជាប់យួនហ្នឹងគឺមានពួកឧទ្ទាមដែលធ្វើសកម្មភាពប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ គឺអត់ដឹងដែរ។

**ស៖** លោកនិយាយថា កងរបស់លោកមិនដែលចាប់បានទាហានវៀតណាមទេ។ តើលោកមិនដែលចាប់ខ្លួនអ្នកបះបោរដែលខ្មែរគាំទ្រវៀតណាមទេ មែនទេ?

[១៥:១១:00]

**ឆ៖** ព្រោះខ្ញុំសូមបញ្ជាក់ ព្រោះអង្គភាពខ្ញុំមិនដែល អត់ដែលមានអ្នកណាបះបោរអីផង គឺអត់មានទេ ហើយក៏ខ្ញុំមិនដែលចាប់អ្នកបះបោរអីដែរ អត់ដែលមានទេ គឺនៅតែព្រំដែនហ្នឹង គឺសភាពការណ៍ហ្នឹង បះបោរខាងក្រោយខាងអី គឺខ្ញុំក្តាប់អត់មានទេ។ ដូច្នេះខ្ញុំនៅតែខាងមុខ គឺអត់មានដែលឃើញអ្នកបះបោរអីផង។

**ស៖** ប្រហែលជាខ្ញុំសួរមិនច្បាស់។ ខ្ញុំ<មិន>ចង់និយាយអំពីកងរបស់លោក<ទេ> ប៉ុន្តែខ្ញុំក៏និយាយអំពី<ទ័ព>ខាងបូព៌ាដែលបានចូលរួមជាមួយកង<កម្លាំងវៀតណាម>។ ដូច្នេះខ្ញុំចង់សួរថា លោកធ្លាប់ចាប់ខ្លួនអ្នកបះបោរមកពីខាងបូព៌ាដែរឬទេ គឺអតីតទាហានបះបោរដែលមកពីខាងបូព៌ាដែរទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ គឺខ្ញុំដែលទៅដល់៧៨ហ្នឹង គឺសភាពការណ៍នៅខាងកើតស្វាយរៀងហ្នឹង អត់មានអីអ្នកណាបះបោរ គឺស្ងៀតស្ងាម អត់មានអីទេ ហើយកងទ័ពខ្ញុំក៏អត់មានទៅចាប់ អត់មានអ្នកណាបះបោរផងទេ។ ដូច្នេះគឺអត់ សូមបញ្ជាក់អ៊ីចឹង។

**ស៖** ឥឡូវនេះខ្ញុំសូមបន្តទៅខែកញ្ញា ឆ្នាំ៧៨ ហើយខ្ញុំសូមអាននូវសៀវភៅដែលខ្ញុំបានដកស្រង់មកហើយគឺ សៀវភៅរបស់ ណាយ៉ាន់ ចាន់ដា ដើម្បីអាចជួយឲ្យលោកនឹកឃើញខ្លះ គឺឯកសារ <E3/2376> <ទំព័រ២៥៥>, អង់គ្លេសមានលេខ<00192440>, បារាំងមានលេខ 00237111, ខ្មែរមានលេខ 00191597។ នេះគឺជាអ្វីដែល<> ណាយ៉ាន់ ចាន់ដា បានសរសេរនៅក្នុងសៀវភៅអំពីហេតុការណ៍នៅក្នុងដើមខែកញ្ញា ឆ្នាំ៧៨។ "នៅដើមខែកញ្ញា វៀតណាមបានចាប់ផ្តើមប្រតិបត្តិការដែលដឹកនាំដោយកងរថក្រោះចូលក្នុងប្រទេសកម្ពុជា គោលដៅគឺដើម្បីទាក់ទងជាមួយ ហេង សំរិន ហើយនិងអ្នកគាំទ្ររបស់គាត់ ដែលលាក់ខ្លួននៅក្នុងព្រៃ ហើយអន្ទងហៅចូលទៅប្រទេសវៀតណាមវិញ។" សូមបញ្ចប់ការដកស្រង់។ តើលោកធ្លាប់ឮអំពីកងទ័ពរបស់មេបញ្ជាការកងពល<ភូមិភាគបូព៌ា> គឺលោក ហេង សំរិន លាក់ខ្លួននៅក្នុងព្រៃដែរឬទេ? តើលោកធ្លាប់ឮ ឬក៏ធ្លាប់ទទួលការណែនាំអំពីបញ្ហា

នេះទេ?

[១៥:១៤:០៩]

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចំពោះនៅព្រំដែនដែលថា មានកន្លែងលាក់ខ្លួនរបស់សត្រូវ របស់ខ្មាំង ដែលមាន ហេង សំរិន ជាមេបញ្ជាការ ដូច្នេះពេលនោះក៏ខ្ញុំអត់ ១ដែរបានឮផងហ្នឹង ព្រោះខ្ញុំទៅអត់ដែលបានឮថា មានតំបន់ខ្មាំងលាក់ខ្លួនណា ព្រោះខ្ញុំនៅតាមម្ដុំស្រុកប្រសូត្រ ម្ដុំអីហ្នឹងដូចអត់មានធ្វើសកម្មភាពអត់មានឃើញអីផង ឃើញតែយួនមកបាញ់គ្នាចុះឡើងហ្នឹង។ តែអីទៀត គឺខ្ញុំក្ដាប់អត់បាន ព្រោះការងារទាំងអស់ ដែលអ៊ីចឹងៗ ដូច្នេះក្នុងនាមខ្ញុំកងទ័ព ខ្ញុំក្ដាប់បានតែកម្លាំងខ្ញុំ និងសកម្មភាពគឺបាញ់ និងនេះប៉ុណ្ណឹងទេ។ ឯការងារផ្សេងៗ ដូចជាផ្នែកព័ត៌មានអីផ្សេងៗ គឺមិនសូវបានដឹងទេ មិនសូវបាននេះទេព្រោះគ្មានប្រព័ន្ធទាក់ទងអីបាន មានប្រព័ន្ធទាក់ទងអី ព្រោះគ្មានប្រព័ន្ធទាក់ទង។

**សៈ** មិនអីទេលោកសាក្សី ខ្ញុំគ្រាន់តែចង់សាកសួរអំពីការដឹងឮរបស់លោកប៉ុណ្ណោះ។ ខ្ញុំនឹងអានឲ្យលោកស្ដាប់នូវចំណុចមួយទៀត គឺជាសៀវភៅរបស់ ណាយ៉ាន់ ចាន់ដា គឺពីទំព័រ២៥៤ អង់គ្លេសមានលេខ <00192439>, បារាំងមានលេខ 00237111, ខ្មែរមានលេខ 00191596។ មុនពេលខ្ញុំអាននូវសម្រង់នេះ ខ្ញុំយល់ថា លោកមិនមានវិទ្យុទាក់ទងទេ ក៏ប៉ុន្តែខ្ញុំសូមអានឲ្យស្ដាប់នូវចំណុចនេះតែម្ដង។ "នៅ<ចុង>ខែមិថុនា ហាណូយ (ឬក៏យើងហៅថា វៀតណាមក៏បានដែរ) បានចាប់ផ្ដើមការផ្សព្វផ្សាយជាភាសាខ្មែរ ស្នើសុំឲ្យមានការបះបោរ គឺថាជាសំឡេងរបស់អតីតទាហានខ្មែរដែល<គេជឿថាបានស្លាប់ហើយនោះ បានផ្សាយតាមវិទ្យុហើយ>មកផ្ដល់ការធានាអះអាង។" ហើយបន្ទាប់មកទៀតគាត់និយាយអំពីបងរបស់ ហេង សំរិន គឺហេង សំកៃ។ តើក្នុងនាមលោក ជាមេបញ្ជាការ ថាតើគេមានប្រាប់លោក ឬក៏លោកមានបានដឹងអំពីការផ្សព្វផ្សាយវិទ្យុជាភាសាខ្មែរ ដែលអំពាវឲ្យមានការងើបបះបោរនៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ?

[១៥:១៦:៥៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថែម ដូច្នេះអត់បានឮ អត់បានអីទេ ដូច្នេះអត់មានអ្នកណាគេមកផ្សព្វផ្សាយឲ្យបះបោរអីទេ គឺនាំគ្នានៅអ៊ីចឹង ប្រុងប្រៀប។ ដូច្នេះដឹងគ្រាន់តែសភាពការណ៍ក្ដាប់ទៅ មើលថាយួនវាខ្លាំងហើយ ដូច្នេះយើងត្រៀមចំ រៀបចំ តែប្រុងតែចាញ់គេនោះដែរ។ ដូច្នេះអត់មានក្ដាប់បញ្ហាអីបានផ្សេងទៀតទេ គឺឃើញសភាពការណ៍នោះវាយ៉ាប់ហើយ ចុង៧៨ ដើម៧៩ គឺសភាពការណ៍គឺយ៉ាប់ហើយ គឺលែងចង់ស្ដាប់សភាពការណ៍អីអស់ហើយ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** មិនអីទេ លោកសាក្សី តើលោកធ្លាប់ដឹង តើកងទ័ពវៀតណាមហ្នឹងជាអ្នកណាដែរ? តើលោកដឹងថា ឧទាហរណ៍ដូចថា តើកងទ័ពវៀតណាមហ្នឹងមកពីតំបន់ណា មកពីផ្នែកណា ឬក៏មកពីភូមិភាគណាដែលលោកដឹងអំពីព័ត៌មានលម្អិត ថាតើទាហានវៀតណាមដែលលោកត្រូវប្រយុទ្ធជាមួយហ្នឹងមកពីយ៉ាងណាដែរ? តើលោកអាចដឹងអំពីរចនាសម្ព័ន្ធរបស់កងទ័ពវៀតណាមទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់គឺ ទាំងកងទ័ពវៀតណាម ដឹងថាមកពីទិស មកពីខាងបូព៌ាហ្នឹងហើយ ក៏ប៉ុន្តែក៏អត់ដឹងចំនួនប៉ុន្មាន ហើយរចនាសម្ព័ន្ធគេហ្នឹង គេរៀបចំយ៉ាងម៉េចអីយ៉ាងម៉េច អត់ដឹងទេ។ ហ្នឹងគឺក្តាប់អត់បានដែរ។ អាហ្នឹងគឺខ្ញុំសូមបញ្ជាក់អ៊ីចឹង។

**ស៖** តើលោកអាចដឹងទេថា កងទ័ពដែលលោកត្រូវប្រយុទ្ធជាមួយហ្នឹង គឺមកពីតំបន់យោធាលេខ៧របស់វៀតណាម ហើយមេបញ្ជាការហ្នឹងគឺមេបញ្ជាការឈ្មោះ ត្រាន់ វ៉ាន់ត្រា តើវាអាចថាជាព័ត៌មានដែលលោកធ្លាប់ដឹងដែរឬទេ?

[១៥:១៩:១៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងត្រូវការឯកសារយោង។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** មិនអីទេ។ គឺនៅក្នុងសៀវភៅ ណាយ៉ាន់ ចាន់ដា អង់គ្លេសមានលេខ 00192378, បារាំងមានលេខ00237061, ខ្មែរមានលេខ 00191525។ គឺនៅទំព័រដដែលនេះ ក៏និយាយអំពីអនុមេបញ្ជាការមកពីកងពលតំបន់លេខ៧។ ខ្ញុំ<សូមនិយាយត្រឹមតែមេបញ្ជាការ ដែលជាបុគ្គលម្នាក់បានដឹកនាំការវាយប្រហារចូលក្រុងសៃហ្គននៅឆ្នាំ១៩៧៥ គឺឧត្តមសេនីយ៍> ត្រាន់ វ៉ាន់ត្រា។ <>តើលោកធ្លាប់ឮឈ្មោះមេបញ្ជាការនេះទេ? ឬក៏ថាអាចដឹងថា គាត់ជាមេបញ្ជាការដឹកនាំកងតំបន់យោធាលេខ៧ទេ?

**លោក ជួន ធី៖**

**ឆ៖** ខ្ញុំសូមឆ្លើយ ព្រោះពេលហ្នឹងគឺរឿងរចនាសម្ព័ន្ធយោធា កងពលប៉ុន្មាននៅប៉ុន្មានដែលវ៉ៃទល់មុខគ្នា ហើយមេបញ្ជាការឈ្មោះអី ក៏ក្តាប់អត់បានដែរ។ ហើយពេលនោះគឺយួននៅបៀត ហើយសំខាន់គឺដឹងថាពេលដែលវាបាញ់មកៗ គឺតាមផ្លូវលេខ១ហ្នឹង គឺចេញពីនេះមកគឺតាមហ្នឹងកងទ័ពហ្នឹងទាំងរថក្រោះអីមកតាមហ្នឹងមក ហើយយើងនេះប្រឹងនាំគ្នារត់ទៅ មាននេះៗ ក្តាប់វាមិនបានមេបញ្ជាការក៏មិនដឹងយួនហ្នឹងឈ្មោះអី ព្រោះអាហ្នឹងដឹងទាល់តែមានវិទ្យុទាក់ទង បើមេខាងលើប្រាប់ បើមេខាងលើ

អត់ប្រាប់ ខ្ញុំអត់បានដឹងដែរហ្នឹង អត់បានឮដែរ។

[១៥:២០:៥៧]

**ស៖** មិនអីទេលោកសាក្សី។ ឥឡូវនេះខ្ញុំសូមបន្តសួរទាក់ទងនឹងអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញនៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់មេធាវីការពារក្តី ខៀវ សំផន គឺប្រហែលជាម៉ោង១៥:៥១ នៅពេលរសៀល។ គឺលោកបានឆ្លើយដូចតទៅនេះ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថាតើខ្ញុំយល់អ្វីដែលលោកនិយាយឬអត់។ លោកថា “លោក<បានសួរខ្ញុំ>អំពីរយៈពេលចន្លោះឆ្នាំ៧៥<ដល់ឆ្នាំ៧៩> ព្រោះវាពិបាកក្នុងការនិយាយនៅក្នុងរយៈពេលនេះ ព្រោះថារឿងរ៉ាវវាមានទំនាក់ទំនងជាមួយនឹងស្ថានភាពនៅមុនពេលនោះ។” តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកឆ្លើយបែបនេះកាលពីម្សិលមិញ លោកសាក្សី?

**ឆ៖** ខ្ញុំសូមឆ្លើយចំពោះដែលខ្ញុំឆ្លើយរបៀបនេះ ព្រោះសង្គ្រាមហ្នឹងវាបន្លាយពេលតាំងពីឆ្នាំ៧០មក រហូតមកដល់៧៥ ៧៥ហើយក៏បន្តទៅ៧៥ ទៅដល់៧៨ទៀត។ ដូច្នេះរឿងខ្ញុំចង់និយាយអ៊ីចឹង ថាដូច្នេះសង្គ្រាមហ្នឹងបើនិយាយតែមួយកំណាត់ទៅ ក៏ដូចជាពិបាកនិយាយ មិនដឹងអី ព្រោះសង្គ្រាមនោះវាដើមហេតុមកតាំងពីឆ្នាំ៧០។ នេះខ្ញុំសូមបញ្ជាក់ មានប៉ុណ្ណឹង។

**ស៖** ប៉ុន្តែតើលោកចង់មានន័យថា សង្គ្រាមរវាងកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងលន់ នល់ ឬមួយក៏សង្គ្រាមរវាងបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងកងកម្លាំងរបស់បក្សកុម្មុយនីស្តវៀត-ណាម?

**ឆ៖** ខ្ញុំបញ្ជាក់ ខ្ញុំសូមតែពិបាកនិយាយទាំងពីរហ្នឹង ពិបាកទាំងពីរហ្នឹង។

[១៥:២៣:០៩]

**ស៖** ខ្ញុំយល់ ប៉ុន្តែឥឡូវខ្ញុំសួរលោកអ៊ីចេះវិញ តើលោកដឹងអំពីការបះទង្គិចគ្នារវាងកងទ័ពកុម្មុយនីស្តវៀតណាមជាមួយកងទ័ពកុម្មុយនីស្តខ្មែរមុនឆ្នាំ៧៥ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** ដើម្បីជាកំណត់ត្រាប្រតិចារឹក ខ្ញុំគិតថាវាអាចជួយដល់ការចងចាំរបស់លោកផងដែរ។ អ្នកជំនាញអូស្ត្រាលីដែលបានមកផ្តល់កាលពីសប្តាហ៍មុន បានសរសេរនៅក្នុងឯកសារ E3/7338 <មានERNតែជាភាសា>អង់គ្លេសមានលេខ <01001722>។ បានសរសេរដូចតទៅនេះ៖ “ក្នុងរយៈពេល២ឆ្នាំក្រោយរដ្ឋប្រហារលន់ នល់ ទោះបីថាទីក្រុងហាណូយព្យាយាមណែនាំដោយប្រុងប្រយ័ត្នដល់

ឧទ្ទាមកម្ពុជា ក៏ឧទ្ទាមរបស់កម្ពុជាបានកើនឡើងយ៉ាងខ្លាំង ហើយមានការបះទង្គិចញើកញាប់រវាងកុម្មុយនីស្តវៀតណាម និងខ្មែរក្រហម។” សូមបញ្ចប់ការដកស្រង់។ គឺការបះទង្គិចញើកញាប់ អាច<> បះទង្គិច<ដល់ទៅ>២០០ដង។ ថាតើលោកធ្លាប់ឮអំពីការបះទង្គិចគ្នានេះដែរឬទេ ឬមួយក៏លោកមិនដែលឮទាល់តែសោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថែម ព្រោះខ្ញុំនៅខាង ដូចខ្ញុំបញ្ជាក់អ៊ីចឹងថា ខ្ញុំនៅ ហៅថាព្រំដែនខាងលិច ហៅបស្ចិម ដូច្នេះចេះតែមានបញ្ហាជាមួយយួន ហើយជាមួយនឹងខ្មែរយើងមកពីខាងបូព៌ា ដូច្នេះវាឆ្ងាយចន្លោះហ្នឹងគឺខ្ញុំក្តាប់សភាពការណ៍អីអត់បានដែរទេ។ ហ្នឹងខ្ញុំសូមបញ្ជាក់អ៊ីចឹង ព្រោះសភាពការណ៍វានៅឆ្ងាយពីគ្នា សភាពការណ៍អីដែលកើតឡើង ក៏ក្តាប់អត់បានដែរ។

[១៥:២៥:៥២]

**ស៖** ខ្ញុំយល់ មិនអីទេលោកសាក្សី។ ឥឡូវនេះខ្ញុំសូមបន្តទៅប្រធានបទថ្មីដែលជាប្រធានចុងក្រោយសម្រាប់ខ្ញុំ។ លោកបាននិយាយសង្ខេបអំពីឈ្មោះរដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការធំ គឺលោក សុន សេន នោះ។ នៅក្នុងសក្ខីកម្មរបស់លោកនៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃ២៤ ខែមេសា ២០១៣ គឺនៅ<មុនម៉ោង><១០:១០នាទី>ព្រឹកបន្តិច គឺលោកបានឆ្លើយដូចតទៅនេះ៖ “ខ្ញុំធ្លាប់ជួបលោក សុន សេន ម្តងម្កាលដែរ នៅពេលដែលយើងពិភាក្សាអំពីផែនការទប់ទល់ជាមួយវៀតណាម។” ហើយក្រោមបន្តិច លោកនិយាយថា៖ “ខ្ញុំជួបគាត់ក្នុងពេលដែលយើងរៀបផែនការ ដើម្បីធានាថា កងទ័ពវៀតណាមមិនអាចឈ្លានពានចូលជ្រៅមកក្នុងទឹកដីកម្ពុជាសាជាថ្មី។” តើលោកចាំថា លោកបានឆ្លើយនូវចំណុចទាំងអស់នេះទេ លោកសាក្សី គឺប្រហែលជា<ជាង>៣ឆ្នាំ<កន្លងទៅ>នៅក្នុងតុលាការនេះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ គឺចម្លើយ គឺខ្ញុំឆ្លើយខ្លះ ត្រង់ថា សុន សេន គឺបានជួប។ ត្រង់ថា បាននិយាយគ្នា យួនលែងចូលមកទឹកដីយើងបានហ្នឹង ត្រង់ហ្នឹង ខ្ញុំដូចអត់មានឆ្លើយទេ អត់មាននិយាយទេ ត្រង់ហ្នឹង ព្រោះយើងឃើញសកម្មភាពយួនខ្លាំង អាហ្នឹងយើងអត់ហ៊ាន អត់មានដែលខ្ញុំថាទេ។ ហ្នឹងខ្ញុំសូមបញ្ជាក់គឺមានប៉ុណ្ណឹង។

**ស៖** មិនសំខាន់ទេ ប៉ុន្តែលោកចាំថាលោកបាននិយាយជាមួយ សុន សេន អំពីស្ថានភាពជាមួយវៀតណាមមែនទេ?

**ឆ៖** បាននិយាយជាមួយ។

[១៥:២៨:១២]

**ស៖** ខ្ញុំដឹងថា វាកើតឡើងយូរមកហើយ ក៏ប៉ុន្តែតើលោកអាចចាំបានទេថា ប្រហែលជាមិនចាំបាច់ចាំពាក្យពេចន៍ទាំងស្រុងរបស់គាត់ទេ ប៉ុន្តែគ្រាន់តែថា គាត់ប្រើប្រាស់ពាក្យយ៉ាងម៉េចដែរ ឬក៏វាមានលក្ខណៈបែបណាដែរ នៅពេលដែលគាត់និយាយអំពីវៀតណាមនោះ?

**ឆ៖** ពេលនោះ គឺតាមខ្ញុំស្តាប់គាត់និយាយ ក៏មិនជាខ្លាំងអីដែរ គ្រាន់ថាយួន គេចូលមកទឹកដីយើង ដូច្នេះយើង ទ័ពយើងក៏តិច សម្ភារៈយើងក៏នេះ ក៏ប៉ុន្តែយើងមិនដឹងជាទប់ទល់យ៉ាងម៉េចទេ។ ហ្នឹងគ្រាន់តែៗនិយាយគ្នាតែអ៊ីចឹង។ ខ្ញុំសូមបញ្ជាក់ គឺមាននិយាយអ៊ីចឹង។

**ស៖** ឥឡូវនេះខ្ញុំចង់ឲ្យលោកពិនិត្យអំពីឯកសារមួយ ដែលសរសេរអំពីពាក្យរបស់ សុន សេន ទាក់ទងទៅនឹងវៀតណាម គឺ<មាន>ពាក្យ<ពីរ>ដែលគាត់និយាយជាមួយនឹងមេបញ្ជាការយោធាមួយរូបទៀត នៅក្នុងឆ្នាំ៧៦ គឺប្រធានកងពល៩២០។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ មកពីឯកសារE3/799 គឺជាកំណត់ហេតុកិច្ចប្រជុំពេញអង្គរបស់កងពល៩២០ <ថ្ងៃទី៧> ខែកញ្ញា ឆ្នាំ៧៦។ គឺអង់គ្លេសមានលេខ <00184781>, បារាំងមានលេខ 00323916, ខ្មែរមានលេខ<00083160>។ ហើយខ្ញុំមានឯកសារជាភាសាខ្មែរ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ជូនទៅដល់សាក្សី សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៣០:៤៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅពេលដែលលោកកំពុងតែអានសម្រង់នេះ ខ្ញុំសូមអានជាភាសាអង់គ្លេស។ គាត់បាននិយាយថា៖ “បដិវត្តយើងជាបដិវត្តកុម្មុយនីស្តដ៏ជ្រាលជ្រៅ។ ដូច្នេះចំពោះវៀតណាម យើងត្រូវប្រកាន់ជំហរដូចតទៅ ទី១ យើងមិនមែនជាអ្នកបង្កបញ្ហាទេ។ ២) យើងត្រូវតែការពារទឹកដីរបស់យើងជាដាច់ខាត ដោយមិនឲ្យអ្នកណាឈ្លានពានយកទឹកដី <ទី៣)>ទោះបីបើវៀតណាមឈ្លានពាន យើងនឹងស្នើសុំឲ្យពួកគេដកទៅវិញ ហើយបើមិនដកទេ យើងនឹងវាយប្រយុទ្ធហើយ។ <ទិសដៅរបស់យើងគឺយើងវាយទាំងពីរ> គឺយើងវាយទាំងផ្នែកចិត្តសាស្ត្រ និងទាំងផ្នែកកងទ័ពផង។” លោកសាក្សី តើលោកនៅនឹកឃើញថា កិច្ចប្រជុំរបស់លោកជាមួយ សុន សេន នេះ គាត់មាននិយាយដូចដែលខ្ញុំទើបតែអានឲ្យ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកស្តាប់ ដូចដែលមាននៅក្នុងឯកសារចំពោះមុខលោកនេះដែរឬទេ?

**លោក ជួន ធី៖**

**ធ៖** ខ្ញុំសូមបញ្ជាក់ ចំពោះអង្គភាព៩២០នេះ ក៏ខ្ញុំមិនដែលស្គាល់ ហើយក៏មិនដែលឮទេដែរ។ ដូច្នេះដែលការជួបជុំជាមួយ សុន សេន ម្តងម្កាល គឺអត់មាននិយាយដូចក្នុងនេះទេ ក៏គាត់អត់ដែលបាននិយាយពីរឿងអ៊ីចឹងទេ គ្រាន់តែថា យើងដាច់ខាត គ្រាន់ថាការពារទឹកដីយើងឲ្យបាន។ អាហ្នឹងគ្រាន់តែនិយាយប៉ុណ្ណឹង។ ហ្នឹងគឺប៉ុណ្ណឹង តែក្នុងកង -- គាត់គ្រាន់តែនិយាយបញ្ជាក់ ទឹកដីយើង ត្រូវតែយើងរស់នៅ ហើយយើងការពារ។ ហ្នឹងគាត់និយាយ គ្រាន់តែប្រាប់អ៊ីចឹង។

**ស៖** <គ្រាន់តែដើម្បីបញ្ជាក់ឲ្យបានច្បាស់តែប៉ុណ្ណោះ។ ខ្ញុំយល់ហើយថា> លោកមិនមានអ្វីពាក់ព័ន្ធជាមួយកងពល៩២០ទេ ក៏ប៉ុន្តែនេះគឺជាពាក្យពេចន៍ដែល សុន សេន បាននិយាយនៅពេលដែលគាត់បើកអង្គប្រជុំពេញអង្គជាមួយកងពល៩២០នោះ។ សំណួររបស់ខ្ញុំ សូមសួរពាក្យពេចន៍ដែលគេបានកត់ត្រានេះ តើនេះក៏ជាសម្តីដែល សុន សេន បានប្រាប់លោកដែរឬទេ?

[១៥:៣៣:១៤]

**ធ៖** ដូចខ្ញុំបញ្ជាក់អំមិញ សម្តីនេះគាត់អត់បានប្រាប់ខ្ញុំទេ តែគ្រាន់គាត់ថា ទឹកដីយើង យើងត្រូវតែការពារឲ្យបាន។ នេះគ្រាន់តែគាត់ប្រាប់អ៊ីចឹង។ ទោះជាមានឧបសគ្គយ៉ាងម៉េចក៏ដោយ។ នេះគ្រាន់តែបញ្ជាក់តែប៉ុណ្ណឹងទេ អត់មានថាយ៉ាងម៉េចទៀតទេ។

**ស៖** ខ្ញុំយល់ហើយ។ ប៉ុន្តែឥឡូវខ្ញុំសួរឲ្យ<ចំ>ចំណុចតែម្តង គឺថាលោកត្រូវបានគេយកសក្ខីកម្មរបស់ មាស វឿន មកសួរលោកបីបួនដងហើយ គឺគាត់មកពីកងពលលេខ១ មកពីភូមិភាគបស្ចិម។ ទោះយ៉ាងណាក៏ដោយ មាស វឿន បានផ្តល់ភស្តុតាងដូចតទៅ នេះគឺឯកសារE3/8752, ERN ជាភាសាអង់គ្លេស 00849510 ដល់11, បារាំង 01309292, ខ្មែរ 00733339។ បុគ្គលម្នាក់នេះ ដែលជាកងទ័ពមកពីភូមិភាគបស្ចិមនោះ គាត់មិនមែននិយាយតែត្រឹម សុន សេន នេះទេ គាត់និយាយពី តាម៉ុក ផងដែរ។ នេះគឺអ្វីដែលគាត់បាននិយាយ៖ "ចាប់តាំងពីធ្វើការតស៊ូមក មានតែ តាម៉ុក ទេ ក្រោយមកគេបង្កើតកងទ័ព កងទ័ពជើងអាកាស និងកងទ័ពជើងទឹក។ នៅពេលនោះ សុន សេន គឺជានាសេនាធិការ ហើយ តាម៉ុក ហ្នឹងជាមេបញ្ជាការនៅសមរភូមិ។ តាម៉ុក ទៅសមរភូមិដោយផ្ទាល់ ហើយ សុន សេន គ្រាន់តែបញ្ជាពីក្រោយទេ។ ដោយសារ តាម៉ុក ទៅសមរភូមិដោយផ្ទាល់ អ៊ីចឹងគាត់ក៏ជាអគ្គមេបញ្ជាការ ហើយក៏ជាមេបញ្ជាការនៅតាមសមរភូមិទាំងអស់នោះផងដែរ។" នេះជាចំណុចសំខាន់ "នៅ

តាមព្រំដែន គាត់ណែនាំនិយាយអំពីខ្មាំងខាងក្រៅ។ គាត់បាននិយាយថា សូមដកស្រង់៖ យើងត្រូវតែការពារបូរណភាពដែនដីរបស់យើង ហើយយើងត្រូវតែអត់ធ្មត់ កុំវាយតបតទៅវិញ បើគេបាញ់រប៉េះរបោះមកយើង គឺថាត្រូវតែនៅស្ងាត់ស្ងៀម បើគេបាញ់បីបួនគ្រាប់មកយើង ហើយយើងបាញ់ទៅវិញ នឹងបង្កើតបញ្ហាធំហើយ។” បញ្ចប់ការដកស្រង់។ ទោះបីជាសក្ខីកម្មនេះមិនច្បាស់ថា សម្ដីនេះជាសម្ដី តាម៉ុក ឬសម្ដីសុន សេន ក៏ដោយ គឺវាមិនជាបញ្ហាអ្វីទេ។ តើនេះក៏ជាការណែនាំដល់លោក និងកងទ័ពរបស់លោកនៅឯស្វាយរៀង នៅខែ<មិថុនា> ៧៨ នោះដែរឬទេ ដែលណែនាំថាឲ្យអត់ធ្មត់ ស្ងៀមស្ងាត់ កុំបង្កបញ្ហាអ្វីធំដុំ?

[១៥:៣៦:៤៤]

**ឆ៖** ខ្ញុំសូមពាក្យដូចលោកសួរមកហ្នឹង អាហ្នឹងគឺជាបញ្ហាដែលត្រូវអប់រំអង្គភាព ប្រាប់អង្គភាព។ ដូចខ្ញុំបញ្ជាក់ឲ្យវែងបន្តិចទៅ ដូចខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹងថា សភាពការណ៍នៅព្រំដែនវាយ៉ាប់យឺន វាខ្លាំងហើយ ដូច្នេះគ្រាន់ថា ឲ្យកងទ័ពហ្នឹងប្រុងប្រៀបរៀបចំហ្នឹង គឺមិនរៀបចំអី មិនមែនរៀបចំ តែដឹងថាទប់មិនឈ្នះហើយ បើរៀបចំ និយាយស្ងាត់ៗ បើរៀបចំមិនឈ្នះ ទប់គេមិនឈ្នះ ដីយើងនៅលិចនេះច្រើនរត់ទៅលិចទៅ អាហ្នឹងគឺគ្រាន់តែមានទស្សនៈ គឺមានអ៊ីចឹង តែការនិយាយស្ដីអាហ្នឹងវាផ្សេង អាហ្នឹងសូមបញ្ជាក់អ៊ីចឹង។

**ស៖** ខ្ញុំសួរបញ្ជាក់កុំឲ្យមានការយល់ច្រឡំគ្នា។ គឺថាសុន សេន បានប្រាប់ទៅកងពលមួយ ឥឡូវខ្ញុំនិយាយអំពីអ្វីដែលមេបញ្ជាការនេះបាននិយាយ។ ឥឡូវខ្ញុំនិយាយអំពីឆ្នាំ១៩៧៥ មានការបញ្ជាទៅដល់កម្មាភិបាលទាំងអស់ជាពិសេសដល់យុវជន កងទ័ពយុវជនបដិវត្ត។ នេះគឺឯកសារ E3/749 <នេះជាការបើកពុម្ពលើកទី>៨ <គឺ>ឯកសារ<>យុវជនបដិវត្ត <ខែសីហា ឆ្នាំ១៩៧៥> ERN ជាភាសាអង់គ្លេស 00532686, បារាំង 00593942, ខ្មែរ 00399114។ នេះគឺជាអ្វីដែលបានបង្គាប់បញ្ជាទៅយុវជន កងទ័ពយុវជនទាំងអស់នៅក្នុងឆ្នាំ៧៥ សូមដកស្រង់៖ “នៅតាមព្រំដែន ដាច់ខាតត្រូវតែប្រុងប្រយ័ត្ន ហើយមិនត្រូវធ្វើអ្វីបង្កបញ្ហាទៅដល់ប្រទេសជិតខាងនោះទេ ប៉ុន្តែត្រូវការពារជាដាច់ខាតកុំឲ្យគេរំលោភបំពាន ឬឈ្លានពានដល់ជាតិសាសន៍យើង។” បញ្ចប់ការដកស្រង់។ លោកសាក្សី លោកយល់ស្របជាមួយនឹងខ្ញុំទេថា គោលនយោបាយថាត្រូវមានប្រតិកម្មយ៉ាងម៉េច ចំពោះការឈ្លានពានពីសំណាក់វៀតណាមហ្នឹង គឺថាត្រូវបានគេបង្គាប់យ៉ាងច្បាស់លាស់<ទៅដល់កម្មាភិបាល>តាំងពីដើមដំបូងមក<ម្ល៉េះ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01376927



[១៥:៣៩:៣៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះយោបល់ដែលលើកឡើងថា ពេលដែលយើងបានវ៉ៃឈ្នះអាមេរិកហើយ នៅ៧៥ហ្នឹង គឺខ្ញុំក៏បានទទួលដែរ ពាក្យថា យើងរស់នៅលើទឹកដីយើង យើងកុំទៅបង្កហេតុ បង្ករឿងនៅប្រទេសជិតខាង។ យើងកុំទៅចូលឈ្លានពានគេ វ៉ៃគេ ហើយកុំធ្វើអីគេ។ ហ្នឹងគឺមានការណែនាំអ៊ីចឹង គឺអត់ឱ្យមានបង្កហេតុបង្ករឿងអីទេ។ អាហ្នឹងគឺខាងលើ គឺបានណែនាំអ៊ីចឹង គ្រប់អង្គភាពដែរគេនិយាយ។

**ស៖** ហើយនេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ លោកប្រធាន គឺខ្ញុំសួរបន្ទាប់ពីអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ។ នៅម៉ោង១៤:៣៩រសៀលនេះ សហការី សហភាតារបស់ខ្ញុំនេះបានសួរទៅលោក។ ខ្ញុំសុំសួរឡើងវិញ "បើខ្ញុំយល់មិនច្រឡំទេ គឺតែនៅពេលដែលវៀតណាមឆ្លងកាត់ព្រំដែនចូលមកក្នុងបូរណភាពដែនដីយើងទេ ទើប<លោក>វាយប្រយុទ្ធ អ៊ីចឹងមែនទេ?" ហើយលោកឆ្លើយថា "បាទ។" ហើយមានបីបួនលើកនោះ ជាភាសាអង់គ្លេសដែលខ្ញុំស្ដាប់ទៅ លោកប្រើពាក្យដដែលដូចគ្នាទេ ជាពាក្យមួយដែលគួរឱ្យចាប់អារម្មណ៍មែនទែនសម្រាប់ខ្ញុំ។ នៅម៉ោង១៥:០៩ ក្រោយម៉ោង១៥:០៩នេះម្សិលមិញនេះ លោកឆ្លើយថា៖ "ប្រសិនណាមានការលុកលុយណាមួយ យើងគឺថាត្រូវតែទប់ស្កាត់ រុញពួកគេវិញ ទប់ស្កាត់ពួកគេ។" <នៅម៉ោង១៥:១៣នាទី លោកថា> "យើងត្រូវតែឯករាជ្យ ត្រូវតែបញ្ឈប់គេ កុំឱ្យឈ្លានពានយើង។" នៅម៉ោង១៥:២៥៖ "ថាដើម្បីទប់ស្កាត់ កុំឱ្យគេលុកលុយចូលមក។" <នៅម៉ោង១៥:៤៤នាទី៖> "យើង<>ឯករាជ្យ។ <បើសត្រូវ>វាយមករកយើង ៗត្រូវតែប្រយុទ្ធតបតទៅវិញ។" លោកបានឆ្លើយជាញឹកញយកាលពីម្សិលមិញនេះ។--

[១៥:៤២:០០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សូមទោសលោកមេធាវី។ គ្រាន់តែដើម្បីបញ្ជាក់ឱ្យច្បាស់តែប៉ុណ្ណោះ ដោយសារថាលោកសំដៅទៅលើពាក្យដែលលោកប្រើ> គឺថាគាត់ប្រើពាក្យខ្មែរដដែលៗ ឬក៏យ៉ាងណា?

**លោក វ៉ិចទ័រ កូប៉េ៖**

<មិនមែនប្រើជានិច្ចនោះទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកសួរសំណួរអ៊ីចឹង វាមានបញ្ហាបន្តិចហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយលោកស្រីចៅក្រម។ អ៊ីចឹងខ្ញុំរៀបសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅជាភាសាអង់គ្លេស គឺមានពាក្យមួយដែលលោកបានប្រើប្រាស់នោះ ខ្ញុំសួរបើកចំហតែម្ដង។ កាតព្វកិច្ចរបស់លោកជាមេបញ្ជាការគឺថា ត្រូវតែម្ចាស់ការដោយខ្លួនឯង។ តើលោកចង់មានន័យដូចម្ដេច ពាក្យថា *"ខនថេន"* នេះ "ម្ចាស់ការដោយខ្លួនឯង" នេះ?

[១៥:៤២:៥៩]

**លោក ជួន ធី៖**

**ធ៖** ពាក្យ "ម្ចាស់ការដោយខ្លួនឯង" នេះគឺបានន័យថា ពេលដែលមានសភាពការណ៍ដូចជាខ្មាំងបុកចូលមក យើងត្រូវវាយ ឈ្នះចាញ់ ត្រូវដកថយ ឬយ៉ាងម៉េច អាហ្នឹងគឺតាមយើងឯករាជ្យម្ចាស់ការ។ ដូច្នេះគ្មានបញ្ជាការពីខាងលើណាមកបញ្ជាយើងទេ។ ដូច្នេះយើងក្នុងនាមយើងជាបញ្ជាការសមរភូមិនោះត្រូវដោះស្រាយរៀបចំខ្លួនឯង ធ្វើម៉េចការពារកម្លាំងខ្លួនឯងកុំឲ្យគ្រោះថ្នាក់។ អាហ្នឹងគឺម្ចាស់ការអ៊ីចឹង។

**ស៖** តើពាក្យ "ម្ចាស់ការ" ហ្នឹងគឺថាត្រូវបញ្ឈប់កុំឲ្យគេវាយប្រយុទ្ធចូល ហើយនិងបណ្ដេញពួកគេទៅវិញដែរ ឬក៏យ៉ាងម៉េច? ឥឡូវនៅពេលដែលលោកប្រើពាក្យថា "ម្ចាស់ការ" ហ្នឹងលោកចង់និយាយថា ក្ដោបក្ដាប់ទៅលើសកម្មភាពអីខ្លះ?

**ធ៖** ពាក្យថា "ម្ចាស់ការ" ដូចខ្ញុំបញ្ជាក់អ៊ីចឹង។ ក្ដោបក្ដាប់ មិនមែនតែឱបក្ដាប់លើខ្មាំងសត្រូវទេ គឺឱបក្ដោបលើកម្លាំងខ្លួនឯងនេះ។ បើមានសភាពការណ៍ គេវ៉ៃមកយើងខ្លាំង តើយើងត្រូវធ្វើយ៉ាងម៉េច ដើម្បីដោះកុនខ្លួនឯងឲ្យរួចណេះ កុំឲ្យគ្រោះថ្នាក់នេះ។ ត្រូវធ្វើយ៉ាងម៉េច? អាហ្នឹងគឺម្ចាស់ការខ្លួនឯង ក្នុងសមរភូមិគឺគ្មានខាងលើណាមកបញ្ជាថា អ្ហ៎!ត្រូវដក ត្រូវថយអាម៉េចទេ ដូច្នេះបើសភាពការណ៍ត្រូវងាប់ហើយ គេបញ្ជាឲ្យនៅ ស្មានតែនៅ មិននៅទេ ត្រូវតែថយ។ អាហ្នឹងគឺម្ចាស់ការអ៊ីចឹង។ អាហ្នឹងគឺចង់និយាយអ៊ីចឹង។ ម្ចាស់ការ គឺមិនមែនទប់ មិនមែនឃាត់មិនឲ្យសត្រូវចូលទេ អាហ្នឹងឃាត់ហើយ តែបើគេមក មិនដឹងធ្វើម៉េច។ ត្រូវទប់ហើយ ម្ចាស់ការទៅ។ បើគេទប់ -- បើកម្លាំងគេខ្លាំង យើងចាញ់គេ យើងរត់ទៅ យើងថយទៅ។ អាហ្នឹងសូមបញ្ជាក់អ៊ីចឹង។

[១៥:៤៤:៤៥]

**ស៖** នេះសំណួរចុងក្រោយមែនទែនហើយ។ "ម្ចាស់ការ" មានន័យថា ត្រូវគ្រប់គ្រងទៅលើស្ថានការណ៍ទាំងអស់។ តើពាក្យនេះវាឆ្លុះបញ្ចាំងនូវអ្វីដែល តាម៉ុក និង សុន សេន និយាយដែរឬទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អានេះយោងតាមសក្ខីកម្មរបស់ មាស រឿន ថាការការពារបូរណភាពទឹកដីរបស់ខ្លួនត្រូវតែអត់ធ្មត់ស្ងៀមស្ងាត់ អ៊ីចឹងពាក្យថា “ម្ចាស់ការ” កន្លែងហ្នឹង ក៏ដូចពាក្យសម្តីរបស់ សុន សេន និង តាម៉ុក និយាយអ៊ីចឹងដែរឬ?

**ឆ៖** ពាក្យ “ម្ចាស់ការ” នេះបើចង់និយាយទៅថា វាអត់ដូចទេ គាត់និយាយថា បើម្ចាស់ការ បើគេវ៉ៃមកខ្លាំង សុខចិត្តឲ្យងាប់នៅកន្លែង ពាក្យគាត់ថា “ម្ចាស់ការ”។ ឯ “ម្ចាស់ការ” ដែលខ្ញុំនៅអង្គភាពនេះ បើសភាពការណ៍វាគ្របដណ្តប់ខ្លាំង វានេះខ្លាំង ខ្ញុំនៅម៉េចបាន ខ្ញុំត្រូវថយ។ អាហ្នឹងគឺម្ចាស់ការខ្លួនឯង ដោយគ្មានការបញ្ជាពីអ្នកណាទេ គឺខ្លួនឯងបញ្ជាត្រូវថយ ត្រូវដកយ៉ាងម៉េច អាហ្នឹងគឺខ្លួនឯង។ អាហ្នឹងចង់និយាយម្ចាស់ការអ៊ីចឹងទេ គឺមិនម្ចាស់ការអីធំជាងហ្នឹង ច្រើនជាងហ្នឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ អស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោក ជួន ធី សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីដល់ពេលនេះ ដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅពេលនេះ លែងមានភាពចាំបាច់ទៀតហើយ ហើយលោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

[១៥:៤៦:៣៣]

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រីមេធាវី សុក សុជាតា មេធាវីប្រឹក្សាសាក្សី នាពេលនេះ លោកស្រីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ជួន ធី វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយលោក ជួន ធី និងមេធាវីប្រឹក្សាអាចចាកចេញពីបន្ទប់សវនាការបានហើយ! អញ្ជើញចុះ!

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់នូវសារណាផ្ទាល់មាត់របស់ភាគីនៅលើ

សំណើសុំរបស់មេធាវីការពារក្ដី នួន ជា។ កាលពីរសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានទទួលការជូនដំណឹងតាមរយៈអ៊ីម៉ែល ពីក្រុមមេធាវីការពារក្ដី នួន ជា ហើយនាពេលនេះ សំណើនេះបានមានជាភាសាខ្មែរ និងភាសាអង់គ្លេសរួចហើយគឺឯកសារ E448។ ហើយនៅក្នុងសំណើនេះ មេធាវីការពារក្ដី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួនពីរជាឯកសារភស្តុតាងមុនពេលការផ្ដល់សក្ខីកម្មរបស់សាក្សី 2-TCW-1065 និងស្នើសុំឱ្យកោះហៅសាក្សីពីររូបបន្ថែមទៀត។ ហើយនៅព្រឹកមិញនេះ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីរួចហើយ ហើយអង្គជំនុំជម្រះមានបំណងស្ដាប់សារណាផ្ទាល់មាត់របស់ភាគីទៅលើសំណើនេះ នៅពេលរសៀលនេះ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅមេធាវីការពារក្ដី នួន ជា ដើម្បីឡើងធ្វើសេចក្ដីថ្លែងរៀបរាប់សង្ខេបអំពីសំណើសុំរបស់ខ្លួន។

[១៥:៤៨:៣៦]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងជាសង្ខេបទេ។ ខ្ញុំយល់ហើយថា តាមពិតទៅ គឺថាយើងបានដាក់សំណើសុំនេះ យើងបានបញ្ជូនចេញកាលពីម្សិលមិញ<តាមរយៈការ>ផ្ញើអ៊ីម៉ែល <>។ ជាសង្ខេបយើងខ្ញុំបានស្នើសុំឱ្យអង្គជំនុំជម្រះ ទទួលយកជាភស្តុតាងនូវអត្ថបទពីរដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយ <គឺឯកសារ>ដែលយើងទទួលបានពីឃ្លាំងផ្ទុកឯកសាររួម។ នេះគឺការស្វែងរកការពិត ចុះខែកក្កដា ឆ្នាំ២០១៥។ ខ្ញុំមិនលើកឈ្មោះគាត់យកមកនិយាយទេ ដោយសារតែយើងខ្ញុំក៏បានស្នើសុំឱ្យកោះហៅគាត់ឱ្យធ្វើជាសាក្សីពាក់ព័ន្ធទៅនឹងអតីតអង្គរក្ស និងជាចៅរបស់លេខាភូមិភាគបូព៌ា គឺ សោ ភឹម ហើយនិងឯកសារស្វែងរកការពិតមួយទៀត ដែលចេញពីនីរសារ និងអ្នកបើកបររបស់ សោ ភឹម។ យើងបានស្នើសុំឱ្យទទួលយកឯកសារនេះ ភ្លាមៗក្រោយការបោះពុម្ពផ្សាយនៅខែ៩ កញ្ញា ឆ្នាំ២០១៦ គឺឯកសារដែលមាននៅលើ*គេហទំព័របភីង* ហើយសូមឱ្យសាក្សីរូបនេះចូលខ្លួនមកនៅសប្ដាហ៍ក្រោយ។ យើងខ្ញុំយល់ឃើញថា អត្ថបទទាំងពីរនេះ គឺថាវាអាចជួយដល់ការស្វែងរកការពិត ជាពិសេស ផ្នែកមួយដែលសាក្សីបាននិយាយអំពីទំនាក់ទំនងរវាង<>រវាងមេភូមិភាគបូព៌ា សោ ភឹម និង រស់ ញឹម <ហើយនិងដំណើរទស្សនកិច្ចរបស់ពួកគេជាញឹកញាប់>។ ដូចដែលអង្គជំនុំជម្រះបានជ្រាបរួចមកហើយថា ការជំទាស់របស់យើងគឺមានការបះបោរមួយដែលបានរៀបចំឡើងទាំងដោយ សោ ភឹម និង រស់ ញឹម។ យើងខ្ញុំយល់ឃើញថា បុគ្គលទាំងពីរនេះ អ្វីៗដែលទាក់ទងទៅនឹង

សោ ភឹម មិនមែនតែពាក់ព័ន្ធតែត្រឹមទ្រឹស្តីតែប៉ុណ្ណោះទេ ក៏ប៉ុន្តែសាក្សី<ដែលនឹងមកបំភ្លឺនៅពេលខាងមុខនេះគឺ> 2-TCW-1065 ក៏<នឹង>ផ្តល់សក្ខីកម្មអំពីការបះបោរនៅភូមិភាគបូព៌ា និងការបោសសម្អាតនៅភូមិភាគបូព៌ាផងដែរ។ អ៊ីចឹងជាសង្ខេប នេះឯងគឺជាសារតារនៃសំណើសុំរបស់យើងខ្ញុំ។

[១៥:៥១:១៦]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយជាបន្តទៅនេះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានតប ឬក៏ធ្វើការកត់សម្គាល់លើសំណើសុំរបស់មេធាវីការពារក្តី នួន ជា។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំមិនមានការជំទាស់ទៅនឹងសំណើសុំឲ្យទទួលយកឯកសារទាំងពីរពីមជ្ឈមណ្ឌលឯកសារកម្ពុជានេះទេ <ប៉ុន្តែត្រូវគោរពតាមកិច្ចព្រមព្រៀង>។ តាមធម្មតានៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពផ្សាយនូវឯកសាររបស់ខ្លួន គឺទស្សនាវដ្តីស្វែងរកការពិត <គឺពួកគេផ្អែក>ទៅនឹងកិច្ចសម្ភាសន៍<ពេញលេញ ដែលបានធ្វើ>ជាមួយបុគ្គលណាមួយនោះ។ ដូច្នេះយើងខ្ញុំគ្រាន់តែធ្វើការកត់សម្គាល់ថា បើទទួលយកឯកសារនេះ ត្រូវតម្រូវឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ផ្តល់នូវកិច្ចសម្ភាសន៍ឲ្យបានពេញលេញជាមួយបុគ្គល<ទាំងអស់នេះ ទោះជាប្រតិចារឹកក៏ដោយ។ ហើយដូច្នេះ ខ្ញុំគិតថា ឯកសារទាំងអស់នោះក៏ត្រូវតែទទួលយកផងដែរ ដើម្បីឲ្យ>យើងមានប្រតិចារឹកនេះពេញលេញ ពាក់ព័ន្ធទៅនឹងការសម្ភាសបុគ្គលរូបណានោះ។

[១៥:៥២:៣៥]

ទាក់ទងទៅនឹងសំណើសុំឲ្យកោះហៅ<ពួកគេមកធ្វើជា>សាក្សី ពិតណាស់ ពួកគេមានព័ត៌មានពាក់ព័ន្ធ។ <ប៉ុន្តែតាមទស្សនៈរបស់យើង> នេះគឺជាឆន្ទានុសិទ្ធរបស់អង្គជំនុំជម្រះទេ ដែលត្រូវសម្រេចថាត្រូវកោះហៅមកផ្តល់សក្ខីកម្ម ឬក៏យ៉ាងណានោះ។ <ខ្ញុំលើកឡើងពីរចំណុច។ ទី១> នៅពេលដែលយើងខ្ញុំមើលទៅលើភស្តុតាងទាំងអស់នេះ <យើង>ពិបាកយល់ថាព័ត៌មានទាំងអស់ហ្នឹង វាជួយដល់មេធាវីការពារក្តីដោយរបៀបណាណាស់។ <វាពិតជាមិនគាំទ្រដល់ការស៊ើបអង្កេតលើទ្រឹស្តី ដែលយើងបានឮពីពួកគេនោះទេ ទោះបីជាភស្តុតាងរបស់ពួកគេមានភាពពាក់ព័ន្ធក៏ដោយ។ ដូច្នេះបើ>អង្គជំនុំជម្រះយល់ឃើញថា <វាមានប្រយោជន៍ នោះគឺយើងខ្ញុំមិនជំទាស់អ្វី>ទេ។ <យើងសង្កេតឃើញដែរថាយើងបានមកដល់ទីបញ្ចប់នៃការជំនុំជម្រះនេះហើយ។> រយៈពេល២ឆ្នាំមកហើយនៅក្នុងសំណុំរឿង

នេះ គឺថាតាំងពីខែតុលា ឆ្នាំ<២០១៤>មកម្ល៉េះ អ៊ីចឹងយើងចង់បញ្ចប់កិច្ចដំណើរការនីតិវិធីឲ្យបានលឿន។ អ៊ីចឹងសរុបមកវិញ គឺថាការកោះហៅសាក្សីណាមួយនោះ គឺជាឆន្ទានុសិទ្ធរបស់អង្គជំនុំជម្រះហើយ យើងខ្ញុំមិនជំទាស់ទេ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ហើយបន្តទៅនេះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន យ៉ាងម៉េចដែរ មានអ្វីកត់សម្គាល់ឬក៏មានការតបទៅនឹងសំណើសុំនេះដែរឬទេ?

[១៥:៥៤:២៩]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន យើងខ្ញុំមិនមានការជំទាស់អ្វីទេ ពាក់ព័ន្ធនឹងការស្នើសុំឲ្យកោះហៅសាក្សីនេះ។ មេធាវីការពារក្តី នួន ជា គាត់មានព័ត៌មានសម្រាប់សួរសាក្សីរូបនោះ អ៊ីចឹងគួរតែទទួលយកតាមការស្នើសុំលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ការឆ្លើយតប និងកត់សម្គាល់ខ្លីពីរទេ លោកប្រធាន។ តាមពិតយើងកំពុងនៅក្នុងដំណើរការមួយកំណត់ទៅលើកិច្ចសម្ភាសន៍ មានន័យថា គឺស្នើសុំឲ្យទទួលយកឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជានេះឯង។ អ៊ីចឹងបើសិនជាអង្គជំនុំជម្រះមិនយល់ទាស់ទេ យើងខ្ញុំនឹងខិតខំប្រឹងប្រែងទៅតាមនោះ។ ទី២ ឆ្លើយតបទៅនឹងការចោទប្រកាន់មិនមានមូលដ្ឋាន ពាក់ព័ន្ធទៅនឹងទ្រឹស្តីនៃការសមគំនិតនេះ យើងខ្ញុំសូមដកសំណើសុំនេះចេញវិញភ្លាម។ លោកប្រធាន <បើលោកត្រូវកោះហៅបុគ្គលណានោះ> តាមការពិតគឺបុគ្គលនេះ គឺថាជាអ្នកដែលជិតដិតនឹង សោ ភឹម បំផុត។ យើងបានស្នើសុំ៩ឆ្នាំ ឲ្យកោះហៅ ហេង សំរិន, អ៊ុក ប៊ុនឈឿន <និង ប៉ុល សារឿន>ជាដើម ។ល។ ៩ឆ្នាំហើយ ដូចនៅក្នុងកថាខណ្ឌ៥នៃសំណើសុំរបស់យើងខ្ញុំ។ មកតាមពិត បុគ្គលទាំងអស់នេះទេ ទើបជាសាក្សីដ៏សំខាន់។ <ហើយបើសិនជាពួកគេមកមែន យើងមិនចាំបាច់ត្រូវធ្វើសក្ខីកម្មជាមួយ>នឹងសាក្សី 2-TCW-1065 <ឬក៏>អ្នកបើកបរ <ឬក៏

អង្គរក្ស ឬក៏អ្វីនោះទេ>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណនូវរាល់មតិយោបល់របស់ភាគី ពាក់ព័ន្ធនឹងសំណើសុំរបស់ នួន ជា នេះ។ ហើយអង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិនិត្យពិចារណាសម្រេច ហើយនិងចេញសេចក្តីសម្រេចលើសំណើនេះឲ្យបានឆាប់បំផុត តាមតែអាចធ្វើទៅបាន។

បាទ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២៧ ខែតុលា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-1045 ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូប ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៧ នាទី)*